ក្រសួងអប់រំ យុវជន និងកីឡា

**Ministry of Education, Youth and Sport**

វិទ្យាស្ថានជាតិអប់រំ

**National Institute of Education**

# និក្ខេបបទ

# កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង

FACTORS AFFECTING THE LEARNING OUTCOME OF ENGLISH SUBJECT FOR HIGH SCHOOL STUDENTS IN PREY VENG PROVINCE, CAMBODIA


ដោយ/ BY

ចែម ចិន្តា / **CHEM CHENDA**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

**ក្រសួងអប់រំ យុវជន និងកីឡា**

**Ministry of Education, Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**

**National Institute of Education**

# និក្ខេបបទ

# កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង

FACTORS AFFECTING THE LEARNING OUTCOME OF ENGLISH SUBJECT FOR HIGH SCHOOL STUDENTS IN PREY VENG PROVINCE, CAMBODIA


**ដោយ**/ BY

**ចែម ចិន្ដា / CHEM CHENDA**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**


**គ្រូដឹកនាំបង្គោល ៖ លោក ឌី បុណ្ណា**

**គ្រូដឹកនាំរង ៖ បណ្ឌិត ឈាង សទ្ធាត**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ។ សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះសុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់។

និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ...............ខែ............. ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..... ខែ...... ឆ្នាំ ២០២០

**ហត្ថលេខាបេក្ខជន**

**ចែម ចិន្តា**

# លិខិតបញ្ជាក់

លោក **ឌី ប៊ុណ្ណា** ជាគ្រូដឹកនាំបង្គោល

បណ្ឌិត **ឈាង សទ្ធាត** ជាគ្រូដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ចែម ចិន្តា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសារអង់គ្លេស នៅខេត្តព្រៃវែង**» ពិតប្រាកដមែន។

ថ្ងៃ.................. ខែ................. ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ....... ឆ្នាំ២០២០

..................................... ..........................................

**លោក ឌី ប៊ុណ្ណា**
នាយករងវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត ឈាង សទ្ធាត**
គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៦៣៤៧ **អយក.**[illegible]

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF-Cambodia International Education Support Foundation) ដែលផ្តល់កិច្ចគាំទ្រ និងឱកាសដល់រូបខ្ញុំបាទបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ដល់ខ្ញុំបាទ ក៏ដូចជាមិត្តភក្តិទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់**លោក ប៉ាវ សុធីរ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង លោកប្រធានការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ដែលបានចូលរួមសហការក្នុងការប្រមូលទិន្នន័យតាមកម្រងសំនួរនៅខេត្តព្រៃវែង ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យ ឌី មុន្នីណា** ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត និងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំបាទទទួលបានជោគជ័យ និង ជានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមអរគុណដល់ **បណ្ឌិត ឈាង សទ្ធាត** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង និងចែករំលែកបទពិសោធន៍ជាច្រើន ដល់រូបខ្ញុំបាទ រហូតដល់សម្រេចបានជាលទ្ធផលល្អប្រសើរ។

ខ្ញុំបាទសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូង ចំពោះក្រុមគ្រួសារ លោកពុក និងអ្នកម្តាយ ពូមីង បងប្អូន ដែលបានផ្តល់ការគាំទ្រជានិច្ច តែងតែលើកទឹកចិត្តរហូតមក និងផ្តល់ឱកាសឱ្យរូបខ្ញុំបាទបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់ តាមក្តីប្រាថ្នា។

សូមអរគុណ!

# មាតិកា

**ជំពូកទី ១ សេចក្តីផ្តើម** ........ 1

១.១ លំនាំបញ្ហា នៃការស្រាវជ្រាវ ........ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 5

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤ សំណួរស្រាវជ្រាវ ........ 6

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 6

១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ ........ 7

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

**ជំពូកទី២ រំឭកទ្រឹស្តី** ........ 9

២.១ និយមន័យ ........ 9

២.២ ព័ត៌មានទូទៅស្តីពីខេត្តព្រៃវែង ........ 9

២.៣ ការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ........ 10

២.៤ តួនាទីគ្រូបង្រៀនសតវត្សទី ២១ ........ 11

២.៤.១ លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនសតវត្សទី២១ ........ 11

២.៥ បញ្ហាប្រឈមលើការរៀនភាសាអង់គ្លេស ........ 12

២.៥.១ ការរៀន និងបង្រៀនភាសាអង់គ្លេសក្នុងថ្នាក់ ........ 14

២.៥.២ ឥរិយាបថ ចំពោះការសិក្សាភាសារបស់សិស្ស ........ 16

២.៥.៣ ការលើកទឹកចិត្ត និង ការសិក្សាភាសា ........ 16

២.៦ មូលហេតុនៃភាពកម្សោយក្នុងការរៀនភាសាអង់គ្លេស ........ 18

២.៦.១ ការលើកទឹកចិត្តសម្រាប់ការរៀនភាសាអង់គ្លេស ........ 19

២.៧ យុទ្ធសាស្ត្ររៀនភាសាអង់គ្លេស ........ 20

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ........ 22

៣.១ គម្រោងវិភាគ (Analysis Plan) ........ 22

៣.២ ការប្រមូលទិន្នន័យ ( Data collection) ....22
៣.៣ ឧបករណ៍ស្រាវជ្រាវ....23
៣.៣.១ កម្រិតចង្អុលបង្ហាញ....24
៣.៣.២ កម្រងសំណួរ....25
៣.៤ ការជ្រើសរើសភាគសំណាក....28
៣.៥ ការវិភាគទិន្នន័យ....29
**ជំពូកទី៤ លទ្ធផល និងការពិភាក្សា**....31
៤.១.ព័ត៌មានទូទៅរបស់អ្នកចូលរួម....31
៤.១.១ ព័ត៌មានទូទៅពីគ្រូបង្រៀន....31
៤.១.២ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង....32
៤.១.៣ ព័ត៌មានទូទៅពីសិស្សានុសិស្ស....32
៤.២ កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....33
៤.២.១ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....33
៤.២.២ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....37
៤.២.៣ ទិន្នន័យពីការឆ្លើយតបរបស់សិស្ស កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....43
៤.៣ លទ្ធផលសរុបនៃការឆ្លើយតប របស់គ្រូបង្រៀន គណៈគ្រប់គ្រង និងសិស្សលើកត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....48
៤.៤ ការពិភាក្សាលើកត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យម....49
សិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស....49
៤.៥ ទិន្នន័យលើដំណោះស្រាយជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អ....52

៤.៥.១ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន ដើម្បីជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អប្រសើរ ....52
៤.៥.២ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង ជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អប្រសើរ ....55
៤.៦ លទ្ធផលនៃការឆ្លើយតបសរុបពី គ្រូបង្រៀន និងគណៈគ្រប់គ្រង លើការជំរុញលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស ....59
៤.៧ ការពិភាក្សាលើការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសបានល្អ ....60
**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ....64
៥.១ សេចក្តីសន្និដ្ឋាន ....64
៥.២ សំណូមពរ ....67
ឯកសារយោង ....69
ឧបសម្ព័ន្ធ ក ....71
ឧបសម្ព័ន្ធ ខ ....78
ឧបសម្ព័ន្ធ គ ....85
ឧបសម្ព័ន្ធ ឃ ....89

# តារាងទិន្នន័យ


*តារាង 3.1៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ*..........29
*តារាង 4.1៖ ក.ការអនុវត្តកម្មវិធីសិក្សា*..........33
*តារាង 4.2៖ ខ.ដំណើរការបង្រៀន*..........34
*តារាង 4.3៖ គ.ទំនាក់ទំនងគ្រូ-សិស្ស*..........35
*តារាង 4.4៖ ឃ. ការប្រើប្រាស់សម្ភារៈឧបទ្ទេស*..........36
*តារាង 4.5៖ ទិន្នន័យសរុបរបស់គ្រូបង្រៀន*..........37
*តារាង 4.6 ៖ ក. ការរៀបចំផែនការ*..........38
*តារាង 4.7៖ ខ. ការកសាងសមត្ថភាពគ្រូ*..........39
*តារាង 4.8៖ គ. ការកសាងសមត្ថភាពសិស្ស*..........40
*តារាង 4.9៖ ឃ. ភាគីពាក់ព័ន្ធ*..........40
*តារាង 4.10៖ ង. ធនធានរូបវន្ត*..........41
*តារាង 4.11៖ ច. ការធានាគុណភាព*..........42
*តារាង 4.12៖ ទិន្នន័យសរុបរបស់គណៈគ្រប់គ្រង*..........43
*តារាង 4.13៖ ក. អំពីមេរៀន*..........43
*តារាង 4.14៖ ខ. អំពីការបង្រៀន*..........44
*តារាង 4.15៖ គ. ទំនាក់ទំនងគ្រូ-សិស្ស*..........45
*តារាង 4.16៖ ឃ. ការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស*..........46
*តារាង 4.17៖ ទិន្នន័យសរុបរបស់សិស្សានុសិស្ស*..........47
*តារាង 4.18៖ មធ្យមភាគសរុបរបស់គ្រូបង្រៀន គណៈគ្រប់គ្រង និង សិស្ស*..........48
*តារាង 4.19៖ ក. កត្តាគណៈគ្រប់គ្រង*..........52
*តារាង 4.20៖ ខ. កត្តាគ្រូបង្រៀន*..........53
*តារាង 4.21៖ គ. កត្តាសិស្ស*..........54
*តារាង 4.22៖ ទិន្នន័យសរុបលើចម្លើយតបរបស់គ្រូបង្រៀន*..........55
*តារាង 4.23៖ ក. កត្តាគណៈគ្រប់គ្រង*..........56
*តារាង 4.24៖ ខ. កត្តាគ្រូបង្រៀន*..........57
*តារាង 4.25៖ គ. កត្តាសិស្ស*..........58
*តារាង 4.26៖ ទិន្នន័យសរុបលើចម្លើយតបរបស់គណៈគ្រប់គ្រង*..........59
*តារាង 4.27៖ មធ្យមភាគសរុបរបស់គណៈគ្រប់គ្រង និង គ្រូបង្រៀន*..........60

# បញ្ជីអក្សរកាត់

| | |
|---|---|
| ល.រ | : លេខរៀង |
| វិ. | : វិទ្យាល័យ |
| CamTESOL | : Cambodia Teaching English to Speaker of Other Language |
| CIESF | : Cambodia International Education Support Foundation |
| COVID-19 | : Corona Virus Disease 2019 |
| EFL | : English as a Foreign Language |
| ESL | : English as a Second Language |
| ICT | : Information Computer Technology |
| No | : Number |
| SLA | : Second Language Acquisition |
| UNESCO | : United Nation Educational Scientific and Cultural Organization |
| Vol | : Volume |
| WER | : World Education Report |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវពីកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅខេត្តព្រៃវែង មានគោលបំណងសិក្សាស្វែងយល់ពីកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡង និងដំណោះស្រាយក្នុងការជំរុញឱ្យលទ្ធផលប្រឡងលើមុខវិជ្ជាភាសាអង់គ្លេសបានល្អប្រសើរឡើងវិញ ។

វិធីសាស្ត្រស្រាវជ្រាវ គឺអនុវត្តតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ នៅវិទ្យាល័យចំនួន ៦នៅខេត្តព្រៃវែង ដែលមានចំនួនសំណាកសរុប ១០០ នាក់ លោកគ្រូ-អ្នកគ្រូ ចំនួន ២០នាក់ គណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ និងសិស្សានុសិស្សចំនួន៦០នាក់។ ការវិភាគទិន្នន័យសិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈការវិភាគលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា គណៈគ្រប់គ្រងសាលាមិនសូវមានឥទ្ធិពលដល់លទ្ធផលប្រឡងរបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសទេ។ តែផ្ទុយទៅវិញ កត្តាដែលជះឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលប្រឡងគឺ កត្តាធនធានរូបវន្ត ការប្រើប្រាស់សម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀននិងរៀន មេរៀនក្នុងសៀវភៅសិក្សាគោល និង ការយកចិត្តទុកដាក់របស់សិស្សលើការសិក្សាភាសាអង់គ្លេស។គ្រូបង្រៀនមិនមានសម្ភារៈឧបទ្ទេសបង្រៀនគ្រប់គ្រាន់ពេលបង្រៀនធ្វើឱ្យសិស្សពិបាកយល់លើខ្លឹមសារមេរៀន សាលាខ្វះបន្ទប់អនុវត្តភាសាអង់គ្លេសដែលធ្វើឱ្យសិស្សគ្មានឱកាសអភិវឌ្ឍន៍ជំនាញមេរៀនពិបាកយល់ដោយមិនសូវបានផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្ស និងសិស្សខ្លួនឯងមិនយកចិត្តទុកដាក់រៀនសូត្រ ដែលកត្តាទាំងអស់នេះហើយជាមូលហេតុធ្វើឱ្យលទ្ធផលប្រឡងរបស់សិស្សមិនល្អ (ធ្លាក់ច្រើន)។ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវក៏បានបង្ហាញពីដំណោះស្រាយក្នុងការជំរុញឱ្យលទ្ធផលប្រឡងបានល្អប្រសើរឡើងវិញផងដែរ ដោយការសិក្សាស្រាវជ្រាវបានបង្ហាញថា ការធានាបាននូវគុណភាពសិក្សារបស់សិស្សត្រូវពឹងផ្អែកទាំងស្រុងលើគ្រូបង្រៀនព្រោះគ្រូបង្រៀនជាអ្នកអនុវត្តន៍កម្មវិធីសិក្សាដោយផ្ទាល់ អ្នកតម្រង់ទិស អ្នកប្រឹក្សាយោបល់ ជាស្ពានសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនាពេលអនាគត និងជាអ្នកនៅជាមួយសិស្សជាប្រចាំ។ មានតែគ្រូបង្រៀនទេដែលដឹងថាសិស្សរបស់គាត់សិក្សា

យ៉ាងដូចម្តេច?។ ជាមួយគ្នានោះ ក៏មានការរួមចំណែករបស់គណៈគ្រប់គ្រងសាលាផងដែរ។ គ្រូបង្រៀនដែលមានឆន្ទៈមុតស្រួចអាស្រ័យលើគណៈគ្រប់គ្រងព្រោះគណៈគ្រប់គ្រងជាអ្នកជួយគាំទ្រដល់ការបង្រៀន និងរៀន ពិសេសគណៈគ្រប់គ្រងជាអ្នកមានទំនាក់ទំនងផ្ទាល់ជាមួយថ្នាក់ដឹកនាំអប់រំក្នុងមូលដ្ឋានថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។ បើគណៈគ្រប់គ្រងល្អ គ្រូបង្រៀននឹងពេញចិត្តបំពេញការងារប្រកបដោយទំនួលខុសត្រូវ និងឆន្ទៈដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សល្អផងដែរ(ជាប់ច្រើន)។ បន្ថែមពីនេះទៅទៀត ការចូលរួមសហការរបស់សិស្សក៏សំខាន់ណាស់ដែរ ព្រោះបើទោះបីជាគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាបានបំពេញតួនាទីបានល្អប្រសើរក្តី តែសិស្សានុសិស្សមិនចូលរួមសហការនោះ គឺពិតជារាំងស្ទះដល់លទ្ធផលសិក្សាដូចគ្នា។

ជារួមការកំណត់បាននូវកត្តាជះឥទ្ធិពល និងដំណោះស្រាយដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសដែលបានសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ ពិតជាឆ្លុះបញ្ចាំងលើការធានាបាននូវគុណភាពសិក្សា ហើយអាចឆ្លើយតបទៅនឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន គន្លងអាជីពគ្រូបង្រៀន គោលនយោបាយសាលារៀនជំនាន់ថ្មី និងការធានាគុណភាពអប់រំនៅកម្ពុជា។

## Abstract

The purposes of this study intend to reveal the factors affecting the learning outcome of English subject for high school students in prey veng province, and effective solutions enhancing students' learning outcome.

The research methodology used in this study is quantitative method. The questionnaires were designed to collect the data from 6 high schools in Prey Veng province with a total number of 100 samples, 20 teachers, 20 school principals and 60 students. The data collected from participants are identified on percentage and mean of each variable. According to the research results, school principals did not have much influence on the students' achievement in English subject, as the school principals performed their duties well in management. On the contrary, the most influential factors on students' learning achievement are teachers and students themselves including the lack of teaching and learning materials for teachers and students, the lack of physical resources, the lessons in the textbooks, and the students' attitude to learning English. If teachers do not have enough teaching materials, it will be difficult for students to understand the content of lessons. Lack of English practice room causes students have no opportunity to develop English four macro-skills. Most of the lessons are hard to understand because of no connection to students' lifestyles and the last point is students themselves. These are the factors for students' low achievement on English subject at high school at Prey Veng province. However, research has also shown the solutions enhancing students' achievement on English. The study showed that ensuring the quality of students' learning depends entirely on teachers because teachers are considered as advisor, door keeper, and curriculum practitioners; and teachers are always with students almost every day. Only a teacher knows what his students are like. Also, school principals are considered as an important solution, because teachers with a strong will depend on the management. If the school principals are good, the teachers will be satisfied to work responsibly and willingly, which will also lead to good results for each student. In addition, students' involvement is also important, because although teachers and school principals have done a good job, but students do not cooperate it is believed that the academic results will also be hindered.

Overall, the factors affecting the learning outcome of English subject for high school students in prey veng province, and effective solutions enhancing students' learning outcome. really reflects on ensuring the quality of education in response to teachers professional ethics, teachers career pathway, new school policy and quality assurance in Cambodia.


*Keyword : Factor Influences, English proficiency, students' learning outcome, effective solution*

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហា នៃការស្រាវជ្រាវ

ការប្រាស្រ័យទាក់ទងគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងពីជាតិសាសន៍មួយទៅជាតិសាសន៍មួយទៀត គឺមានសារៈសំខាន់ណាស់តាំងពីអតីតកាល ពេលបច្ចុប្បន្ន និងនាពេលអនាគត តាមរយៈការបង្ហាញជាកាយវិការ ពាក្យសម្តី និងពិសេសនោះ គឺភាសា។ មនុស្សជាតិចែករំលែកពីរឿងរ៉ាវ បទពិសោធន៍ ឬ សកម្មភាពនានាពីអតីតកាល ហើយផ្ទេរប្រេកពទាំងនេះពីជំនាន់មួយទៅជំនាន់មួយ ហើយរឹតតែធ្វើឱ្យក្មេងជំនាន់ក្រោយកាន់តែរកឃើញនូវអ្វីៗដែលថ្មី និងមានបច្ចេកវិទ្យាកាន់តែជឿនលឿនឡើងៗ គឺតាមរយៈការប្រើប្រាស់ភាសានេះឯង។ បើយើងក្រឡេកមើលនិន្នាការពិភពលោក មានការប្រើប្រាស់ភាសា ក្នុងការប្រាស្រ័យទាក់ទងគ្នាតាមជាតិសាសន៍នីមួយៗ ជាច្រើនបែបសណ្ឋាន ដូចជា ភាសាខ្មែរ បារាំង ចិន និងភាសាអង់គ្លេស ជាដើម។គួយ៉ាងនៅប្រទេសកម្ពុជាក្នុងអំឡុងពេលប្រមាណជាជាងសាមសិបឆ្នាំចុងក្រោយនេះ ការសិក្សារៀនសូត្រភាសាបរទេសក៏ត្រូវបានកំពុងតែពេញនិយមជាខ្លាំងសម្រាប់អ្នកជំនួញ អ្នកបច្ចេកទេស អ្នកការទូត និស្សិត និង សិស្សានុសិស្សស្ទើរគ្រប់កម្រិតថ្នាក់តាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សា។ទាំងអស់នេះគឺពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការខិតខំប្រឹងប្រែង និង យកចិត្តទុកដាក់ អភិវឌ្ឍន៍ និង ផលិតធនធានមនុស្សក្នុងការរួមចំណែកជាមួយរដ្ឋាភិបាលក្នុងកិច្ចការកសាងប្រទេសជាតិដើម្បីឱ្យសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលនយោបាយជាតិនានាផងដែរ។ ដោយមើលឃើញពីសក្តានុពលនេះ ក្រសួង អប់រំ យុវជន និងកីឡា បានដាក់ចេញនូវចក្ខុវិស័យការកំណែទម្រង់វិស័យអប់រំ ដែលមានសសរស្តម្ភប្រាំជាមូលដ្ឋាន ។តាមរយៈកំណែទម្រង់នេះ វិស័យអប់រំនៅកម្ពុជាបានប្រែក្លាយខ្លួនគួរឱ្យកត់សម្គាល់ ពិសេសក្នុងអំឡុងពេលប្រមាណជាជាង ៥ ឆ្នាំចុងក្រោយនេះ លើការពង្រឹងការប្រឡងគ្រប់

ប្រភេទ។ជាឧទាហរណ៍ ការប្រឡងគ្រូបង្រៀនគ្រប់កម្រិត និង ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានផ្លាស់ប្តូរឥរិយាបថ មិនត្រឹមតែបុគ្គលិកអប់រំ (អនុរក្ស)ប៉ុណ្ណោះទេ ថែមទាំងនិស្សិត និង សិស្ស (និយាយឱ្យចំបេក្ខជនប្រឡង) ស្ទើរតែទាំងស្រុង ដោយការប្រែក្លាយ ពីការលួចកែពិន្ទុសិស្ស ជួយសរសេរចម្លើយឱ្យសិស្ស ការគាបសង្កត់សិស្សយកលុយក្នុងអំឡុងពេលប្រឡង ការឱ្យលួចចម្លងឯកសារ ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចក្នុងការប្រឡង ការសូកប៉ាន់គ្រូក្នុងពេលប្រឡង ការផ្លាស់ប្តូរកិច្ចការ និង កែលទ្ធផលប្រឡង ឱ្យទៅការងាកមករកការខិតខំរៀនសូត្រដោយខ្លួនឯង និងចាប់ផ្តើមកាន់សៀវភៅឡើងវិញគ្រប់ៗគ្នា ស្ថិតនៅក្រោមពាក្យស្លោកមួយឃ្លារបស់រដ្ឋមន្ត្រីក្រសួងអប់រំបានលើកឡើងថា " **អ្នកចេះ គឺជាប់**"។ ស្ថិតក្រោមបរិយាកាស រឹតត្បិតដ៏ហ្មត់ចត់នេះ បានធ្វើឱ្យសិស្សានុសិស្ស ពិសេសអាណាព្យាបាលដែលយកចិត្តទុកដាក់លើការសិក្សារបស់កូនៗ សម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ពិសេសវាក៏បានលើកស្ទួយដល់តម្លៃអ្នកសិក្សាពិតប្រាកដ និងបានលើកមុខមាត់ និងកិត្តិយសគ្រូបង្រៀន (អនុរក្ស ឬគណៈកម្មការប្រឡង)ឡើយវិញផងដែរ។ក្នុងន័យនេះចង់បញ្ជាក់ឱ្យឃើញច្បាស់ថា ជោគជ័យដ៏ធំធេងមួយនេះ មិនត្រឹមតែជាជោគជ័យរបស់សិស្សានុសិស្ស អាណាព្យាបាលសិស្ស ឪពុកម្តាយ ក្រសួងអប់រំ និងរាជរដ្ឋាភិបាលប៉ុណ្ណោះទេតែជាជោគជ័យសម្រាប់ទាំងអស់គ្នាក្នុងនាមជាប្រជាជនកម្ពុជាតែមួយ។ជាមួយគ្នានេះដែរ តាមរយៈការពង្រឹងការប្រឡងគ្រប់ប្រភេទនេះ វាពិតជាបានឆ្លុះបញ្ចាំងពីការធានានូវគុណភាពអប់រំនៅកម្ពុជាដែលឆ្លើយតបទៅនឹងសសរស្តម្ភទាំង ៥ របស់ក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការពិនិត្យឡើងវិញ កម្មវិធីសិក្សា សៀវភៅសិក្សាគោល បរិស្ថានសិក្សា (៣) ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់តំបន់ ថ្នាក់ជាតិ និងអន្តរជាតិ (៥) កំណែទម្រង់ឧត្តមសិក្សា ( បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឆ្នាំ២០១៦ ទំព័រ ២៧ ដល់ ៣៣)។ ឈរលើមូលដ្ឋានទាំង ៥ចំណុចនេះ គឺពិតជាអាចផលិតបាននូវធនធានមនុស្សពិតប្រាកដប្រកបដោយគុណភាព ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដល់ការអភិវឌ្ឍមូលធនមនុស្សដែលសមស្របទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួនសម្រាប់ " ការធ្វើឱ្យមានកំណើន មានការងារធ្វើ

សមធម៌ និងប្រសិទ្ធភាព" ដើម្បីឆ្ពោះទៅរកការសម្រេចចក្ខុវិស័យនៃការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។ ដើម្បីគាំទ្រដល់ចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញគោលនយោបាយស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល ៤ ចំណុច គឺ(១)ធានាឱ្យមានការអប់រំប្រកបដោយគុណភាពនិងបរិយាបន្ន(២)លើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា(៣)ធានានូវភាពជាអ្នកដឹកនាំ(៤)និងការគ្រប់គ្រងបុគ្គលិកអប់រំប្រកបដោយប្រសិទ្ធភាពដែលគោលដៅទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល(15th Annual CamTESOL Conference Handbook: P2)។ ក្រៅអំពីកិច្ចការទាំងអស់ខាងលើ ប្រមុខរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់លើមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និស្សិត និង សិស្សានុសិស្ស ក្នុងការជំរុញ និងលើកទឹកចិត្តឱ្យខិតខំអភិវឌ្ឍសមត្ថភាព លើគ្រប់មុខវិជ្ជាវិជ្ជាជីវៈ និង មុខវិជ្ជាសិក្សាដើម្បីក្លាយជាមនុស្សគំរូល្អ និង ធនធានពេញលេញសម្រាប់ ខ្លួនឯង គ្រួសារ សហគមន៍ និង សង្គមជាតិ។ ពិសេសការយល់ដឹងលើ បច្ចេកវិទ្យា និងភាសាបរទេសគឺកាន់តែមានសារៈសំខាន់មួយកម្រិតទៀត។ ថ្វីបើប្រទេសកម្ពុជាទើបតែរួចផុតពីរបបប្រល័យពូជសាសន៍ក្តី រាជរដ្ឋាភិបាលក៏ដូចជាក្រសួងអប់រំបានប្រឹងប្រែងប្រមែប្រមូលធនធានមនុស្សដែលនៅសេសសល់ឱ្យជួយបង្រៀនសិស្សអំពីភាសាបរទេស ដូចជា ភាសាបារាំង និង អង់គ្លេស ជាដើម ។ ដោយមើលឃើញពីវិសាលភាពនៃការរីកដុះដាលលើការប្រើប្រាស់ភាសាបរទេស ពិសេសភាសាអង់គ្លេស ក្នុងការទំនាក់ទំនងជាមួយអន្តរជាតិ និងទីផ្សារការងារ ក្រសួងអប់រំក៏បានសម្រេចដាក់មុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សារបស់រដ្ឋ ដើម្បីបើកនូវទំព័រប្រវត្តិសាស្ត្រលើភាសាបរទេសមួយនេះនៅចុងសតវត្សទី១៩។ ដោយផ្អែកលើតម្រូវការរបស់អ្នកសិក្សា ក្រសួងអប់រំបានសម្រេចបន្ថែមមុខវិជ្ជាភាសាអង់គ្លេស ជាមុខវិជ្ជាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ ២០០៦។ ទោះជាយ៉ាងណាក្តី ការដាក់ភាសាអង់គ្លេសសម្រាប់ការប្រឡងនេះគឺគ្រាន់តែជាមុខវិជ្ជាបន្ថែមពិន្ទុតែប៉ុណ្ណោះ មានន័យថាសិស្សមិនត្រូវបានដកពិន្ទុពីមុខវិជ្ជានេះឡើយ បើទោះបីជាសិស្សធ្វើបាន ឬមិនបានក្តី ។ ចាប់តាំងពីពេលនោះមក ភាសាអង់គ្លេសបានក្លាយជាភាសាសេដ្ឋកិច្ចដ៏សំខាន់សម្រាប់គ្រូបង្រៀនមុខវិជ្ជានេះ។យ៉ាងណាមិញ បើយើងក្រលេក

មើលលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន អត្រាសិស្សដែលប្រឡងជាប់មានការកើនឡើងជាលំដាប់។ ជាលទ្ធផលក្នុងឆ្នាំ ២០១៤ ប្រឡងពីរលើកមានចំនួន ៤២% ភាគរយ ឆ្នាំ ២០១៥មានចំនួន ៥៥,៨៨ ភាគរយ ឆ្នាំពី២០១៦ មានចំនួន ៦២,១៨ ភាគរយ ឆ្នាំ ២០១៧ មានចំនួន ៦៣,៨៤ ភាគរយ ឆ្នាំ ២០១៨ មានចំនួន ៦៧,០៧ ភាគរយ និង ឆ្នាំ ២០១៩ មានចំនួន ៦៨,៦៦ ភាគរយ។ ការកើនឡើងនូវអត្រាសិស្ស ប្រឡងជាប់នេះ ជាផលវិជ្ជមានមួយដែលឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់គុណភាពអប់រំប្រកបដោយប្រសិទ្ធភាព។ តែផ្ទុយទៅវិញ ទោះបីអត្រាសិស្សប្រឡងជាប់មានការកើនឡើង គេនៅតែសង្កេតឃើញថាអត្រាជាប់តាមមុខវិជ្ជានីមួយៗនៅមិនទាន់ល្អនៅឡើយ ដោយមុខវិជ្ជាខ្លះសិស្សបានពិន្ទុល្អប្រសើរ ខ្លះទៀតធ្វើបានពិន្ទុល្អ ខ្លះទៀតធ្វើបានមធ្យម និង ខ្លះទៀតនៅខ្សោយនៅឡើយ។ក្នុងចំណោមមុខវិជ្ជាប្រឡងទាំងអស់នោះ មុខវិជ្ជាដែលសិស្សនៅតែទទួលបានអត្រាទាបជាងគេបំផុតគឺ ភាសាអង់គ្លេស។បើយោងតាមលទ្ធផលប្រឡងតាមឆ្នាំនីមួយៗ(២០១៤-២០១៩)អត្រាប្រឡងជាប់លើមុខវិជ្ជាភាសាអង់គ្លេសមានភាគរយប្រឡងជាប់ទាបជាងគេបំផុត បើប្រៀបធៀបទៅមុខវិជ្ជាផ្សេងទៀតដូចជា៖មុខវិជ្ជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ជាដើម ។ ក្នុងនោះដែរ តាមរយៈការបញ្ជាក់របស់គណៈគ្រប់គ្រងលើស្ថិតិប្រឡងជាប់តាមមុខវិជ្ជានៅតាមវិទ្យាល័យទាំងប្រាំមួយក្នុងខេត្តព្រៃវែងបានឱ្យដឹងថាអត្រាប្រឡងជាប់លើមុខវិជ្ជាភាសាអង់គ្លេសគឺពិតជាមានកម្រិតពិតមែន មិនមែនតែមួយឆ្នាំ ឬពីរឆ្នាំនេះទេ។ គណៈគ្រប់គ្រងបានបន្ថែមថាបើការសង្កេតរបស់គាត់ឃើញថាសិស្សរៀនគួរច្រើនលើមុខវិជ្ជាភាសាអង់គ្លេសច្រើនមុខវិជ្ជាផ្សេងៗ តែផ្ទុយទៅវិញបែរជាលទ្ធផលប្រឡងទទួលបានទាបទៅវិញ។ហេតុនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកប្រធានបទ "កត្តាជះឥទ្ធិផលដល់លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង" មកសរសេរដើម្បីកំណត់ឱ្យបាននូវកត្តាចម្បងៗ និង ដំណោះស្រាយដ៏មានប្រសិទ្ធភាពនានា សម្រាប់ទុកឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយបានសិក្សាបន្ត ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈលទ្ធផលប្រឡងកន្លងមក យើងសង្កេតឃើញថា ថ្នាក់ក្រសួង ពិសេសលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ហាក់នៅមិនទាន់ពេញចិត្តនៅឡើយទេ។ នេះជាហេតុដែលធ្វើឱ្យក្រសួងអប់រំបានដាក់ចេញនូវវិធានការជាច្រើនឈានដល់ការសម្រេចដាក់បញ្ចូលកម្មវិធីសិក្សាភាសាអង់គ្លេសចាប់ពីកម្រិតបឋមសិក្សាមកដើម្បីពង្រឹងចំណេះដឹងបន្ថែមទៀតទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្ពុជា។ទោះជាយ៉ាងណាក្តី ការប្រឡងលើមុខវិជ្ជាមួយនេះ មិនមែនមានតែសិស្សនៅប្រទេសកម្ពុជាប៉ុណ្ណោះទេដែលទទួលបានលទ្ធផលមិនសូវល្អ មានសិស្សនៅតំបន់អាស៊ានមួយចំនួនក៏ទទួលបានលទ្ធផលស្រដៀងគ្នានេះដែរ។ តាមរយៈការសិក្សាជាក់ស្តែងនៅសង្គមកម្ពុជា បើយើងក្រឡេកមើលសំទុះនៃការសិក្សារបស់លើមុខវិជ្ជាភាសាអង់គ្លេស យើងអាចកត់សម្គាល់ឃើញបានថា ភាសាអង់គ្លេសជាមុខវិជ្ជាមួយដែលមានសិស្សចូលចិត្តរៀនច្រើនជាងគេក្នុងចំណោមមុខវិជ្ជាភាសាបរទេសដទៃទៀតទាំងនៅសាលារៀនសាធារណៈ និងនៅសាលារៀនឯកជន។ ជាការពិតបើការនិយមចូលចិត្តរៀនច្រើនបែបនេះ ច្បាស់ណាស់ ថាលទ្ធផលនៃការសិក្សាក៏ពិតជាប្រសើរជាក់ជាមិនខាន។ តែផ្ទុយទៅវិញ លទ្ធផលដែលទទួលបានមកវិញនៅតែមានកម្រិតមិនគួរឱ្យជឿទាល់តែសោះ។ទាំងនេះហើយទើបធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវចង់ស្វែងរកឫសគល់ឱ្យកាន់តែស៊ីជ្រៅដើម្បីកែលម្អលទ្ធផលសិក្សាភាសាអង់គ្លេស(កត្តាជះឥទ្ធិពល និងដំណោះស្រាយ)ដែលអាចធ្វើឱ្យសិស្សចាប់យកអាជីពធ្វើការងារខ្លួនឱ្យមានការលូតលាស់ និងរីកធំធាត់បាននាពេលអនាគត។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

បន្ទាប់ពីក្រសួងធ្វើកំណែទម្រង់លើវិស័យអប់រំដោយផ្អែកលើសសរស្តម្ភទាំងប្រាំ ជាលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានផ្លាស់ប្តូរមករកគុណភាពមួយដែលមិនត្រឹមតែប្រមុខថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លោកគ្រូ-អ្នកគ្រូ និងអាណាព្យាបាលប៉ុណ្ណោះទេ ថែមទាំងគ្រប់ភាគីពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍក៏បានទទួលស្គាល់ពីលទ្ធផល និងគុណភាពរបស់សិស្សដែលបានប្រឡងជាប់

។ ទោះជាយ៉ាងណាក៏ដោយ ក៏លទ្ធផលតាមមុខវិជ្ជាប្រឡងមួយចំនួនបានល្អ និងមួយចំនួននៅមានកម្រិតនៅឡើយ។ ដោយឡែកចំពោះមុខវិជ្ជាភាសាអង់គ្លេសសង្កេតឃើញថា លទ្ធផលប្រឡងជាប់នៅតែជាបញ្ហាប្រឈមសម្រាប់សិស្សទាំងអស់នៅឡើយ។ ដោយឈរលើឆន្ទៈ និងទំនួលខុសត្រូវលើជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ទើបខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតលើគោលបំណងសំខាន់ៗពីរគឺ ៖

១. កំណត់ឱ្យបាននូវកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅខេត្តព្រៃវែង

២. ស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាពក្នុងការជំរុញឱ្យសិស្សទទួលបានលទ្ធផលល្អប្រសើរឡើងវិញក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញនូវកត្តាជះឥទ្ធិពល និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

១. តើមានកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង ?

២. ដើម្បីជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែល្អ តើត្រូវមានដំណោះស្រាយយ៉ាងដូចម្តេច ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីកំណត់បានពីកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងដំណោះស្រាយឱ្យមានប្រសិទ្ធភាពក្នុងការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែល្អ។ទើបការសិក្សាស្រាវជ្រាវមួយនេះ នឹងក្លាយជាសូចនាករដ៏សំខាន់

សម្រាប់ជួយជ្រោមជ្រែងដល់អ្នកដែលមានអាជីពជាគ្រូបង្រៀនភាសាអង់គ្លេស ដើម្បីធ្វើឱ្យគាត់មានភាពងាយស្រួលក្នុងការបង្រៀន និងជួយសម្រួលដល់ការតម្រង់ទិសសិស្សឱ្យឆាប់ចាប់បាននូវចំណេះដឹងផ្នែកភាសាអង់គ្លេសយ៉ាងពិតប្រាកដ និងមានប្រសិទ្ធភាព ដើម្បីឈានទៅរកការទទួលបានលទ្ធផលដ៏ល្អប្រសើរក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

## ១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ

គ្រូបង្រៀនភាសាអង់គ្លេសចំនួន២០នាក់ គណៈគ្រប់គ្រងសាលា ២០នាក់ និងសិស្សានុសិស្សចំនួន ៦០ នាក់ នៅវិទ្យាល័យចំនួន ៦ ក្នុងខេត្តព្រៃវែង ដែលជាខេត្តមួយស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជាដែលមានចម្ងាយប្រមាណ ៩១គីឡូម៉ែត ពីចំកណ្តាលនៃទីក្រុងភ្នំពេញប្រទេសកម្ពុជា ត្រូវបានជ្រើសរើសយកមកសិក្សាក្នុងការសិក្សាស្រាវជ្រាវ។ដោយផ្អែកលើសំណាកដែលបានកំណត់នេះ អ្នកស្រាវជ្រាវបានផលិតកម្រងសំណួរបិទ និង សំណួរបើក សម្រាប់គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និង សិស្សានុសិស្សទាំងអស់។ ក្នុងកម្រងសំណួរទាំងនោះត្រូវបានបែងចែកពីរផ្នែកសំខាន់ៗគឺ ៖ ផ្នែកទី១ ៖ ព័ត៌មានផ្ទាល់ខ្លួនរបស់ជាតុសំណាក ផ្នែកទី២ ទិន្នន័យស្រាវជ្រាវ។ មូលហេតុដែលអ្នកស្រាវជ្រាវសម្រេចយកសំណាកទាំង ៣ តួអង្គនេះព្រោះអ្នកសិក្សាស្រាវជ្រាវចង់សិក្សាស្វែងយល់ទស្សនៈយល់ឃើញរបស់ជាតុសំណាកដើម្បីឈានដល់ការកំណត់នូវកត្តាជះឥទ្ធិពលជាវិជ្ជមាន និងដំណោះស្រាយដ៏មានប្រសិទ្ធភាពដើម្បីជម្រុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមុខវិជ្ជាភាសាអង់គ្លេសបានប្រសើរឡើង

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូក៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំឭកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានសិក្សាលើនិយមន័យពាក្យគន្លឹះ សិក្សាទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ ឯកសារគតិយុត្តិនានា និងអត្ថបទស្រាវជ្រាវដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវវិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវតាមរយៈកម្រងសំណួរ និងការពិភាក្សាលើលទ្ធផល។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ធ្វើសេចក្តីសន្និដ្ឋាន ឆ្លើយតបទៅលើសំនួរស្រាវជ្រាវ ដោយបង្ហាញលទ្ធផលតាមរយៈទិន្នន័យដែលបានពីកម្រងសំនួរ និងការសង្ខេបខ្លឹមសារពិភាក្សាតាមរយៈការឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាននិងចំណុចត្រូវកែលម្អ។ លើកសំណូមពរតាមរយៈប្រធានបទសិក្សា ដល់ភាគីពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវបន្តនៅថ្ងៃអនាគត ដើម្បីពង្រីកវិសាលភាពនៃលទ្ធផលលើប្រធានបទដែលបានលើកយកមកសិក្សាស្រាវជ្រាវរួច។

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១ និយមន័យ

**កត្តាជះឥទ្ធិពល ៖** ពាក្យនេះមកពីពាក្យ (កត្តា+ជះ+ឥទ្ធិពល)ដោយយោងតាមវចនានុក្រម សម្តេចសង្ឃរាជ្យ ជួន ណាត បានឱ្យនិយមន័យថា " កត្តា " សំដៅដល់អ្នកធ្វើ , អ្នកផ្តើមធ្វើ ។ " ជះ" មានន័យថា ការបាចចោលដោយប្រដាប់មានភាជន៍ ។ "ឥទ្ធិពល" មានន័យថាកម្លាំងនៃឫទ្ធិ ។ ដូចនេះហើយកត្តាជះឥទ្ធិពល មានន័យថា៖ ជាអ្នកធ្វើឱ្យមានការប៉ះពាល់ដល់នរណាម្នាក់ ឬអ្វីមួយដោយទង្វើរបស់អ្នកនោះ ។

**លទ្ធផលប្រឡង ៖** ជាផលដែលទទួលបានពីការវាស់ស្ទង់លើកម្លាំង ឬ សមត្ថភាពដើម្បីឱ្យដឹងថានរណាខ្លាំង នរណាខ្សោយ ឬ នរណាមានសមត្ថភាព និង នរណាអសមត្ថភាព ។

**ភាសាអង់គ្លេស ៖** ដោយយោងតាមវចនានុក្រម Longman បានឱ្យនិយមន័យថា ភាសាអង់គ្លេសជាសម្តី ឬ ពាក្យដែលជនជាតិអង់គ្លេស អាមេរិចកាំង អូស្ត្រាលី ... -ល- ប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទងគ្នា។

## ២.២ ព័ត៌មានទូទៅស្តីពីខេត្តព្រៃវែង

ខេត្តព្រៃវែងជាខេត្តមួយក្នុងចំណោមខេត្តជាច្រើនដែលមានចំងាយ ៩០ គីឡូម៉ែតពីកណ្តាលនៃប្រទេសកម្ពុជា។ខេត្តព្រៃវែងមានផ្ទៃក្រឡា ៤៨៨៣ គីឡូម៉ែតការ៉េ មានស្រុកចំនួន ១២ ក្រុងចំនួន ១ ឃុំចំនួន ១១៦ និងភូមិចំនួន ១១៣៩។ដោយយោងតាមជំរឿនប្រជាជនឆ្នាំ ២០១៩ ខេត្តព្រៃវែងមានប្រជាជនសរុប ១,០៥៧,៤២៨នាក់។ប្រជាជនភាគច្រើនជាកសិករ ប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ដោយសាររាល់ឆ្នាំខេត្ត ព្រៃវែងទទួលដីភក់ពីទន្លេ ស្ទឹង និងព្រែក មួយចំនួននាំយកមក ចាក់ ក្នុងស្រែចម្ការនានា នៅក្នុងរដូវវស្សា ដូច្នោះហើយទើបធ្វើឲ្យតំបន់នេះមានដីជាតិល្អងាយស្រួល ដាំដុះ ស្រូវ និងដំណាំផ្សេងៗ។ ខេត្តនេះត្រូវបានទទួលស្គាល់ជាទូទៅថាជា "ខ្សែក្រវ៉ាត់បៃតង "ធំ" នៃ ប្រទេសកម្ពុជា។ ដំណាំ

សំខាន់ជាងគេរបស់ខេត្ត ព្រៃវែងគឺ ស្រូវ ដែលខេត្តនេះចូលរួម ចំនួន ១០ ភាគរយ នៃផលិតផលស្រូវសរុប របស់ប្រទេសសម្រាប់ការផ្គត់ផ្គង់ក្នុងខេត្ត និងនាំចេញ ។ លើសពីនោះទៀត ប្រជាកសិករក៏មានដាំណាំបន្ទាប់បន្សំ ដូចជា ថ្នាំ ជក់ សណ្តែកបាយ ស្ពៃអំពៅ ស្ពៃត្នោត ដំឡូង ឈើ (ដំឡូង មី ឬ ដំឡូង បារាំង) ល្ង និងផ្លែឈើច្រើនប្រភេទទៀតដូចជា ដូង ស្វាយ ស្វាយចន្ទីដើម្បីជួយសម្រួលដល់សេដ្ឋកិច្ចគ្រួសារផងដែរ។វិស័យអប់រំនៅខេត្តព្រៃវែងក៏មានការផ្លាស់ប្តូរទៅរកវឌ្ឍនភាពមួយគួរឱ្យកត់សម្គាល់ផងដែរ។តាមរយៈបទបង្ហាញរបស់ឯកឧត្តម ជា សុមេធី អភិបាលនៃគណៈអភិបាលខេត្ត នៅទូទាំងខេត្តព្រៃវែងមានសាលាមត្តេយ្យចំនួន៦៣៧កន្លែង បឋមសិក្សា៥៤៧




ផែនទី៖ ខេត្តព្រៃវែង

កន្លែង អនុវិទ្យាល័យ ៩២កន្លែង និង វិទ្យាល័យ ៣២កន្លែង វិទ្យាស្ថាន ២កន្លែង និងសាកលវិទ្យាល័យ ៣ កន្លែង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ១កន្លែង និងគរុកោសល្យវិក្រឹតការខេត្ត ១ កន្លែង។ បុគ្គលិកអប់រំសរុបចំនួន ៧,៣៧០ នាក់ ស្រី ២,៩៦២[1] នាក់ និងគ្រូបង្រៀនដែលកំពុងបង្រៀននៅកម្រិតមធ្យមសិក្សា(កម្រិតវិទ្យាល័យ)មានចំនួន ១៦៨៩ នាក់ ស្រី ៥៤៧ នាក់។ ក្នុងឆ្នាំសិក្សាថ្មី ២០១៩-២០២០ សិស្សថ្នាក់ទី ១២ សរុបមានចំនួន ៦,៦៧៧ នាក់ ស្រី ៣,៤៧៦ នាក់ ។

## ២.៣ ការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ

នាពេលបច្ចុប្បន្ននេះភាសាអង់គ្លេសជាមុខវិជ្ជាសិក្សាមួយដែលត្រូវបានរៀបចំឡើងសម្រាប់សិស្សចាប់ពីកម្រិតបឋមសិក្សា រហូតដល់វិទ្យាល័យ។ ការដាក់បញ្ចូលមុខវិជ្ជានេះគឺដើម្បីលើកស្ទួយកិត្យានុភាព និងគុណភាពវិស័យអប់រំនៅកម្ពុជាដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ សមាហរណកម្មអាស៊ាន និងការ

[1] ស្ថិតិ និងសូចនាករអប់រំសាធារណៈ (២០១៦-២០១៧)

ប្រែប្រួលរបស់ពិភពលោក។យោងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស(ឆ្នាំ ២០១៥) កម្មវិធីសិក្សាភាសាអង់គ្លេសត្រូវបានបែងចែកយ៉ាងច្បាស់លាស់នៅគ្រប់កម្រិតសិក្សាចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី១២។ ផងដែរដោយយោងតាមឯកសារណែនាំការអនុវត្តកម្មវិធិសិក្សាចំណេះទូទៅថ្នាក់ទី ១១ និង ទី១២ (ឆ្នាំ ២០១១) ការអនុវត្តម៉ោងបង្រៀនមានចំនួន ២ ម៉ោងក្នុងមួយសប្តាហ៍ ស្មើនឹង ៧៦ ម៉ោងក្នុងមួយឆ្នាំសិក្សា ដោយគ្របដណ្តប់លើ ១៣ ជំពូក និង ៦៩ មេរៀន។

## ២.៤ តួនាទីគ្រូបង្រៀនសតវត្សទី ២១

អ្វីៗជាច្រើនក្នុងសតវត្សរ៍ទី២១ កំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីមួយថ្ងៃទៅមួយថ្ងៃទាំងការអភិវឌ្ឍសេដ្ឋកិច្ច ការធ្វើអាជីវកម្ម កសិកម្ម បច្ចេកវិទ្យា និងការអប់រំ ។ ការអភិវឌ្ឍសមត្ថភាពគឺត្រូវការជាចាំបាច់ដើម្បីបំពេញតាមតម្រូវការ ពិសេសគ្រូបង្រៀនដែលជាវិស្វករព្រលឹងត្រូវតែខិតខំអភិវឌ្ឍសមត្ថភាពក្នុងការជំរុញលទ្ធផលសិក្សារបស់ឱ្យបានល្អជៀសវាងការបង្រៀនសិស្សដោយប្រើប្រាស់វិធីសាស្រ្តបង្រៀនហួសសម័យ " សិស្សសតវត្សទី២១ គ្រូសតវត្សទី២០ " ។ ដោយយោងតាម Hafsha Jan (2017) បានលើកឡើងថា "គ្រូបង្រៀននៅសតវត្សរ៍ទី២១ ត្រូវបង្កើតសិស្សសតវត្សរ៍ទី ២១" ដូចគ្នា។ គ្រូនៅសតវត្សទី ២១ ត្រូវការការច្នៃប្រឌិតខ្ពស់ ដូចជាការរួមបញ្ចូលការបង្រៀនជាមួយបច្ចេកវិទ្យាជាដើម ។ លោកបានបន្ថែមថាគុណភាពគ្រូជាអ្នកកំណត់កំណត់គុណភាពអប់រំនិងផ្សារភ្ជាប់ជាមួយការអភិវឌ្ឍន៍ប្រទេស។

### ២.៤.១ លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនសតវត្សទី២១

គ្រូល្អអាចជំរុញក្តីសង្ឃឹមរំញោចការស្រមើស្រម៉ៃនិងបង្កើតឱ្យមានសេចក្តីស្រឡាញ់ក្នុងការរៀនសូត្រ Hafsha Jan (2017)។គ្រូបង្រៀនសតវត្សទី ២១ ត្រូវគិតគូរពីតម្រូវការរបស់សិស្ស និង រៀបសិស្សឱ្យសមស្របទៅនឹងឧបនិស្ស័យនាពេលអនាគតរបស់ពួកគេ។ការងាររបស់គ្រូត្រូវបានចាត់ទុកថាស្មុគស្មាញនិងទាមទារការបង្កើតជំនាញវិជ្ជាជីវៈដែលមានគុណភាពខ្ពស់និងបញ្ចូលការធ្វើសមាហរណកម្មបច្ចេកវិទ្យាក្នុងការបង្រៀន។ លក្ខណៈសម្បត្តិ ១៣ យ៉ាងរបស់គ្រូបង្រៀនសតវត្សទី២១ ៖

- ប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល និងស្វែងយល់ពីសិស្ស Learner-centred classroom and Personalized Instructions
- សិស្សជាផលិតករ Students as Producers
- ការរៀបចំផែនការសិក្សា Project-Based Learning
- ការសិក្សាពីបច្ចេកវិទ្យាថ្មីៗ Learnig New technologies
- សាកលភាវូបនីយកម្ម Go Global
- ភាពវាងវៃ និងប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចឆ្លាតវៃ Be smart and Use smart phone
- បង្កើត Blog
- ឌីជីថល Go Digital
- កិច្ចសហការ គ្រូ-សិស្ស Collaborate
- ប្រើ Twitter, Telegram, Messenger chat
- មានការភ្ជាប់ទំនាក់ទំនងជាប្រចាំ Connect
- កសាងគន្លង ឌីជីថល វិជ្ជមាន Build positive Digital Footprint
- ច្នៃប្រឌិត Innovate

## ២.៥ បញ្ហាប្រឈមលើការរៀនភាសាអង់គ្លេស

លទ្ធផលសិក្សារបស់សិស្ស បានក្លាយជាក្តីបារម្ភរបស់គ្រូបង្រៀន និង អ្នកឯកទេសអប់រំក្នុងរយៈពេលប្រមាណបីបួនទសវត្សចុងក្រោយ ។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវលើសិស្សមួយចំនួនតូចនៅទីជនបទដែលបង្រៀនដោយគ្រូដដែលៗបានបង្ហាញថា៖ លទ្ធផលនៃការសិក្សារបស់សិស្សនៅជនបទមានកម្រិតទាបជាងសិស្សនៅទីប្រជុំជន។បញ្ហានេះបានទទួលការចាប់អារម្មណ៍កាន់តែច្រើនជាមួយនឹងការចាប់ផ្តើមនៃសតវត្សទីម្ភៃដំបូង។ ក៏មានការពិនិត្យកត្តាមួយចំនួនដែលជះឥទ្ធិពលដល់កម្រិតនៃការលើកទឹកចិត្តរបស់សិស្ស សាលាត្រៀមក្នុងការប្រើប្រាស់វត្ថុសិក្សាភាសាដែលជួយដល់ការសិក្សាភាសា

របស់សិស្សតាមកុំព្យូទ័រ(យោង Ramirez,1986; Genc and Aydin,2011)។សំណាកនៃការសិក្សាស្រាវជ្រាវដែលជាអ្នកសិក្សាភាសាអង់គ្លេសជាភាសាបរទេសចំនួន ១២៦ នាក់នៅសាលាត្រៀមនៃសាកលវិទ្យាល័យរដ្ឋមួយត្រូវបានគេរកឃើញថាមិនមានភាពខុសគ្នារវាងស្ថិតិប្រជាសាស្ត្រដែលបានជ្រើសរើសដូចជាអាយុរបស់សិស្ស ភេទថ្នាក់ កាតព្វកិច្ចនិងស្ថានភាពជម្រើស ប្រភេទវិទ្យាល័យ កម្រិតការអប់រំរបស់ឪពុកម្តាយ រយៈពេលនៃដំណើរការការសិក្សារបស់សិស្ស ឬក៏ជំនាញការប្រើប្រាស់កុំព្យូទ័រឡើយ។ អថេរតែមួយគត់ដែលត្រូវបានរកឃើញថាមានសារៈសំខាន់តាមស្ថិតិ គឺកម្រិតនៃការរៀនភាសាអង់គ្លេសសម្រាប់អ្នកចូលរួមក្នុងការស្រាវជ្រាវ ។ អ្នកចូលរួមច្រើនជាងពាក់កណ្តាលមានកម្រិតលើកទឹកចិត្តខ្ពស់ល្មម។ បើយោងតាមលោកJurkovic(2010) បានពិនិត្យឃើញថាផលប៉ះពាល់ពីរ លើពិន្ទុនៃលទ្ធផលមុខវិជ្ជាភាសាអង់គ្លេសដែលជាភាសាបរទេសសម្រាប់គោលបំណងជាក់លាក់ក្នុងការអប់រំឧត្តមសិក្សាគឺជំនាញភាសាដែលមានជំនាញនិងភាពញឹកញាប់នៃការប្រើប្រាស់យុទ្ធសាស្ត្ររៀនភាសា។លទ្ធផលនៃការសិក្សានេះបង្ហាញពីលទ្ធផលវិជ្ជមានគួរឱ្យកត់សំគាល់តាមស្ថិតិនៃសមត្ថភាពភាសាទូទៅលើពិន្ទុនៃការធ្វើតេស្តលទ្ធផល។ទោះយ៉ាងណាក្នុងចំណោមការកសាងយុទ្ធសាស្ត្រអ្នកសិក្សាភាសាគឺមានតែមួយគត់ដែលមានឥទ្ធិពលយ៉ាងសំខាន់លើស្ថិតិនៃការធ្វើតេស្តលទ្ធផលគឺយុទ្ធសាស្ត្រទាក់ទងនឹងការយល់ដឹង។Suh et al (2010)បានស៊ើបអង្កេតអំពីប្រសិទ្ធភាពនៃការលេងហ្គេមតាមអ៊ិនធឺណេតដែលមានអ្នកលេងច្រើន (MMORPG) ដែលមានមូលដ្ឋានលើការលេងបែបភាសាអង់គ្លេស។ លទ្ធផលបានបង្ហាញថានិស្សិតកំពុងសិក្សាភាសាអង់គ្លេសប្រើប្រាស់ល្បែងតាមអ៊ិនធឺណែតបានបង្ហាញពិន្ទុខ្ពស់ក្នុងការស្តាប់ ការអាន និងការសសេរជាងសិស្សដែលចូលរៀនវគ្គបង្រៀនទល់មុខគ្នា។ វាក៏បានបង្ហាញផងដែរថា ចំណេះដឹងមានស្រាប់ជំរុញទឹកចិត្តសម្រាប់ការសិក្សាដែលជាកត្តាជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សាភាសាអង់គ្លេស។Hungi និងThuku,(2010) បានប្រើប្រាស់នីតិវិធីវិភាគចំរុះ ដើម្បីពិនិត្យលើសិស្សនិងសាលាដែលបណ្តាលឱ្យមានបម្រែបម្រួលលើលទ្ធផលនៃការអានក្នុងចំណោមសិស្សានុសិស្សកម្រិតបឋមសិក្សាថ្នាក់ទី ៦ ដែលមកពីប្រព័ន្ធសាលារៀននៅអាហ្វ្រិកខាងត្បូងចំនួន ១៤ កន្លែង។ កត្តាសំខាន់បំផុតដែលជះឥទ្ធិពលដល់បម្រែបម្រួល នៃលទ្ធផលសិក្សារបស់សិស្សនៅលើប្រព័ន្ធសាលារៀនភាគច្រើនគឺការរៀនត្រួតថ្នាក់ កម្រិត

ជីវភាពរបស់សិស្ស ការនិយាយភាសាដែលបានបង្រៀននៅផ្ទះ និងអាយុសិស្ស ។ សមធម៌សង្គមទាបក្នុងសមិទ្ធផលនៃការអានត្រូវបានគេមើលឃើញជាក់ស្តែងនៅMaurtius, Seychelles និង Tanzania ។ លោក Small (2010) បានរាយការណ៍ថាកុមារដែលឪពុកម្តាយដែលមានការអប់រំល្អ កូនៗរបស់គាត់ធ្វើបានល្អនៅសាលារៀន និងមានឥរិយាបថវិជ្ជមានលើលទ្ធផលសិក្សា។ជាងនេះទៅទៀត គាត់បានបង្ហាញថាកត្តាសំខាន់ពីរដែលជះឥទ្ធិពលដល់ឪពុកម្តាយដែលចូលរួមយ៉ាងសកម្ម គឺពេលវេលារបស់សាលារៀន ឬអន្តរកម្មកំណត់ពេលនិងការប្រាស្រ័យទាក់ទងដោយផ្ទាល់ពីសាលារៀនដូចជាការអញ្ជើញផ្ទាល់ខ្លួនចូលរួមព្រឹត្តិការណ៍នានាជាដើម។ការសិក្សាក៏កំណត់នូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីបង្កើនការចូលរួមរបស់មាតាបិតាដែលត្រូវអនុវត្តចំពោះសាលារៀននៅទីក្រុងក៏ស្រដៀងគ្នាផងដែរ។Woo(2009) បានធ្វើការស្រាវជ្រាវលើកត្តាជាច្រើនដែលជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សារបស់សិស្សក្នុងការធ្វើតេស្តដែលមានលក្ខណៈស្តង់ដារដោយស្វែងយល់ពីភាពចម្រូងចម្រាស់ដែលទាក់ទងទៅនឹងឋានានុក្រមនៅក្នុងកម្រិតសិស្ស ថ្នាក់រៀននិងកម្រិតសាលារៀន។ បន្ថែមពីនេះទៅទៀតដោយផ្អែកលើការសិក្សាស្រាវជ្រាវរបស់ Mosha (2014) បានលើកឡើងពីចំនុចសំខាន់ បីគឺ៖

### ២.៥.១ ការរៀន និងបង្រៀនភាសាអង់គ្លេសក្នុងថ្នាក់

ដំណើរការរៀន និងបង្រៀនភាសាអង់គ្លេសមានការចូលរួមពីជាតុសំខាន់ពីរគឺ គ្រូបង្រៀន និងសិស្ស។ ហើយអ្នកសិក្សាក៏មិនត្រូវផ្តេកផ្តួលលើគ្រូតែម្នាក់ដែរ។សិស្សក៏ត្រូវទទួលខុសត្រូវបន្ថែមទៀតចំពោះដំណើរការសិក្សារបស់ខ្លួន(យោង Quist, 2000)។ ជាឧទាហរណ៍ Vuzo,(2010) បានរកឃើញថា "វាគឺជាការធ្វើអន្តរកម្មរវាង គ្រូនិងសិស្ស ដើម្បីធ្វើការជាមួយគ្នា និងបង្កើតសកម្មភាព និងភាពជាក់ស្តែងដែលទាក់ទងនឹងប្រធានបទដែលបានដៅទុក។ទោះជាយ៉ាងណាក៏ដោយស្ថានភាពបែបនេះមិនត្រូវបានរកឃើញជាទូទៅទេនៅតាមអនុវិទ្យាល័យលើមុខវិជ្ជាទាំងអស់ ដោយសារវិធីសាស្ត្របង្រៀនគ្របដណ្តប់លើដំណើរការបង្រៀននិងរៀនដែលនាំទៅរកផលអវិជ្ជមាន។ Cummings,(2002) ដូចដែលបានដកស្រង់នៅ Wang,(1994) បាននិយាយថា "នៅពេលខ្ញុំលឺ ខ្ញុំភ្លេច នៅពេលខ្ញុំឃើញខ្ញុំចងចាំ ហើយនៅពេលខ្ញុំធ្វើ ខ្ញុំរៀន" ទំព័រ ១១១ ។ Cummings,(2002) បានកត់សម្គាល់ថាការសិក្សាដែលសិស្សបង្កើតឱ្យមាន

អន្តរកម្ម ធ្វើឱ្យមានការចូលរួមកាន់តែមានប្រសិទ្ធភាពនៅក្នុងថ្នាក់។មានន័យថាប្រសិទ្ធភាពនៃការរៀនភាសានិងការបង្រៀននៅក្នុងថ្នាក់រៀននឹងអាស្រ័យលើគ្រូបង្រៀន។ គំនិតនេះស្របគ្នានឹង លទ្ធផលសិក្សាស្រាវជ្រាវរបស់Quist,(២០០០)បានបង្ហាញថា នៅក្នុងការបង្រៀនប្រកបដោយគុណភាព និងគុណភាពនៃការរៀនសូត្ររបស់សិស្សគឺទាក់ទងយ៉ាងជិតស្និតទៅនឹងចំណេះដឹងនិងការយល់ដឹងរបស់គ្រូលើមុខវិជ្ជាឯកទេស។លើសពីនេះទៀតគ្រូភាសាអង់គ្លេសគឺជាអ្នកដើរតួរសំខាន់បំផុតក្នុងវគ្គសិក្សានីមួយៗ។មានការរំលឹកទ្រឹស្តីមួយទៀតបង្ហាញយ៉ាងច្បាស់ថា គ្រូបង្រៀនគឺជាអ្នកដែលកំណត់សកម្មភាពរៀនរបស់សិស្ស Allen & Valette, (1997) Quist, (2000)។ដោយសារការបង្រៀនគឺការប្រាស្រ័យទាក់ទង គ្រូភាសាអង់គ្លេសត្រូវតែមានសមត្ថភាពទំនាក់ទំនងអតិបរមា។ ផងដែរនោះ គ្រូម្នាក់ក៏ត្រូវចេះភាសាខ្លួនឯងដើម្បីឱ្យគាត់អាចធ្វើការសម្រេចចិត្តដែលមានប្រយោជន៍ទាក់ទងនឹងអ្វីដែលគួរត្រូវបានបង្រៀនដល់អ្នកណានិងរបៀបដែលការបង្រៀន គួរតែត្រូវបានអនុវត្តយ៉ាងណា។ យោងតាម Harmer,(2003); Moha,(2004) ការស្រាវជ្រាវបង្ហាញយ៉ាងច្បាស់ថាក្នុងចំណោមកត្តាដែលនាំឱ្យទទួលលទ្ធផលមិនល្អរបស់សិស្សគឺជាគុណសម្បត្តិរបស់គ្រូ)។ជាងនេះទៅទៀតការសិក្សាជាក់ស្តែងបានបង្ហាញថាប្រសិនបើនៅដើមឆ្នាំ សាលាមិនបានផ្តល់មូលដ្ឋានគ្រឹះត្រឹមត្រូវសម្រាប់ការរៀនសូត្រទេ នោះសិស្សក៏មិនអាចទទួលបាន នូវសក្តានុពលពេញលេញទាក់ទងនឹងរបៀបដែលការរៀនសូត្ររបស់គាត់នឹងដំណើរការទៅមុខនោះទេ។ហើយឥរិយាបថរបស់គាត់មានអត្ថប្រយោជន៍យ៉ាងដូចម្តេចចំពោះជីវិតនិងការរៀនសូត្រនាពេលអនាគតរបស់គាត់ Quist,(2000)។សម្ភារៈបង្រៀន គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការរៀន និងបង្រៀនលើគ្រប់មុខវិជ្ជា។វាបានធ្វើឱ្យការរៀនសូត្រកាន់តែរីករាយដល់សិស្សពីព្រោះពួកគេផ្តល់នូវបទពិសោធន៍ជាក់ស្តែងដែលជំរុញសកម្មភាពខ្លួនឯងនិងការស្រមើលស្រមៃរបស់សិស្ស។ ពួកគេក៏ផ្តល់ជាមូលដ្ឋានជាក់ស្តែងសម្រាប់ការគិត និងកាត់បន្ថយការឆ្លើយតបដោយពាក្យគ្មានន័យពីសិស្ស Nyamubi,(2003) ។ ជាឧទាហរណ៍Kapoli,(2001)បានកត់សម្គាល់ថាឯកសារដែលមានសមត្ថភាពអាចឱ្យសិស្សអាចស្វែងយល់ភាសាដែលត្រូវបានប្រើក្នុងជីវិតប្រចាំថ្ងៃហើយដែលត្រូវនឹងតម្រូវការនិងផលប្រយោជន៍របស់ពួកគេ។ អង្គការUNISCO(២០០០)បានរាយការណ៍ថាការផ្តល់សម្ភារៈបង្រៀននិងរៀនជាពិសេសសៀវភៅគឺជា

មធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកែលម្អលទ្ធផលសិក្សា។ ទោះយ៉ាងណាដោយយោងតាមរបាយការណ៍អប់រំពិភពលោកWER( World Educational Report:១៩៩៨)បានបង្ហាញថានៅក្នុងប្រទេសជាច្រើនស្ថានភាពគឺមានភាពលំបាកទាំងសម្ភារៈរូបវន្ត សម្ភារៈបង្រៀន ការរៀន ទំហំថ្នាក់រៀន និងផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ។

### ២.៥.២ ឥរិយាបថ ចំពោះការសិក្សាភាសារបស់សិស្ស

ឥរិយាបថសំដៅទៅលើសំណុំនៃជំនឿដែលអ្នកសិក្សាមានចំពោះសមាជិកក្រុមគោលដៅនិងឆ្ពោះទៅរកវប្បធម៌ផ្ទាល់ខ្លួនរបស់គាត់( យោងBrown,2000)។ទស្សនៈចំពោះការសិក្សាភាសាគឺជាគំនិតសំខាន់មួយពីព្រោះវាដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀនសូត្រភាសា។ឧទាហរណ៍អ្នកស្រាវជ្រាវដែលដឹកនាំដោយលោកGardner,( 2001&2002)អំពីឥរិយាបថនិងការលើកទឹកចិត្តបានបង្ហាញពីការទាក់ទងគ្នាជាមួយនឹងការអនុវត្តភាសារបស់អ្នកសិក្សាដោយសង្កត់ធ្ងន់លើតួនាទីនៃឥរិយាបថ និងការលើកទឹកចិត្តដែលជាកត្តាកំណត់ក្នុងការសិក្សាភាសាបរទេស។ ជាទូទៅវាត្រូវបានគេរកឃើញថាឥរិយាបថវិជ្ជមានជួយសម្រួលដល់ដំណើរការនៃការរៀនសូត្រទោះបីជាឥរិយាបថមិនកំណត់អាកប្បកិរិយាក៏ដោយ Khanna & Agnihotri,( 1994)។ ក្នុងការអប់រំឥរិយាបថត្រូវបានគេចាត់ទុកថាជាធាតុចូល និងលទ្ធផល។ ឥរិយាបថមានទំនាក់ទំនងវិជ្ជមានជាមួយនឹងភាពជោគជ័យក្នុងការរៀនសូត្រភាសាអង់គ្លេសជាភាសាទីពីរព្រោះវាជួយសម្រួលដល់ការលើកទឹកចិត្តរបស់អ្នកសិក្សាក្នុងការរៀនភាសា Gardner & Trembly,( 1994 )។ពួកគេបានបន្ថែមទៀតថាឥរិយាបថបុគ្គលចំពោះភាសាដែលពួកគេរៀនបំពេញតាមតម្រូវការសំខាន់ៗនៅពេលពួកគេបំពេញមុខងារជាក់លាក់ដូចជាការទទួលបានពិន្ទុខ្ពស់ក្នុងការប្រឡងភាសាជាដើម ។

### ២.៥.៣ ការលើកទឹកចិត្ត និង ការសិក្សាភាសា

ការលើកទឹកចិត្តគឺជាគំនិតដែលត្រូវបានប្រើច្រើនបំផុតសម្រាប់ការបកស្រាយពីភាពបរាជ័យឬភាពជោគជ័យរបស់អ្នកសិក្សា។ការលើកទឹកចិត្តក៏ត្រូវបានគេចាត់ទុកថាជាកត្តាសំខាន់មួយដែលជះឥទ្ធិពលដល់ល្បឿននិងចំនួនជោគជ័យនៃអ្នកសិក្សាភាសាបរទេសGardner,( 2006)។ជាឧទាហរណ៍ Gardner,

(2006),ទំព័រ២៤១បានរកឃើញថានិស្សិតដែលមានកម្រិតលើកទឹកចិត្តខ្ពស់នឹងធ្វើបានល្អជាងសិស្ស ដែលមានកម្រិតទាប។គាត់បានបន្ថែមទៀតថាប្រសិនបើមនុស្សម្នាក់ត្រូវបានលើកទឹកចិត្តគេនឹងមានហេតុផលសម្រាប់ចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធទំព័រ២៤៣។នៅក្នុងការអភិវឌ្ឍមួយផ្សេងទៀតElliot, Kratochil and Cook,(2000) មើលឃើញការលើកទឹកចិត្តសភាពផ្ទៃក្នុងមួយដែលធ្វើឱ្យមានសកម្មភាពរុញច្រានយើងក្នុងទិសដៅជាក់លាក់ ហើយធ្វើឱ្យយើងចូលរួមក្នុងសកម្មភាពដ៏ពិតប្រាកដ។ពួកគេបានបន្ថែមទៀតថាការរៀនសូត្រនិងការលើកទឹកចិត្តគឺចាំបាច់ដូចគ្នាសម្រាប់ការអនុវត្តហើយពួកគេអាចឱ្យយើងទទួលបានចំណេះដឹងនិងជំនាញថ្មីៗ។លើសពីនេះទៀតការលើកទឹកចិត្តផ្តល់នូវកម្លាំងរុញច្រានសម្រាប់ការបង្ហាញនូវអ្វីដែលយើងបានរៀន ហើយមនុស្សដែលមានកម្លាំងចិត្តកាន់តែច្រើន ទទួលបានកម្រិតខ្ពស់។ ប៉ុន្តែដោយយោងតាម Harmer,(2004)បានព្រមានថាការលើកទឹកចិត្តដែលនាំសិស្សឱ្យអនុវត្តន៍ការសិក្សា ភាសាអង់គ្លេសនេះក៏អាចជះឥទ្ធិពលពីឥរិយាបថរបស់មនុស្សមួយចំនួនផងដែរ។ នៅក្នុងការបង្រៀនការលើកទឹកចិត្តគឺជាកត្តាមួយដែលជះឥទ្ធិពលដល់ភាពជោគជ័យឬបរាជ័យក្នុងការរៀនសូត្រភាសាជាពិសេសភាសាទីពីរឬភាសាបរទេសGardner,(2006)។ជាមួយគ្នានេះPetty,(1998)បានអះអាងថាប្រសិនបើសិស្សមិនចង់រៀនទេ ប្រសិទ្ធភាពនៃការរៀនសូត្ររបស់ពួកគេនឹងមានភាពយឺតយ៉ាវ ហើយក៏មិនទទួលបានអ្វីសោះឡើយ។ហើយប្រសិនបើអ្នកដឹងពីរបៀបជំរុញទឹកចិត្តសិស្សអ្នកអាចបង្កើនការរៀនសូត្ររបស់ពួកគេ។ក្រៅពីការលើកទឹកចិត្តនិងអាកប្បកិរិយាអ្នកសិក្សាស្រាវជ្រាវបង្ហាញថា បរិយាកាសសិក្សានៅផ្ទះបានរួមចំណែកធ្វើឱ្យសិស្សបំពេញការងារសិក្សានិងចូលរួមសកម្មភាពនៅតាមសាលារៀនមិនសូវបានល្អSulciman,(1999)&Mapuri,(1999)។តាមរយៈលទ្ធផលការសិក្សាស្រាវជ្រាវរបស់Thongma Souriyavongsa,(2013) នៅសាកលវិទ្យាល័យជាតិនៃប្រទេសឡាវ បោះពុម្ពនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ បានកំណត់បញ្ហាសំខាន់ៗ មួយចំនួនទាក់ទងនឹងកត្តាជះឥទ្ធិពលលើការសិក្សាភាសាអង់គ្លេសជាភាសាបរទេស និងភាសាទី២ សម្រាប់សិស្សដែលមានភាសាកំណើតមិនមែនភាសាអង់គ្លេសដូចជាប្រទេសឡាវនេះឯង។ កត្តាទាំងនោះអាចទាញចេញពីសមាសធាតុជាច្រើនរួមមានបញ្ហាបរិស្ថានសង្គម ភាពខុសគ្នានៃវប្បធម៌ ការពង្រីកសេដ្ឋកិច្ចសង្គម - ល-។ បញ្ហាទាំងនេះបណ្តាលឱ្យ

សិស្សមានលទ្ធផលមិនល្អនៅក្នុងការសិក្សាភាសា។ ជាពិសេសនៅក្នុងបណ្តាប្រទេសដែលបាតតារាងមួយចំនួនដូចជា ឡាវ មីយ៉ាន់ម៉ា កម្ពុជា និងវៀតណាមជាដើម។

## ២.៦ មូលហេតុនៃភាពកម្សោយក្នុងការរៀនភាសាអង់គ្លេស

ការសិក្សាភាសាអង់គ្លេសនៅតែជាការលំបាកសម្រាប់សិស្សានុសិស្ស ដោយកត្តារួមផ្សំជាច្រើនទៅតាមស្ថានភាពនៃប្រទេសនីមួយៗ។យោងតាមលទ្ធផលសិក្សាស្រាវជ្រាវរបស់Khattak,(2011)បានបង្ហាញថាសាវតាសេដ្ឋកិច្ចខ្សត់ខ្សោយក៏ជាកត្តាមួយដែលបង្កើតឱ្យអ្នកសិក្សាប្រឈមនឹងការប្រើប្រាស់ភាសាបរទេស។ ការសិក្សាមួយដែលត្រូវបានធ្វើឡើងដោយ Muhammad, (2007)បានបង្ហាញថាៈកត្តាដែលបណ្តាលឱ្យមានការព្រួយបារម្ភក្នុងការរៀនភាសាសម្រាប់អ្នកសិក្សា ESL/EFL នៅក្នុងជំនាញនិយាយនិងការជះឥទ្ធិពលលើការប្រាស្រ័យទាក់ទងគ្នាបានរកឃើញថាមានការលំបាកក្នុងការរៀនសូត្រភាសានិង ប្រភពផ្សេងគ្នានៃវប្បធម៌របស់អ្នកសិក្សា។ភាពខុសគ្នានៅក្នុងស្ថានភាពសង្គមរបស់អ្នកនិយាយគឺជាកត្តាដែលជះឥទ្ធិពលដល់ភាពទន់ខ្សោយនៃការសិក្សាភាសា។ លើសពីនេះទៀតការសិក្សាអំពីបញ្ហាដែលបានជួបប្រទះដោយអ្នកសិក្សា Arab EFL បានបង្ហាញថាអ្នកសិក្សាចូលចិត្តប្រើភាសាអារ៉ាប់ជាជាងភាសាអង់គ្លេសសម្រាប់ការទំនាក់ទំនងទាំងខាងក្រៅនិងខាងក្នុងថ្នាក់រៀន កង្វះខាតនៃការនិយាយភាសាដោយអ្នកនិយាយជនជាតិដើម កង្វះការបែងចែកលើភាពកម្សោយក្នុងបរិបទបង្រៀនភាសា និងកង្វះការលើកទឹកចិត្តផ្ទាល់ខ្លួនLoae,(2011)។ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Normazidah, Koo, and Hazita,(2012) & Trawiński ,(2005)ក៏បានបង្ហាញពីកត្តាដែលជះឥទ្ធិពលដល់អ្នកសិក្សា EFL ឱ្យមានការអនុវត្តមិនល្អនៅក្នុងការសិក្សាភាសាអង់គ្លេសដូចខាងក្រោមៈ

- ភាសាអង់គ្លេសត្រូវបានគេចាត់ទុកថាជាប្រធានបទពិបាករៀន
- ការរៀនសូត្ររបស់អ្នកសិក្សាអាស្រ័យលើគ្រូភាសាអង់គ្លេសក្នុងនាមជាអាជ្ញាធរ
- ខ្វះការគាំទ្រក្នុងការប្រើប្រាស់ភាសាអង់គ្លេសនៅផ្ទះនិងសហគមន៍
- អ្នកសិក្សាមិនបានប្រើប្រាស់ភាសា និងឱកាសគ្រប់គ្រាន់នៅខាងក្រៅថ្នាក់រៀន

- សមត្ថភាពរបស់សិស្សមានកម្រិតលើវាក្យស័ព្ទ និងខ្វះខាតសម្ភារៈសម្រាប់អាន
- សិស្សមិនសូវមានឆន្ទៈ និងកង្វះការលើកទឹកចិត្តក្នុងការរៀនសូត្រភាសាអង់គ្លេសព្រោះពួកគេមិនបានមើលឃើញពីតម្រូវការប្រើប្រាស់ភាសាភ្លាមៗនោះទេ។
- កង្វះនៃការលើកទឹកចិត្ត និងមានអាកប្បកិរិយាអវិជ្ជមានចំពោះភាសា

តាមរយៈការសិក្សាស្រាវជ្រាវរបស់លោក Chang,(2010) បានចង្អុលបង្ហាញថាមូលហេតុដែលបណ្ដាលឱ្យមានភាពទន់ខ្សោយរបស់សិស្សសម្រាប់ការសិក្សាភាសាអង់គ្លេសបានមកពីភាពខ្ជិលច្រអូសរបស់អ្នកសិក្សា។ កង្វះប្រសិទ្ធភាពសាលារៀន និងការផ្សព្វផ្សាយរបស់ឪពុកម្ដាយមិនគ្រប់គ្រាន់។ លើសពីនេះទៅទៀតយោងតាមលោកDembo,(2004)បញ្ជាក់ថាការគ្រប់គ្រងពេលវេលាគឺជាប់ទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍សិស្សដែលមានជំនាញគ្រប់គ្រងពេលវេលាល្អទទួល បានមធ្យមភាគពិន្ទុខ្ពស់ជាងសិស្សដែលមិនមានជំនាញគ្រប់គ្រងពេលវេលា។ Alderman ,(2004) ចែងអំពីលទ្ធផលនៃការរៀនភាសាមិនល្អរបស់សិស្សទទួលរងផលប៉ះពាល់ពីការខ្វះខាតការខិតខំប្រឹងប្រែង ខ្វះយុទ្ធសាស្ត្ររៀនសូត្រប្រកបដោយប្រសិទ្ធភាព ចំណែកឯអ្នករៀនភាសាបានល្អ គឺជាសិស្សដែលមានកម្លាំងចិត្តខ្ពស់ និងជាអ្នកប្រើយុទ្ធសាស្ត្រច្រើន Trawiński ,(2005) ។

### ២.៦.១ ការលើកទឹកចិត្តសម្រាប់ការរៀនភាសាអង់គ្លេស

យោងតាមលទ្ធផលសិក្សាស្រាវជ្រាវរបស់Lei,(2012)&Thang,(2011)បានបង្ហាញថា៖ជាទូទៅការលើកទឹកចិត្តត្រូវបានទទួលស្គាល់ថាជាកត្តាសំខាន់បំផុតមួយដែលជះឥទ្ធិពលដល់ការសិក្សាភាសាទី២។នៅពេលបច្ចុប្បន្នចំនួនសិស្សនៃប្រទេសឡាវជាច្រើនបានបរាជ័យក្នុងការរៀនភាសាអង់គ្លេសដោយសារតែកង្វះការលើកទឹកចិត្តពីជាតុមួយចំនួនដូចជា ៖ សារតាគ្រួសារ បរិយាកាសសង្គម បរិយាកាសរូបវ័ន្ត វប្បធម៌ និង វិធីសាស្ត្រក្នុងការសិក្សាជាដើម នេះបើយោងតាមលោកDembo,(2004) ។ យោងតាម Zhou,(2012) បានបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវថា៖ការលើកទឹកចិត្តអាចមានឥទ្ធិពលលើសេរីភាពរបស់សិស្ស ការយកចិត្តទុកដាក់ ការប្រឹងប្រែង ការអត់ធ្មត់ ទម្លាប់នៃការប្រើប្រាស់ភាសា និងភាព

ជោគជ័យលើការសិក្សារបស់គេ។ អស់រយៈពេលជាយូរមកហើយការលើកទឹកចិត្តជាទូទៅត្រូវបានចូលរួមដោយគ្រូភាសាអង់គ្លេស និងអ្នកស្រាវជ្រាវដែលបានព្យាយាមទ្រទ្រង់ការលើកទឹកចិត្តរបស់សិស្សក្នុងការរៀនសូត្រភាសាអង់គ្លេសដោយដឹងពីប្រភេទនៃកត្តាជំរុញការរៀនភាសាអង់គ្លេសរបស់ពួកគេនិងកត្តាដែលជះឥទ្ធិពលដល់ការលើកទឹកចិត្តរបស់ពួកគេនៅក្នុងដំណើរការដ៏វែងនៃការរៀនសូត្រភាសាអង់គ្លេស (យោង Lei, 2012)។ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Sakiroglu & Dikilitas,(2012)បានបង្ហាញថា៖ប្រសិនបើសិស្សមានការលើកទឹកចិត្តខ្ពស់ពួកគេនឹងរីករាយក្នុងការរៀនត្រូវការរៀនភាសា និងព្យាយាមរៀនភាសា។លើសពីនេះទៅទៀតការលើកទឹកចិត្តជាធម្មតាត្រូវបានគេចាត់ទុកថាជាគន្លឹះដ៏សំខាន់ក្នុងការសិក្សាភាសាបរទេស ពិសេសភាសាអង់គ្លេស (យោង Klimova, 2011) ។

## ២.៧ យុទ្ធសាស្ត្ររៀនភាសាអង់គ្លេស

យុទ្ធសាស្ត្ររៀនគឺជាវិធីសាស្ត្រដែលអ្នកសិក្សាប្រើដើម្បីទទួលបានព័ត៌មាន៖ ជាធម្មតាអ្នកសិក្សាដែលទទួលបានជោគជ័យខ្ពស់ប្រើយុទ្ធសាស្ត្រច្រើនជាងការរៀនដែលទទួលបានលទ្ធផលទាប Dembo,(2004)។មានសិស្សដែលមិនបានទទួលជោគជ័យមួយចំនួនក្នុងការសិក្សារបស់ពួកគេព្រោះពួកគេច្រើនតែខកខានការអនុវត្តយុទ្ធសាស្ត្ររៀនសូត្រឱ្យបានសមស្របទៅនឹងកិច្ចការដែលមាននៅក្នុងដៃ។ តាមទស្សនៈអ្នកស្រាវជ្រាវជឿជាក់ថាយុទ្ធសាស្ត្រនៃការរៀនគឺមានសារៈសំខាន់នៅក្នុងការជំរុញភាសាទី២(SLA = Second Language Aquisition)ព្រោះវាផ្តល់ឱ្យអ្នកសិក្សានូវគន្លឹះដើម្បីសម្រេចបាននូវគោលដៅ។ ពួកគេក៏អាចជួយសម្រួលដល់ទិដ្ឋភាពជាក់លាក់នៃសមត្ថភាពរបស់អ្នកសិក្សាដូចជាការប្រាស្រ័យទាក់ទង និងអារម្មណ៍របស់បុគ្គលដែលទាក់ទងទៅនឹងដំណើរការនៃការរៀនសូត្រ(យោងTrawiński,2005)។ ដោយយោងតាម Margaret,(2005)វាពិតជាមានតម្លៃណាស់ក្នុងការបង្កើត និងសម្របសម្រួលដល់យុទ្ធសាស្ត្ររៀនដើម្បីបំពេញកម្រិតភាសាអង់គ្លេសរបស់អ្នកសិក្សាហើយបន្ទាប់មកលើកទឹកចិត្តឱ្យមានការចូលរួមប្រកបដោយជោគជ័យ។យោងតាមការសិក្សារបស់Ting,(2009)សិស្សអាចយកឈ្នះភាពទន់ខ្សោយរបស់ពួកគេតាមរយៈការបណ្តុះបណ្តាលយុទ្ធសាស្ត្រសមស្រប ហើយយុទ្ធសាស្ត្ររៀនអាចជះឥទ្ធិ

ពលដល់លទ្ធផលនៃការសិក្សារបស់សិស្ស។ជាងនេះទៅទៀត ការរៀនកត្តាយុទ្ធសាស្ត្រក៏ជួយជំរុញឱ្យសិស្សក្លាយជាសិស្សពូកែផងដែរ។ ដោយយោងតាមការសិក្សារបស់ Oxford : 2001 បានចាត់ថ្នាក់លក្ខណៈអ្នករៀនពូកែ គឺជាអ្នកដែលមាន៖

- ជាអ្នកមានភាពក្លៀវក្លានិងទស្សនៈទានត្រឹមត្រូវ
- មានកម្លាំងចិត្តក្នុងការទំនាក់ទំនង
- គ្មានការគំរាមកំហែង និងត្រៀមខ្លួនធ្វើខុស
- ផ្តោតលើទម្រង់បែបបទដោយមើលគំរូនិងការប្រើប្រាស់ការវិភាគ
- ធ្វើឱ្យប្រសើរឡើងនូវឱកាសអនុវត្តន៍ទាំងអស់
- តាមដានសម្តីខ្លួនឯង និងអ្នកដទៃ
- យកចិត្តទុកដាក់លើអត្ថន័យ

ទោះជាយ៉ាងណាក៏ដោយ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនពិពណ៌នាអំពីភាពខុសគ្នានៃនិយមន័យនៃយុទ្ធសាស្ត្រនៃការសិក្សាដូចតទៅ៖ ដោយយោងតាម Richard & Lockhart,(2007)បង្ហាញថា៖ យុទ្ធសាស្ត្ររៀនគឺជាដំណើរការជាក់លាក់ដែលនិស្សិតប្រើជាមួយភារកិច្ចសិក្សាផ្ទាល់ខ្លួនដូចជាការអានជំពូកនៃសៀវភៅ ឬការរៀបចំការសង្ខេបនៃអត្ថបទមួយក៏ដូចជាសិស្សអាចជ្រើសរើសវិធីផ្សេងៗគ្នាជាច្រើនក្នុងការបំពេញភារកិច្ចអ្នកសិក្សាអាចធ្វើឱ្យការរៀនសូត្រកាន់តែងាយស្រួល លឿន រីករាយជាងមុន និងមានប្រសិទ្ធភាពជាងមុន និងអាចផ្ទេរបានច្រើនទៅស្ថានការណ៍ថ្មីៗ។ តាមរយៈការសិក្សាស្រាវជ្រាវរបស់លោកGrainger,(2005)& Oxford,(2002) បានគូសបញ្ជាក់ថា យុទ្ធសាស្ត្ររៀនភាសាគឺជាបច្ចេកទេសសម្រាប់ការប្រើប្រាស់របស់សិស្ស ដើម្បីជួយដល់ដំណើរការរៀនភាសាអង់គ្លេសរបស់សិស្ស។ ដោយយោងតាមAbbasi, Ahmad, & Khattak,(2010) បានកំណត់ច្បាស់ថាយុទ្ធសាស្ត្ររៀនភាសាគឺជាលក្ខណៈឬគំនិតជាក់លាក់ដែលសិស្សប្រើដើម្បីបង្កើនការរៀនភាសារបស់ពួកគេ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេសនៅខេត្តព្រៃវែង" មានគោលបំណងសិក្សាស្វែងយល់ពីកត្តាជះឥទ្ធិពល ដែលធ្វើឱ្យសិស្សប្រឡងធ្លាក់ច្រើនលើមុខវិជ្ជាភាសាអង់គ្លេស ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង និង ដំណោះស្រាយដែលមានប្រសិទ្ធភាពក្នុងការជំរុញឱ្យសិស្សទទួលបានលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេសបានល្អប្រសើរឡើងវិញ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១ គម្រោងវិភាគ ( Analysis Plan )

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ ៣ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សុីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅមធ្យមសិក្សាទុតិយភូមិ ចំនួន ៦វិទ្យាល័យ ក្នុងខេត្តព្រៃវែង និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន ៣ប្រភេទ គឺ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

## ៣.២ ការប្រមូលទិន្នន័យ ( Data collection )

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ-១៩ គ្រូបង្រៀនតាមសាលារដ្ឋ បានចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សឲ្យរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វជអ.ផក ចុះថ្ងៃពុធ ១០រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវ

នឹងថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ ( ONLINE Google Form ) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្រុបខ័ណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាតជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរ ដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស ដោយមានកំណត់ពេលវេលាជាក់លាក់។ការចុះប្រមូលទិន្នន័យគឺមានភាពបត់បែនទៅតាមទីតាំងភូមិសាស្ត្ររបស់សាលារៀន និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានា៖ Google form, តេលេក្រាម, ទូរស័ព្ទ និង Facebook ជាដើម។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរ មានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតប ទៅតាមពេលកំណត់ជាក់លាក់។ ក្នុងអន្តរកាល នៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេស បណ្តាញទំនាក់ទំនងសង្គម និងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូល ទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន ២៧ថ្ងៃ គិតចាប់ពីចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំនួរទាំងអស់ពី គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានៈ កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តព្រៃវែង អ្នកសិក្សាស្រាវជ្រាវ ប្រើប្រាស់កម្រងសំណួរចំនួន៣ប្រភេទ

ក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានា ដែលមានដូចជា៖ ការអនុវត្តកម្មវិធីសិក្សា ស្តង់ដារនាយកសាលារៀន សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ កម្មវិធីសិក្សាពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំ ជាដើម ដើម្បីសិក្សាពីកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងដំណោះស្រាយនានា ក្នុងការប្រឡងសញ្ញាបត្រមធ្យសិក្សាទុតិយភូមិ នៅខេត្តព្រៃវែង។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំនួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត-ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

## ៣.៣.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីកត្តាដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តព្រៃវែង និងដំណោះស្រាយ លើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យលទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេសកាន់តែល្អប្រសើរ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ ការងារមុខវិជ្ជាភាសាអង់គ្លេស។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។

### ៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាទុតិយភូមិ

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង ដែលចែកចេញជា ៣ផ្នែកគឺ

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៨សំណួរ ទាក់ទងទៅនឹងតួនាទី កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស បទពិសោធន៍ការងារ និងភាសាបរទេស។

**ផ្នែកទី២៖ ឥរិយាបថថ្នាក់ដឹកនាំ-គ្រប់គ្រងសាលារៀន ដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេស**

មានសមាសភាគចំនួន ៦ គឺការរៀបចំផែនការ (៩សំណួរ) កសាងសមត្ថភាពគ្រូ (៩សំណួរ) កសាងសមត្ថភាពសិស្ស (៦សំណួរ) ភាគីពាក់ព័ន្ធ (៤សំណួរ) ធនធានរូបវន្ត (៥សំណួរ) និង ការធានាគុណភាព (៧សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃឥរិយាបថរបស់ថ្នាក់ដឹកនាំនិងគ្រប់គ្រងសាលារៀន ដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែម ពីការឆ្លើយតបរបស់គណៈគ្រប់គ្រង នៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៣៖ ដំណោះស្រាយ លើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស**

មានសមាសភាគចំនួន៣ គឺកត្តាគណៈគ្រប់គ្រង (១០សំណួរ) កត្តាគ្រូ (៨សំណួរ) កត្តាសិស្ស (៨សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងពីដំណោះស្រាយ ដើម្បីជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែល្អប្រសើរ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គណៈគ្រប់គ្រងនៅផ្នែកទី៣ ស្តីពី "តើគួរមាន ដំណោះស្រាយអ្វីខ្លះទៀត ដើម្បីអោយការសិក្សាមុខវិជ្ជាភាសាអង់គ្លេសទទួលបានលទ្ធផលកាន់តែល្អប្រសើរ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរគ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិ ដែលកំពុងបង្រៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៧សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅមធ្យមសិក្សាទុតិយភូមិ កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស និងបង្រៀនថ្នាក់ទីប៉ុន្មាន។

**ផ្នែកទី២៖ ឥរិយាបថគ្រូ ដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេស**

មានសមាសភាគចំនួន៤ គឺការអនុវត្តកម្មវិធីសិក្សា (៧សំណួរ) ដំណើរការបង្រៀន (៨សំណួរ) ទំនាក់ទំនងគ្រូ-សិស្ស (៨សំណួរ) និងការប្រើប្រាស់សម្ភារឧបទ្ទេស (៥សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី២ ស្តីពី "តើលោកគ្រូ អ្នកគ្រូភាសាអង់គ្លេស បានជួបប្រទះការលំបាកអ្វីខ្លះក្នុងការបង្រៀនភាសាអង់គ្លេស?" និង "តើលោកគ្រូ អ្នកគ្រូ ដោះស្រាយបញ្ហាទាំងនោះ យ៉ាងដូចម្តេចខ្លះ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ ។

**ផ្នែកទី៣៖ ដំណោះស្រាយ លើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស**

មានសមាសភាគចំនួន៣ គឺកត្តាគណៈគ្រប់គ្រង (១០សំណួរ) កត្តាគ្រូ (៨សំណួរ) កត្តាសិស្ស (៨សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងពីដំណោះស្រាយ ដើម្បីជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែល្អប្រសើរ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី៣ ស្តីពី "តើគួរមាន ដំណោះស្រាយអ្វីខ្លះទៀត ដើម្បីអោយការសិក្សាមុខវិជ្ជាភាសាអង់គ្លេសទទួលបានលទ្ធផលកាន់តែល្អប្រសើរ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.៣ កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ អំពីកម្រិតពេញចិត្តបំពេញ រៀនមុខវិជ្ជាភាសាអង់គ្លេសនៅវិទ្យាល័យរដ្ឋក្នុងខេត្តព្រៃវែង ដែលចែក

ចេញជា ២ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៥សំណួរ ទាក់ទងទៅនឹងបានសិក្សាមុខវិជ្ជាភាសាអង់គ្លេសក្នុងវិទ្យាល័យ ភេទ អាយុ រៀនថ្នាក់ទី និងឈ្មោះវិទ្យាល័យ។

**ផ្នែកទី២៖ ឥរិយាបថរបស់សិស្សលើការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀនភាសាអង់គ្លេស**

មានសមាសភាគចំនួន៤ គឺអំពីមេរៀន (៦សំណួរ) អំពីការបង្រៀន (១០ សំណួរ) ទំនាក់ទំនងគ្រូ-សិស្ស (៨សំណួរ) និងការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស (៨សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីពីការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀនភាសាអង់គ្លេស។អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សនៅផ្នែកទី២ ស្តីពីមេរៀន ការបង្រៀន និងការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងវិទ្យាល័យចំនួន ៦ នៅខេត្តព្រៃវែង ដែលមានចំនួនសំណាកសរុប ១០០នាក់ លោកគ្រូ-អ្នកគ្រូ ចំនួន២០នាក់ គណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ និងសិស្សចំនួន ៦០ នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ឋិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺកូវីដ-១៩។ វិទ្យាល័យមួយចំនួននៅក្នុងខេត្តព្រៃវែង មានស្ថានភាពទីតាំងភូមិសាស្ត្រខុសគ្នា ទៅតាមស្រុកនីមួយៗ ដោយវិទ្យាល័យស្ថិតក្នុងក្រុងមានភាពរីកចម្រើន វិទ្យាល័យខ្លះមានកម្រិតមធ្យម ហើយក៏មានវិទ្យាល័យខ្លះទៀតស្ថិតនៅក្នុងតំបន់ជួបការលំបាក។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន ៤

ក្នុងខេត្តព្រៃវែង គឺ៖ ក្រុងព្រៃវែង ស្រុកកញ្ច្រៀច ស្រុកកំចាយមារ និងស្រុកស្វាយអន្ទរ។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរនៅមធ្យមសិក្សាទុតិយភូមិចំនួន៦ មានសំណាកសរុបចំនួន ១០០នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ គ្រូបង្រៀនទុតិយភូមិចំនួន២០នាក់ និងសិស្សចំនួន៦០នាក់ បានរៀនភាសាអង់គ្លេសថ្នាក់ទី១២។

*តារាង 3.1៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ*

| ល.រ | ឈ្មោះស្រុក | ចំនួនសំណាក គណៈគ្រប់គ្រង | ចំនួនសំណាក គ្រូបង្រៀន | ចំនួនសំណាក សិស្ស |
|---|---|---|---|---|
| ១ | ក្រុងព្រៃវែង | ៦ | ៥ | ២០ |
| ២ | ស្រុកកញ្ច្រៀច | ៤ | ៤ | ១០ |
| ៣ | ស្រុកកំចាយមារ | ៦ | ៧ | ២០ |
| ៤ | ស្រុកស្វាយអន្ទរ | ៤ | ៤ | ១០ |
| **សរុប** | | **២០** | **២០** | **៦០** |

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដារ ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ការវិភាគលើមតិយោបល់បន្ថែម គឺអ្នកសិក្សាបានចាប់ក្រុមពាក្យទៅតាមទស្សនៈយល់ឃើញនីមួយៗ ពីការបំពេញកម្រងសំណួររួច

ធ្វើការឆ្លុះបញ្ចាំងទៅនឹងមធ្យមភាគដែលទទួលបាន ព្រមទាំងស្រង់ជាតុចូលមួយចំនួនពីអ្នកឆ្លើយតបដាក់ក្នុងសំណួមពរ។

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ លើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និង សិស្សានុសិស្ស។ លទ្ធផលដែលទទួលបាននឹងត្រូវបានយកមកពិភាក្សាលើចំណុចសំខាន់នានា ដែលផ្តោតទៅនឹងកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅក្នុងខេត្តព្រៃវែង។ ពិសេសតាមរយៈការពិភាក្សាលើលទ្ធផលដែលទទួលបាន នឹងអាចបង្ហាញពីដំណោះស្រាយដ៏មានប្រសិទ្ធភាពដើម្បីធ្វើយ៉ាងណាឱ្យលទ្ធផលប្រឡងបានល្អប្រសើរឡើងវិញ។

## ៤.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួន ៦ ក្នុងក្រុង/ស្រុក ចំនួន ៤ គោលដៅនៃការសិក្សាស្រាវជ្រាវដោយ ស្រុកកញ្ជៀចមាន ១ វិទ្យាល័យ ស្រុកកំចាយមារមាន ២ វិទ្យាល័យ ស្រុកស្វាយអន្ទរ ១ វិទ្យាល័យ និង ក្រុងព្រៃវែងមាន ២ វិទ្យាល័យ។

នៅក្នុងផ្នែកនេះ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង លោកគ្រូ-អ្នកគ្រូ និង សិស្សានុសិស្ស ដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលមានព័ត៌មានលម្អិតពី កម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ/បង្រៀន និងមុខវិជ្ជាឯកទេសដូចក្នុងតារាងខាងក្រោម៖

### ៤.១.១ ព័ត៌មានទូទៅពីគ្រូបង្រៀន

តាមរយៈការប្រមូលទិន្នន័យ(ឧបសម្ព័ន ក) ឃើញថាគ្រូបង្រៀនថ្នាក់ទី១២ មាន ១២ នាក់ ថ្នាក់ទី១១មាន ៦នាក់ និង ថ្នាក់ទី១០ មានចំនួន ២ នាក់ ។ គ្រូបង្រៀនភេទប្រុសមានចំនួន១៧ នាក់ និងភេទស្រីមានចំនួន ០៣ នាក់ ។ គ្រូបង្រៀនមានអាយុចន្លោះពី ៣០-៣៥ឆ្នាំមានចំនួន ១៧ នាក់ និងមានអាយុលើសពី ៣៥ ឆ្នាំ មានចំនួន ៧នាក់ ។ គ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន ១៧

នាក់ និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣ នាក់ ។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនចន្លោះពី ៦-១០ឆ្នាំ មានចំនួន ០៩ នាក់ បទពិសោធន៍ពី ១១-១៥ ឆ្នាំមានចំនួន ០៨ នាក់ និង លើសពី១៥ឆ្នាំមានចំនួន ០៣ នាក់ ។ គ្រូបង្រៀនទាំងអស់ជាគ្រូឯកទេសភាសាអង់គ្លេស ដែលមានគុណវុឌ្ឍិត្រឹមត្រូវចំណេះដឹងទូលំទូលាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សក្នុងការសិក្សារៀនសូត្រ។

### ៤.១.២ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង

តាមការប្រមូលទិន្នន័យ(ឧបសម្ព័ន្ធ ខ)បានពីគណៈគ្រប់គ្រងបង្ហាញថា គណៈគ្រប់គ្រងដែលមានតួនាទីជានាយកសាលាមានចំនួន ០៤ នាក់ និង ក្រៅពីនោះគឺមានតួនាទីជានាយករងទាំងអស់ ។ គណៈគ្រប់គ្រងសាលាទាំងអស់ជាភេទប្រុស មានអាយុលើសពី ៤០ឆ្នាំ មានចំនួន ១៨នាក់ និង អាយុចន្លោះពី ៣៦ ដល់ ៤០ ឆ្នាំមានចំនួនតែ០២នាក់ប៉ុណ្ណោះ។ គណៈគ្រប់គ្រងភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន ១៨ នាក់ និង សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ០២ នាក់។គណៈគ្រប់គ្រងសាលាទាំងអស់សុទ្ធតែមានបទពិសោធន៍ការងារយូរឆ្នាំ ក្នុងវិស័យអប់រំលើសពី ១៥ ឆ្នាំពិសេសក្នុងការងារបង្រៀន និងគ្រប់គ្រង។ នាយក នាយករងមានតែ ០២ នាក់ប៉ុណ្ណោះចេះភាសាអង់គ្លេស និងមានឯកទេសភាសាអង់គ្លេស និង ១៨ នាក់ទៀតមានឯកទេសផ្សេង ។ គណៈគ្រប់គ្រងសាលាដែលមានចំណេះដឹងភាសាបរទេសមានចំនួន ១៣នាក់ ទាំងភាសាអង់គ្លេស និង ភាសាបារាំង។ដោយឡែកគណៈគ្រប់គ្រងចំនួន ០៧ នាក់ ទៀតមិនចេះភាសាបរទេសទេ។

### ៤.១.៣ ព័ត៌មានទូទៅពីសិស្សានុសិស្ស

តាមទិន្នន័យ (ឧបសម្ព័ន្ធ គ)ដែលទទួលបានពីក្នុងការស្រាវជ្រាវលើសិស្សានុសិស្ស បង្ហាញថាសិស្សានុសិស្សទាំងអស់សុទ្ធតែធ្លាប់រៀនភាសាអង់គ្លេសពីមុនមក។ សិស្សដែលជាភេទប្រុសមានចំនួន ២៤ នាក់ ក្រៅពីនោះគឺសុទ្ធតែភេទស្រី ។ សិស្សានុសិស្សទាំងអស់មានអាយុចន្លោះពី ១៧-១៩ឆ្នាំ និង ជាសិស្សដែលកំពុងរៀនថ្នាក់ទី ១២ ក្នុងឆ្នាំសិក្សា ២០១៩-២០២០

## ៤.២ កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស

### ៤.២.១ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

នៅក្នុងតារាងទិន្នន័យខាងនេះ មានបង្ហាញពីមធ្យមភាគការឆ្លើយតបរបស់គ្រូបង្រៀន លើកត្តាជះឥទ្ធិពលដល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស តាមបទពិសោធន៍នៃការបង្រៀន របស់លោកគ្រូ-អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិនាពេលកន្លងមក ។

*តារាង 4.1៖ ក.ការអនុវត្តកម្មវិធីសិក្សា*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មុខវិជ្ជាភាសាអង់គ្លេសបានបង្រៀនចប់ តាមកម្មវិធីសិក្សា | 3.15 | មធ្យម |
| ២ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជាភាសាអង់គ្លេស | 4.20 | ល្អណាស់ |
| ៣ | បានរៀបចំបំណែងចែកមេរៀន តាមកាលវិភាគយ៉ាងត្រឹមត្រូវ | 4.25 | ល្អណាស់ |
| ៤ | មានបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស | 4.25 | ល្អណាស់ |
| ៥ | សៀវភៅពុម្ពសិក្សា សមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស | 3.55 | ល្អ |
| ៦ | បានរៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆមាស | 4.15 | ល្អ |
| ៧ | បានស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន | 4.30 | ល្អណាស់ |
| ៨ | កិច្ចតែងការបង្រៀនបានពិនិត្យដោយគណៈគ្រប់គ្រង | 4.05 | ល្អ |
| **សរុប** | | **3.99** | **ល្អ** |

តាមតារាងខាងលើ បានបង្ហាញថា សមាសភាគទាំង៨ នៃ ការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅតាមវិទ្យាល័យមានតម្លៃមធ្យមភាគខុសៗគ្នា ដែលសមាសភាគចំនួន ៣ មានកម្រិតល្អ សមាសភាគចំនួន ៤ ទទួលបានកម្រិតល្អណាស់ និង ១ សមាសភាគទទួលបានកម្រិត មធ្យម តែប៉ុណ្ណោះ។ ផ្នែកដែលមានលំដាប់មធ្យមភាគខ្ពស់ជាច់គេក្នុងលំដាប់ទី១ គឺការស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន ដែលមាន មធ្យមភាគ = 4.30 ទទួលបានកម្រិតល្អណាស់ ហើយមានសមាសភាគ ៣ ទៀត

ដែលស្ថិតក្នុងកម្រិតមធ្យមភាគប្រហាក់ប្រហែលគ្នា ពីចន្លោះ មធ្យមភាគ = 4.20 ដល់ មធ្យមភាគ = 4.25 ក្នុងកម្រិតល្អណាស់ដូចគ្នាគឺ (១)មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជាភាសាអង់គ្លេស (២) បានរៀបចំបំណែងចែកមេរៀន តាមកាលវិភាគយ៉ាងត្រឹមត្រូវ (៣)មានបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ។ បើទោះបីជាមានចំណុចល្អច្រើនក៏ពិតមែន យើងសង្កេតឃើញថានៅមានកម្រិតពិន្ទុមធ្យមភាគលើសមាសភាគមួយ ក្នុងចំណោមសមាសភាគទាំង ៨ ដែលមានលំដាប់ពិន្ទុមធ្យមភាគទាបជាងគេបង្អស់ដែលមាន មធ្យមភាគ = 3.15 ទទួលបានកម្រិតមធ្យម គឺ មុខវិជ្ជាភាសាអង់គ្លេសបានបង្រៀនចប់ តាមកម្មវិធីសិក្សា។ ជារួមដោយផ្អែកលើការសរុបពិន្ទុមធ្យមភាគសរុបនេះចំណុចទី១គឺ មធ្យមភាគ= 3.98 ស្ថិតក្នុងកម្រិតល្អ អាចចាត់ទុកថាមិនមែនជាកត្តាជះឥទ្ធិពលខ្លាំងដល់លទ្ធផលប្រឡងបាក់ឌុបមុខវិជ្ជាភាសាអង់គ្លេសឡើយ ។

*តារាង 4.2៖ ខ.ដំណើរការបង្រៀន*

| ល.រ | បរិយាយ | មធ្យម ភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានរៀបចំកិច្ចតែងការ តាមបំណែងចែកកម្មវិធីសិក្សា | 4.15 | ល្អ |
| ២ | បានអនុវត្តតាមគ្រប់ជំហានទាំង៥ នៃកិច្ចតែងការបង្រៀន | 4.10 | ល្អ |
| ៣ | បានបែងចែកក្រុមកិច្ចការ ដល់សិស្សសម្រាប់សកម្មភាពក្នុងថ្នាក់ | 3.95 | ល្អ |
| ៤ | មានចំណេះដឹង និងជំនាញវិជ្ជាជីវៈ ទាក់ទងទៅនឹងវិធីសាស្រ្តបង្រៀនភាសាអង់គ្លេស | 4.25 | ល្អណាស់ |
| ៥ | យល់ច្បាស់ពីតួនាទីរបស់ខ្លួន ក្នុងការអនុវត្តវិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេស | 4.15 | ល្អ |
| ៦ | មានឧទាហរណ៍ ក្នុងការពន្យល់ និងបំណកស្រាយដោយអនុវត្តទៅតាមជំហាននៃកិច្ចតែងការ | 4.20 | ល្អណាស់ |
| ៧ | ផ្តល់កិច្ចការផ្ទះដល់សិស្សជាប្រចាំ | 3.80 | ល្អ |

| | | | |
|---|---|---|---|
| ៨ | មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន | 4.30 | ល្អណាស់ |
| សរុប | | **4.11** | **ល្អ** |

តាមតារាងខាងលើ បានបង្ហាញថា សមាសភាគទាំង៨ នៃ ការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅតាមវិទ្យាល័យមានតម្លៃមធ្យមភាគខុសៗគ្នា ផ្នែកដែលមានលំដាប់មធ្យមភាគខ្ពស់ជាច់គេក្នុងលំដាប់ទី១ គឺ គ្រូបង្រៀនមានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន ដែលមាន មធ្យមភាគ = 4.30 ទទួលបានកម្រិតល្អណាស់ ហើយមានសមាសភាគ ៥ ទៀតដែលស្ថិតក្នុងកម្រិតមធ្យមភាគប្រហាក់ប្រហែលគ្នា ពីចន្លោះ មធ្យមភាគ = 3,80 ដល់ មធ្យមភាគ = 4.15 ក្នុងកម្រិតល្អ។ ជារួមដោយផ្អែកលើការសរុបពិន្ទុមធ្យមភាគសរុបនេះចំណុចទី ២ គឺ មធ្យមភាគ= 4,11 ស្ថិតក្នុងកម្រិតល្អ អាចចាត់ទុកថាកត្តាទី១ នេះក៏មិនមែនជាកត្តាជះឥទ្ធិពលខ្លាំងដល់លទ្ធផលប្រឡងបាក់ឌុបមុខវិជ្ជាភាសាអង់គ្លេសដែរ។

***តារាង 4.3៖ គ.ទំនាក់ទំនងគ្រូ-សិស្ស***

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស | 4.10 | ល្អ |
| ២ | បង្កបរិយាកាសឱ្យសិស្សចេះរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម | 4.15 | ល្អ |
| ៣ | បានជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស | 4.10 | ល្អ |
| ៤ | បានជំរុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | 4.05 | ល្អ |
| ៥ | ជំរុញការចូលរួមយ៉ាងសកម្ម របស់សិស្សក្នុងសកម្មភាពសិក្សា | 4.00 | ល្អ |
| ៦ | បានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន | 4.00 | ល្អ |
| ៧ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | 4.20 | ល្អណាស់ |
| ៨ | សិស្សានុសិស្ស រៀនមុខវិជ្ជាភាសាអង់គ្លេសដោយភាពរីករាយ | 3.70 | ល្អ |
| សរុប | | **4.04** | **ល្អ** |

តាមតារាងខាងលើ បានបង្ហាញថា សមាសភាគទាំង៨ នៃ ការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅតាមវិទ្យាល័យក៏មានតម្លៃមធ្យមភាគខុសៗគ្នាផងដែរ ផ្នែកដែលមានលំដាប់មធ្យមភាគខ្ពស់ដាច់គេគឺ ការបានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា ដែលមាន មធ្យមភាគ = 4.20 ទទួលបានកម្រិតល្អណាស់។យ៉ាងណាមិញ បើយើងក្រឡេកមើលសូចនាករទាំងអស់ ដែលត្រូវបានវាយតម្លៃតាមរយៈកម្រងសំណួរ ក៏នៅមានចំនុចដែលទទួលបានពិន្ទុមធ្យមភាគតិចជាងបំផុត ដែល មធ្យមភាគ= 3.70 កម្រិតល្អគឺ សិស្សានុសិស្ស រៀនមុខវិជ្ជាភាសាអង់គ្លេសដោយភាពរីករាយ ។

*តារាង 4.4៖ ឃ. ការប្រើប្រាស់សម្ភារៈឧបទ្ទេស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្រ | 3.40 | មធ្យម |
| ២ | បានប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស | 3.40 | មធ្យម |
| ៣ | សម្ភារៈឧបទ្ទេស បានជួយឱ្យការសិក្សារីកចម្រើន | 3.75 | ល្អ |
| ៤ | បានប្រើប្រាស់សម្ភារៈឧបទ្ទេស ក្នុងការបង្រៀន ញឹកញាប់ | 3.95 | ល្អ |
| ៥ | បានប្រើប្រាស់រូបភាពទាក់ទងទៅនឹងសកម្មភាពនៃខ្លឹមសារមេរៀនជាប្រចាំ | 3.70 | ល្អ |
| **សរុប** | | **3.64** | **ល្អ** |

តាមតារាងខាងលើ បង្ហាញពីលំដាប់ពិន្ទុដែលបានត្រូវបានយកទៅវិភាគ ។ ក្នុងចំណោមសូចនាករទាំង ៥ ក្នុងតារាងខាងលើ បង្ហាញថា ការប្រើប្រាស់សម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀន អាចជាកត្តាចម្បងទី១ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស ។ ក្នុងនោះដែរ បើយើងក្រឡេកមើលពិន្ទុមធ្យមភាគដែលទាបជាងគេ មធ្យមភាគ= 3.40 កម្រិតមធ្យម មានពីរសមាសភាគគឺ( ១ )មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការ

បង្រៀនតាមវិធីសាស្ត្រ និង (២)បានប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ។ ក្រៅពីនោះសុទ្ធតែមានកម្រិតពិន្ទុល្អទាំងអស់។

*តារាង 4.5៖ ទិន្នន័យសរុបរបស់គ្រូបង្រៀន*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | ការអនុវត្តកម្មវិធីសិក្សា | 3.99 | ល្អ |
| ខ | ដំណើរការបង្រៀន | 4.11 | ល្អ |
| គ | ទំនាក់ទំនងគ្រូ-សិស្ស | 4.04 | ល្អ |
| ឃ | ការប្រើប្រាស់សម្ភារៈឧបទ្ទេស | 3.64 | ល្អ |
| **សរុប** | | **3.94** | ល្អ |

តាមតារាងទិន្នន័យខាងលើបង្ហាញថា មធ្យមភាគសរុបលើការយល់ឃើញរបស់គ្រូបង្រៀនលើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាមុខវិជ្ជាភាសាអង់គ្លេសគឺមាន មធ្យមភាគ= 3.94 ទទួលបានកម្រិតល្អ។ ផងដែរនោះ ក្នុងចំណោមសមាសធាតុធំៗទាំង ៤ ក្នុងតារាងសមាសធាតុដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេលំដាប់ទី១គឺ ដំណើរការបង្រៀនដែលមានតម្លៃមធ្យមភាគ= 4.11 លំដាប់ទី២ ទំនាក់ទំនងគ្រូសិស្ស (មធ្យមភាគ=4.04) និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាប (មធ្យមភាគ= 3.64) ជាងគេបំផុតគឺ ការប្រើប្រាស់សម្ភារៈឧបទ្ទេស។

### ៤.២.២ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

នៅក្នុងតារាងទិន្នន័យនេះ មានបង្ហាញពីមធ្យមភាគសរុបកត្តាចម្បងៗមួយចំនួនដែលជះឥទ្ធិពលដល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស តាមបទពិសោធន៍នៃការគ្រប់គ្រងរបស់នាយក នាយករងទាំង៦វិទ្យាល័យ នៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលបានអនុវត្តន៍ពេលកន្លងមក ។

*តារាង 4.6៖ ក. ការរៀបចំផែនការ*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានទស្សនៈវិស័យ និងគោលដៅដឹកនាំគ្រប់គ្រងច្បាស់លាស់ | 4.10 | ល្អ |
| ២ | បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ | 4.10 | ល្អ |
| ៣ | មានផែនការប្រចាំឆ្នាំ ដើម្បីអនុវត្តជាប្រចាំ | 4.05 | ល្អ |
| ៤ | បានអនុវត្តកម្មវិធីសិក្សាផ្នែកភាសាអង់គ្លេសទៅតាមតម្រូវការសិស្ស | 4.15 | ល្អ |
| ៥ | បានផ្តល់សេវាកម្មសិក្សាស្របតាមគោលការណ៍ស្តីពីអភិបាលកិច្ចល្អ | 4.05 | ល្អ |
| ៦ | មានបំណែងចែកភារកិច្ចនិងការទទួលខុសត្រូវការងារ ច្បាស់លាស់ | 4.30 | ល្អណាស់ |
| ៧ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ មុខវិជ្ជាភាសាអង់គ្លេស | 4.00 | ល្អ |
| ៨ | ត្រួតពិនិត្យជាប្រចាំលើ កិច្ចការរៀន និងបង្រៀនភាសាអង់គ្លេស | 3.90 | ល្អ |
| ៩ | ផ្តល់កិច្ចគាំទ្រទាំងស្មារតី និងសម្ភារៈដល់សិស្សពូកែភាសាអង់គ្លេស | 4.00 | ល្អ |
| **សរុប** | | **4.07** | **ល្អ** |

តារាងខាងលើបានបង្ហាញថា សមាសភាគទាំង៩ នៃការរៀបចំផែនការរបស់គណៈគ្រប់គ្រងលើការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេស នៅតាមវិទ្យាល័យទាំងអស់ដែលទទួលបាន មានតម្លៃពិន្ទុមធ្យមភាគប្រហាក់ប្រហែលគ្នា ពីចន្លោះ មធ្យមភាគ = 3.90 ដល់ មធ្យមភាគ= 4.15 ក្នុងកម្រិតល្អ ដែលមានរហូតដល់ទៅ៨សូចនាករ ។ ដោយឡែកផ្នែកមួយដែលមានលំដាប់ពិន្ទុខ្ពស់ជាច់គេក្នុងលំដាប់ទី១ គឺមានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារច្បាស់លាស់ ដែលមាន មធ្យមភាគ = 4.30 ទទួលបានកម្រិតល្អណាស់។ តាមរយៈការគណនាលើសូចនាករទាំងអស់ សរបញ្ជាក់ឱ្យឃើញថាការអនុវត្តន៍ផែនការរបស់គណៈគ្រប់គ្រងបានឆ្លើយតបទៅនឹងការរៀន និងបង្រៀនភាសាអង់គ្លេសបានល្អ ។

*តារាង 4.7៖ ខ. ការកសាងសមត្ថភាពគ្រូ*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានអភិវឌ្ឍគុណភាព និងសមត្ថភាពជំនាញបច្ចេកទេសដល់គ្រូ | 4.00 | ល្អ |
| ២ | ថែរក្សាគ្រូមានសមត្ថភាពជំនាញច្បាស់លាស់ ឱ្យនៅបម្រើការងារ | 4.20 | ល្អណាស់ |
| ៣ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន | 4.00 | ល្អ |
| ៤ | បានរៀបចំបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូ | 3.70 | ល្អ |
| ៥ | គ្រូ បានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា | 4.30 | ល្អណាស់ |
| ៦ | គ្រូបង្រៀន បានចូលរួមធ្វើបច្ចុប្បន្នភាព ជាប្រចាំនូវកម្មវិធីសិក្សា | 4.10 | ល្អ |
| ៧ | គ្រូបង្រៀន មានគុណវុឌ្ឍិសមស្របតាមនិយាម និងគោលការណ៍ | 3.95 | ល្អ |
| ៨ | គ្រូបង្រៀន បានប្រើប្រាស់សៀវភៅវិធីសាស្ត្រ និងរៀនដោយច្នៃប្រឌិត | 4.05 | ល្អ |
| ៩ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ ដល់គ្រូមុខវិជ្ជាភាសាអង់គ្លេស | 3.75 | ល្អ |
| **សរុប** | | **4.01** | **ល្អ** |

តាមតារាងខាងលើបង្ហាញថាសូចនាករទាំងអស់ដែលបានឆ្លុះបញ្ចាំងពីការ ខិតខំប្រឹងប្រែងកសាងសមត្ថភាពគ្រូបង្រៀនរបស់គណៈគ្រប់គ្រងនៅតាមវិទ្យាល័យទាំងអស់ដែលទទួលបាន មានតម្លៃពិន្ទុមធ្យមភាគប្រហាក់ប្រហែលគ្នា ពីចន្លោះ មធ្យមភាគ = 3.75 ដល់ មធ្យមភាគ= 4.10 ក្នុងកម្រិតល្អ ដែលមានរហូតដល់ទៅ៧សមាសភាគ។ ដោយឡែកផ្នែកដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេក្នុងលំដាប់ទី១ គឺគ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា ដែលមាន មធ្យមភាគ = 4.30 ទទួលបានកម្រិតល្អណាស់ និង លំដាប់ទី២ គឺថែរក្សាគ្រូមានសមត្ថភាពជំនាញច្បាស់លាស់ ឱ្យនៅបម្រើការងារ ដែលមាន មធ្យមភាគ = 4.20។ ជារួមក្នុងចំណុចនេះ ការសរុបពិន្ទុមធ្យមភាគឃើញថា មធ្យមភាគ = 4.01 ស្ថិតក្នុងកម្រិតល្អ នៅតែមានភាពវិជ្ជមានចំពោះគណៈគ្រប់គ្រងលើការជួយដល់ការកសាងសមត្ថភាពគ្រូភាសាអង់គ្លេស។

*តារាង 4.8៖ គ. ការកសាងសមត្ថភាពសិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានផ្តល់ចំណេះដឹងជំនាញរឹង និង ការត្រិះរិះពិចារណាដល់សិស្ស | 3.75 | ល្អ |
| ២ | បានផ្តល់សេវាប្រឹក្សាការសិក្សាដល់សិស្ស | 4.10 | ល្អ |
| ៣ | ផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សា របស់សិស្ស | 4.05 | ល្អ |
| ៤ | សិស្សមានសមត្ថភាពចំណេះដឹង លើជំនាញដែលបានបណ្តុះ | 3.75 | ល្អ |
| ៥ | មានប្រព័ន្ធលើកទឹកចិត្តសិស្ស ទៅតាមលំដាប់ពិន្ទុ | 3.95 | ល្អ |
| ៦ | ពិនិត្យតាមដានលើឥរិយាបថសិក្សារបស់សិស្សានុសិស្សជាប្រចាំ | 4.10 | ល្អ |
| **សរុប** | | **3.95** | **ល្អ** |

តាមតារាងខាងលើបង្ហាញថាសមាសភាគទាំង៦មានពិន្ទុមធ្យមភាគខុសៗគ្នា លើការកសាងសមត្ថភាពសិស្ស របស់គណៈគ្រប់គ្រងនៅក្នុងវិទ្យាល័យទាំង ៦ ក្នុងខេត្តព្រៃវែង ។ ក្នុងចំណោមសមាសភាគទាំងអស់នោះ ផ្នែកដែលទទួលបានពិន្ទុខ្ពស់ដាច់គេមានពីរគឺ (១)បានផ្តល់សេវាប្រឹក្សាការសិក្សាដល់សិស្ស មធ្យមភាគ = 4.10 និងទី (២) ពិនិត្យតាមដានលើឥរិយាបថសិក្សារបស់សិស្សានុសិស្សជាប្រចាំ មធ្យមភាគ = 4.10 ដូចគ្នា។ ជារួមក្នុងចំណុចនេះ គណៈគ្រប់គ្រងស្ទើរតែទាំងអស់ មានយល់ស្របទៅនឹងសូចនាករដែលបានលើកឡើង។

*តារាង 4.9៖ ឃ. ភាគីពាក់ព័ន្ធ*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ផ្សព្វផ្សាយ និងកិច្ចសហការសម្របសម្រួល ក្នុងដំណើរការសិក្សាភាសា | 3.80 | ល្អ |
| ២ | ជំរុញកិច្ចការប្រកួតប្រជែង ក្នុងក្របខណ្ឌសាលារៀន | 3.95 | ល្អ |

| | | | |
|---|---|---|---|
| ៣ | ប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមការរៀននិងបង្រៀនភាសា | 3.70 | ល្អ |
| ៤ | ប្រមូលផ្តុំដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្នុងការចូលរួមដំណើរការរៀននិង ដំណើរការបង្រៀនភាសាអង់គ្លេស | 3.75 | ល្អ |
| **សរុប** | | **3.80** | **ល្អ** |

តាមតារាងទី១១ខាងលើ បានបង្ហាញថា ក្នុងចំណោមសមាសភាគទាំងបួន មិនមានសមាសភាគណាមួយមានពិន្ទុខ្ពស់ដាច់គេឡើយ គឺប្រហាក់ប្រហែលគ្នាស្ថិតក្នុងរង្វង់ មធ្យមភាគ = 3.70 ដល់ មធ្យមភាគ = 3.95 តែប៉ុណ្ណោះ ។ តាមរយៈទិន្នន័យនេះ គណៈគ្រប់គ្រងមួយចំនួនហាក់នៅស្ទាក់ស្ទើរ ក្នុងការស្វែងរកភាគីពាក់ព័ន្ធនានា និងសហការជាមួយដៃគូរក្នុងការជំរុញដល់ការអនុវត្តភាសាអង់គ្លេសឱ្យកាន់តែល្អប្រសើរ ។

***តារាង 4.10៖ ង. ធនធានរូបវន្ត***

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ធនធានរូបវន្ត សម្ភារៈបរិក្ខារ គាំទ្រដល់ការបង្រៀន | 4.05 | ល្អ |
| ២ | បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | 4.10 | ល្អ |
| ៣ | បានបំពាក់សម្ភារៈបរិក្ខារ មុខវិជ្ជាភាសាអង់គ្លេស | 3.60 | ល្អ |
| ៤ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់ដំណើរការមុខវិជ្ជាភាសាអង់គ្លេស | 3.30 | មធ្យម |
| ៥ | មានបន្ទប់អនុវត្ត ភាសាអង់គ្លេស | 3.35 | មធ្យម |
| **សរុប** | | **3.68** | **ល្អ** |

តាមតារាងខាងលើ បង្ហាញពីការប្រើប្រាស់ធនធានរូបវន្តរបស់សាលាដើម្បីឆ្លើយតបទៅនឹងការពង្រឹងសមត្ថភាពភាសាអង់គ្លេសដល់សិស្សានុសិស្ស ។ សមាសភាគដែលមាន កម្រិតពិន្ទុមធ្យមភាគខ្ពស់ជាងគេបំផុតលំដាប់ទី១គឺ បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តតម្លៃ (មធ្យមភាគ= 4.10) ទទួលបានកម្រិតល្អ លំដាប់ទី ២ (មធ្យមភាគ= 4.05) គឺ ធនធានរូបវន្ត សម្ភារៈបរិក្ខារ គាំទ្រដល់ការបង្រៀនក៏

ទទួលបានកម្រិតល្អផងដែរ។ សមាសភាគដែលមាន កម្រិតពិន្ទុមធ្យមភាគទាបជាងគេបំផុតលំដាប់ទី១គឺ មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់ដំណើរការមុខវិជ្ជាភាសាអង់គ្លេសដែលមានមធ្យមភាគ = 3.30 និង លំដាប់ទី២គឺ មានបន្ទប់អនុវត្តន៍ភាសាអង់គ្លេស ដែលមាន មធ្យមភាគ = 3.35 ទទួលបានកម្រិត មធ្យម តែប៉ុណ្ណោះ។

*តារាង 4.11៖ ច. ការធានាគុណភាព*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានពិនិត្យតម្រូវការ និងការផ្គត់ផ្គង់ដល់បុគ្គលិក និងគ្រូបង្រៀន | 4.05 | ល្អ |
| ២ | បានពង្រឹងការអនុវត្តគោលការណ៍ ស្តីពីការធានាគុណភាពសិក្សា | 4.00 | ល្អ |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ | 4.05 | ល្អ |
| ៤ | បានរៀបចំគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា | 4.10 | ល្អ |
| ៥ | ផែនការបណ្តុះបណ្តាល ស្របតាមលទ្ធផលរំពឹងទុក | 3.50 | ល្អ |
| ៦ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស | 4.10 | ល្អ |
| ៧ | បានបង្កើតការស្រាវជ្រាវ វិធីសាស្ត្របង្រៀន | 4.10 | ល្អ |
| **សរុប** | | **3.99** | **ល្អ** |

តាមតារាងខាងលើបង្ហាញពីការធានាគុណភាពលើការបង្រៀន និង រៀន របស់គណៈគ្រប់គ្រង ចំពោះ គ្រូបង្រៀន និង សិស្សានុសិស្ស។ សមាសភាគទាំងអស់សុទ្ធតែទទួលបានកម្រិតល្អ ។ សមាសធាតុដែលមានមធ្យមភាគខ្ពស់ជាងគេមាន ៣ គឺ (១)បានរៀបចំគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា (២) បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស (៣) បានបង្កើតការស្រាវជ្រាវ វិធីសាស្ត្របង្រៀនដែលមានតម្លៃ (មធ្យមភាគ = 4.10)។ មានតែសមាសភាគមួយប៉ុណ្ណោះដែលមាន កម្រិតពិន្ទុមធ្យមភាគទាបជាងគេ បំផុតគឺ ផែនការបណ្តុះបណ្តាល ស្របតាមលទ្ធផលរំពឹងទុកដែលមាន មធ្យមភាគ = 3.50 ទទួលបាន កម្រិតល្អ ។

*តារាង 4.12៖ ទិន្នន័យសរុបរបស់គណៈគ្រប់គ្រង*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | ការរៀបចំផែនការ | 4.07 | ល្អ |
| ខ | ការកសាងសមត្ថភាពគ្រូ | 4.01 | ល្អ |
| គ | ការកសាងសមត្ថភាពសិស្ស | 3.95 | ល្អ |
| ឃ | ភាគីពាក់ព័ន្ធ | 3.80 | ល្អ |
| ង | ធនធានរូបវន្ត | 3.68 | ល្អ |
| ច | ការធានាគុណភាព | 3.99 | ល្អ |
| **សរុប** | | **3.91** | ល្អ |

តាមតារាងទិន្នន័យខាងលើបង្ហាញថា មធ្យមភាគសរុបលើការយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡង មានពិន្ទុមធ្យមភាគ= 3.91 ទទួលបានកម្រិតល្អ។ ក្នុងចំណោមសមាសធាតុទាំង៦ សមាសធាតុដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេគឺ ការរៀបចំផែនការដែលមានតម្លៃមធ្យមភាគ= 4.07 និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាបជាងគេបំផុតគឺ ធនធានរូបវន្ត ដែលតម្លៃពិន្ទុមធ្យមភាគត្រឹមតែ 3.68 តែប៉ុណ្ណោះក្នុងចំណោមសូចនាករទាំងអស់។

### ៤.២.៣ ទិន្នន័យពីការឆ្លើយតបរបស់សិស្ស កត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

នៅក្នុងតារាងទិន្នន័យនេះ មានបង្ហាញពីមធ្យមភាគសរុបកត្តាចម្បងៗមួយចំនួនដែលជះឥទ្ធិពលដល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស តាមបទពិសោធន៍នៃការសិក្សារបស់សិស្សានុសិស្សនៅវិទ្យាល័យទាំង ៦ ក្នុងខេត្តព្រៃវែង ។

*តារាង 4..13 ៖ ក. អំពីមេរៀន*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មេរៀននីមួយៗ មានសារៈប្រយោជន៍យកមកប្រើប្រាស់បាន | 3.43 | ល្អ |

| | | | |
|---|---|---|---|
| ២ | មេរៀនដែលបានរៀន ងាយស្រួលយល់ និងចងចាំ | 3.00 | មធ្យម |
| ៣ | មេរៀនដែលបានរៀន គឺស្របតាមការរំពឹងទុករបស់សិស្ស | 3.15 | មធ្យម |
| ៤ | ឯកសារមេរៀន បានជួយដល់ការ សិក្សារៀនសូត្រ | 3.80 | ល្អ |
| ៥ | សម្ភារៈឧបទ្ទេស ឆ្លើយតបវិធីសាស្ត្របង្រៀន | 3.13 | មធ្យម |
| ៦ | វគ្គបណ្តុះបណ្តាល ផ្តល់ភាពងាយស្រួលដល់ដំណើរការរៀនសូត្រ | 3.38 | មធ្យម |
| **សរុប** | | **3.32** | **មធ្យម** |

តាមតារាងខាងលើ បង្ហាញពីកម្រិតនៃការពេញចិត្តរបស់សិស្សានុសិស្ស លើមេរៀនដែលពួកគេបាននឹងកំពុងសិក្សា។ក្នុងចំណោមសមាសភាគទាំងអស់ដែលបានលើកឡើងក្នុងតារាងបានបង្ហាញថាមានកម្រិតពិន្ទុមធ្យមភាគល្អចំនួន ២សមាសភាគ និង មធ្យមចំនួន ៤សមាសភាគ។ សមាសភាគដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេបំផុតគឺ ឯកសារមេរៀន បានជួយដល់ការ សិក្សារៀនសូត្រដែលមានតម្លៃ (មធ្យមភាគ= 3.80)។ សមាសភាគដែលមានពិន្ទុមធ្យមភាគទាបជាងគេបំផុតគឺមេរៀនដែលបានរៀន ងាយស្រួលយល់ និងចងចាំ ដែលមានមធ្យមភាគ = 3.00 ទទួលបានកម្រិតមធ្យម ។ ក្រៅពីនោះក៏នៅមានសមាសភាគពីរទៀតដែលមធ្យមភាគទាបផងដែរគឺ (១)សម្ភារៈឧបទ្ទេស ឆ្លើយតបវិធីសាស្ត្របង្រៀន និង (២)មេរៀនដែលបានរៀន គឺស្របតាមការរំពឹងទុករបស់សិស្ស ដែលមាន មធ្យមភាគ= 3.10 ទៅ មធ្យមភាគ = 3.15 ទទួលបានកម្រិតមធ្យមតែប៉ុណ្ណោះ ។

***តារាង 4.14៖ ខ. អំពីការបង្រៀន***

| **ល.រ** | **បរិយាយ** | **មធ្យមភាគ** | **កម្រិតចង្អុលបង្ហាញ** |
|---|---|---|---|
| ១ | គ្រូបង្រៀន មានវិធីសាស្ត្របង្រៀនបានល្អ | 3.80 | ល្អ |
| ២ | គ្រូបង្រៀន បានពន្យល់ច្បាស់លាស់អំពីមេរៀននីមួយៗ | 3.65 | ល្អ |
| ៣ | គ្រូបង្រៀនមានចំណេះដឹងច្បាស់លាស់លើមេរៀនបង្រៀន | 3.88 | ល្អ |
| ៤ | ផ្តល់ពេលវេលាសមស្រប ក្នុងដំណើរការបង្រៀន | 3.37 | មធ្យម |

| | | | |
|---|---|---|---|
| ៥ | គ្រូបង្រៀន មានការទទួលខុសត្រូវខ្ពស់លើការបង្រៀន | 3.92 | ល្អ |
| ៦ | មានសីលធម៌ អាកប្បកិរិយា និងទំនាក់ទំនងល្អជាមួយសិស្ស | 3.93 | ល្អ |
| ៧ | មានឥរិយាបថវិជ្ជមានចំពោះការបង្រៀន ដោយមានចិត្តចង់ចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់សិស្ស | 3.88 | ល្អ |
| ៨ | ឆ្លើយតបទៅនឹងសំណួរ ឬចម្ងល់របស់សិស្ស បានច្បាស់លាស់ និងមាន ទំនុកចិត្តខ្ពស់ | 3.72 | ល្អ |
| ៩ | លើកទឹកចិត្តសិស្សឱ្យចូលរួមបញ្ចេញមតិយោបល់ តាមរយៈការឆ្លើយសំណួរ ការអនុវត្តក្នុងថ្នាក់ | 3.93 | ល្អ |
| ១០ | ជារួម គ្រូមានការពេញចិត្តទៅលើការបង្រៀនភាសាអង់គ្លេសនៅក្នុងវិទ្យាល័យ | 3.97 | ល្អ |
| **សរុប** | | **3.81** | **ល្អ** |

តាមតារាងខាងលើបង្ហាញពីកម្រិតនៃការពេញចិត្តរបស់សិស្សានុសិស្សលើការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ។ សមាសភាគនីមួយៗមានមធ្យមភាគខុសៗគ្នា ដែលសមាស ភាគចំនួន ប្រាំបួនមានកម្រិតល្អ និងសមាសភាគចំនួន១ទទួលបានកម្រិតតែមធ្យមប៉ុណ្ណោះ។ ផ្នែកដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេបំផុតគឺគ្រូមានការពេញចិត្តទៅលើការបង្រៀនភាសាអង់គ្លេសនៅក្នុងវិទ្យាល័យដែលមានតម្លៃ(មធ្យមភាគ= 3.97)ទទួលបានកម្រិតល្អ។ ផ្នែកដែលមានលំដាប់ពិន្ទុទាបជាងគេបំផុតគឺ ការផ្តល់ពេលវេលាសមស្របក្នុងដំណើរការបង្រៀន ដែលមាន មធ្យមភាគ =3.37 ទទួលបានកម្រិតមធ្យម ។តាមរយៈទិន្នន័យលើចំណុចនេះ ជារួមយើងឃើញថាការបង្រៀន របស់លោកគ្រូ-អ្នកគ្រូមិនទាន់ចាត់ទុកជាកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងទេ។តែផ្ទុយទៅវិញ ការមិនផ្តល់ពេលវេលាសមស្របសម្រាប់ការបង្រៀន អាចជាកត្តាតូចមួយក្នុងចំណោមកត្តាដទៃទៀត។

*តារាង 4.15៖ គ. ទំនាក់ទំនងគ្រូ-សិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | គ្រូបានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស | 3.67 | ល្អ |

| | | | |
|---|---|---|---|
| ២ | គ្រូបង្កបរិយាកាសឱ្យសិស្សចេះរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម | 3.97 | ល្អ |
| ៣ | គ្រូបានជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស | 3.80 | ល្អ |
| ៤ | គ្រូបានជំរុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | 3.98 | ល្អ |
| ៥ | គ្រូជំរុញការចូលរួមយ៉ាងសកម្មរបស់សិស្ស ក្នុងសកម្មភាពសិក្សា | 3.68 | ល្អ |
| ៦ | គ្រូបានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន | 3.62 | ល្អ |
| ៧ | គ្រូបានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | 3.77 | ល្អ |
| ៨ | សិស្សានុសិស្ស រៀនមុខវិជ្ជាភាសាអង់គ្លេសដោយភាពរីករាយ | 3.45 | ល្អ |
| **សរុប** | | **3.74** | **ល្អ** |

តាមតារាងខាងលើបង្ហាញពីទំនាក់ទំនងរវាងគ្រូ និងសិស្សក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស នៅវិទ្យាល័យទាំងប្រាំមួយក្នុងខេត្តព្រៃវែង។សមាសភាគនីមួយៗមានមធ្យមភាគខុសៗគ្នាដែលសមាសភាគទាំងអស់សុទ្ធតែទទួលបានកម្រិតល្អ។ផ្នែកដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេបំផុតគឺគ្រូបង្កបរិយាកាសឱ្យសិស្សចេះរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម ដែលមានមធ្យមភាគ = 3.97 ទទួលបានកម្រិតល្អ។ប៉ុន្តែក៏មានសមាសភាគចំនួន១ដែលមានលំដាប់ពិន្ទុតិចជាងគេបំផុតគឺ សិស្សានុសិស្ស រៀនមុខវិជ្ជាភាសាអង់គ្លេសដោយភាពរីករាយដែលមានមធ្យមភាគ = 3.45 ។ ជារួមទំនាក់ទំនងគ្រូ-សិស្ស គឺស្ថិតក្នុងសភាពមួយល្អបង្គួរដែលអាចទទួលយកបាន។

***តារាង 4.16៖ ឃ. ការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស***

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានបង្កើតក្លឹបសិក្សា ជាក្រុម លើមុខវិជ្ជាភាសាអង់គ្លេស | 3.10 | មធ្យម |
| ២ | បានសិក្សាមុខវិជ្ជាភាសាអង់គ្លេស មុនពេលរៀនថ្នាក់ទី១២ | 3.92 | ល្អ |
| ៣ | យកចិត្តទុកដាក់រៀនមុខវិជ្ជាភាសាអង់គ្លេស ដូចមុខវិជ្ជាគោលដទៃទៀត | 3.38 | មធ្យម |

| | | | |
|---|---|---|---|
| ៤ | បានរៀនធ្វើលំហាត់ តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការ | 3.45 | ល្អ |
| ៥ | ចូលរួមវគ្គបណ្តុះបណ្តាលបន្ថែម លើសមត្ថភាពចំណេះដឹងភាសាអង់គ្លេស | 3.28 | មធ្យម |
| ៦ | មានការបែងចែកពេលវេលា ក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅផ្ទះ | 3.25 | មធ្យម |
| ៧ | ពង្រឹងឥរិយាបថឧស្សាហ៍ ព្យាយាម និងមករៀនទៀងទាត់ | 3.53 | ល្អ |
| ៨ | បានពង្រឹងដំណើរការស្វ័យសិក្សា និងត្រៀមលក្ខណៈសម្រាប់ប្រឡង | 3.47 | ល្អ |
| **សរុប** | | **3.42** | **ល្អ** |

តាមតារាងខាងលើ បង្ហាញពីកម្រិតសិក្សាលើមុខវិជ្ជា ភាសាអង់គ្លេស របស់សិស្សានុសិស្ស ។ ក្នុងចំណោមសមាសភាគទាំង ៨ សមាសភាគ ៥០% ទទួលបានពិន្ទុមធ្យមភាគកម្រិតល្អ និង ៥០% ភាគរយទៀតទទួលបានពិន្ទុមធ្យមភាគកម្រិតមធ្យម។សមាសភាគដែលទទួលបានពិន្ទុកម្រិតល្អខ្ពស់ជាងគេបំផុតគឺ សិស្សបានសិក្សាមុខវិជ្ជាភាសាអង់គ្លេសមុនពេលរៀនថ្នាក់ទី១២ ដែលមាន(មធ្យមភាគ = 3.92) ហើយសមាសភាគមានលំដាប់ពិន្ទុកម្រិតមធ្យមតិចជាងគេបំផុតគឺ មានបង្កើតក្លឹបសិក្សា ជាក្រុម លើមុខវិជ្ជាភាសាអង់គ្លេស ដែលមាន (មធ្យមភាគ = 3.10) ។ តាមរយៈទិន្នន័យនេះ ការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសនៅមានកម្រិត មានន័យថាសិស្សភាគច្រើនមិនទាន់ខិតខំអស់ពីកម្លាំងកាយ ចិត្តក្នុងការសិក្សាមុខវិជ្ជានេះនៅឡើយទេ។

***តារាង 4.17៖ ទិន្នន័យសរុបរបស់សិស្សានុសិស្ស***

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | អំពីមេរៀន | 3.32 | មធ្យម |
| ខ | អំពីការបង្រៀន | 3.81 | ល្អ |
| គ | ទំនាក់ទំនងគ្រូ-សិស្ស | 3.74 | ល្អ |
| ឃ | ការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស | 3.42 | ល្អ |
| **សរុប** | | **3.57** | **ល្អ** |

តាមតារាងទិន្នន័យខាងលើបង្ហាញថាមធ្យមភាគសរុបលើការយល់ឃើញរបស់សិស្សានុសិស្ស លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងមានពិន្ទុមធ្យមភាគ= 3.57 ទទួលបានកម្រិតល្អ។ ក្នុងចំណោមសមាសធាតុទាំង៤សមាសធាតុដែលមានមធ្យមភាគខ្ពស់ជាងគេគឺ អំពីការបង្រៀនដែលមានតម្លៃ(មធ្យមភាគ= 3.81) និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាបជាងគេបំផុតគឺ អំពីមេរៀន ដែលតម្លៃមធ្យមភាគត្រឹមតែ 3.32 តែប៉ុណ្ណោះក្នុងចំណោមសូចនាករទាំងអស់។

## ៤.៣ លទ្ធផលសរុបនៃការឆ្លើយតប របស់គ្រូបង្រៀន គណៈគ្រប់គ្រង និងសិស្សលើកត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

តាមរយៈការបកស្រាយលើសមាសភាគតាមផ្នែកនីមួយៗដែលទទួលបានពី គ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្សនៅក្នុងវិទ្យាល័យគោលដៅទាំងប្រាំមួយក្នុងខេត្តព្រៃវែង អ្នកសិក្សាស្រាវជ្រាវទទួលបានលទ្ធផលដូចខាងក្រោម៖

*តារាង 4.18៖ មធ្យមភាគសរុបរបស់គ្រូបង្រៀន គណៈគ្រប់គ្រង និង សិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គ្រូបង្រៀន លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស | **3.94** | ល្អ |
| ២ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គណៈគ្រប់គ្រង លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស | **3.91** | ល្អ |
| ៣ | ទិន្នន័យសរុបពីការឆ្លើយតបរបស់សិស្ស លើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស | **3.57** | ល្អ |

តាមតារាង ៤.១៨ ទិន្នន័យសរុបពីការឆ្លើយតបលើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសតាមទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងមានតម្លៃ

មធ្យមភាគខ្ពស់ជាងគេ(មធ្យមភាគ=3.94)គ្រូបង្រៀននៅកម្រិតទី២(មធ្យមភាគ=3.91)និងសិស្សមានកម្រិតទាបជាងគេបំផុត(មធ្យមភាគ=3.57)។

## ៤.៤ ការពិភាក្សាលើកត្តាដែលជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

ដូចដែលយើងបានដឹងហើយថាការសិក្សាគឺតែងតែជួបប្រទះនូវបញ្ហាប្រឈមដែលតែងតែកើតមានឡើងក្នុងការគ្រប់គ្រង ការបង្រៀន ពិសេសគឺការរៀនតែម្តង។ បញ្ហាប្រឈមនោះទៀតសោត ជានិច្ចកាលបានកើតឡើងនូវរាល់មុខវិជ្ជាឯកទេសរបស់សិស្សដែលបានកំពុងនឹងសិក្សាទាំងនៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ សិស្សមួយចំនួននៅកម្រិតវិទ្យាល័យ បើតាមការសង្កេតមើលលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឃើញថាមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាដែលមានចំនួនសិស្សជាប់តិចជាងគេបំផុតក្នុងចំណោមមុខវិជ្ជាដទៃទៀត ទាំងនៅកម្រិតថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។នេះជាហេតុដែលអ្នកសិក្សាស្រាវជ្រាវបានខិតខំប្រមែប្រមូលនូវរាល់ទិន្នន័យទាក់ទងនឹងកត្តាទាំងនោះដែលបាននឹងកំពុងជះឥទ្ធិពលធ្ងន់ធ្ងរដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជាភាសាអង់គ្លេសនេះ ។

តាមរយៈការយកសូចនាករដែលពាក់ព័ន្ធជាច្រើនមកវិភាគយ៉ាងហ្មត់ចត់ម្តងមួយៗយើងទទួលបានលទ្ធផលដូចតទៅ៖តាមតារាង៤.១២ខាងលើបង្ហាញថាតាមទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងកត្តាធនធានរូបវ័ន្ត(កញ្ចប់ថវិកាសម្រាប់ដំណើរការមុខវិជ្ជាភាសាអង់គ្លេសនិងបន្ទប់អនុវត្តភាសាអង់គ្លេស) មានឥទ្ធិពលជាវិជ្ជមានទៅលើលទ្ធផលប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស ខណៈកត្តាមួយចំនួនទៀតស្ថិតក្នុងស្ថានភាពនៃការអនុវត្តក្នុងកម្រិតល្អ។ លទ្ធផលនេះស្រដៀងទៅនឹងការសិក្សាស្រាវរបស់លោក Supvitz, Sirinides, and May,(2014) បានបង្ហាញថា ការដឹកនាំការបង្រៀន និងភាពជាអ្នកដឹកនាំរបស់គណៈគ្រប់គ្រងគឺពិតជាទាក់ទងនឹងការអនុវត្តការបង្រៀនរបស់គ្រូ និង ការសិក្សារបស់សិស្ស។ លោកបានបន្ថែមថា ការអនុវត្តការងាររបស់គណៈគ្រប់គ្រងលើការសិក្សារបស់សិស្សមានសារៈសំខាន់ណាស់ព្រោះ គណៈគ្រប់គ្រងគ្រាន់តែជាកត្តាជះឥទ្ធិពលដោយប្រយោលតែ

ប៉ុណ្ណោះ ដោយឡែកគ្រូបង្រៀនទើបជាកត្តាជះឥទ្ធិពលដោយផ្ទាល់ ព្រោះគ្រូបង្រៀនជាអ្នកនៅជាមួយសិស្សក្នុងថ្នាក់ស្ទើរតែរៀងរាល់ថ្ងៃ។ការគ្រប់គ្រងល្អ ធ្វើឱ្យគ្រូបង្រៀនពេញចិត្តបម្រើការងារ ដែលជំរុញលទ្ធផលសិក្សារបស់សិស្សបានល្អផងដែរ។តែផ្ទុយទៅវិញ បើប្រៀបធៀបទៅនឹងការសិក្សាស្រាវជ្រាវរបស់ Phothongsunan,(2014)ក្នុងប្រទេសថៃបានបង្ហាញថាកត្តាដែលរាំងស្ទះដល់លទ្ធផលសិក្សារបស់សិស្សមាន គ្រូបង្រៀន ការខិតខំប្រឹងប្រែង និងបរិយាកាស ដែលសំដៅដល់ទំនាក់ទំនងប្រកបដោយវិជ្ជមានរវាងគ្រូ និង សិស្ស។ បន្ថែមពីនេះទៅទៀត បើតាមទិន្នន័យពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនក្នុងតារាងទី៥ការប្រើប្រាស់សម្ភារៈឧបទ្ទេសជាកត្តាដែលមានឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសដែលមានន័យថាគ្រូបង្រៀនអាចនឹងខ្វះខាតសម្ភារៈឧបទ្ទេសសម្រាប់បង្រៀន ឬមិនបានប្រើសម្ភារៈឧបទ្ទេសដែលជាហេតុធ្វើឱ្យសិស្សពិបាកយល់លើខ្លឹមសារមេរៀន និងពាក្យថ្មីជាដើម។ ក្រៅពីនេះ បើតាមទស្សនៈយល់ឃើញរបស់គ្រូបង្រៀនបង្ហាញថា ការអនុវត្តកម្មវិធីសិក្សា ដំណើរការបង្រៀន និងទំនាក់ទំនងគ្រូ-សិស្ស មានឥទ្ធិពលតិចទួចតែប៉ុណ្ណោះដល់លទ្ធផលសិក្សារបស់សិស្សដែលមានន័យថាការអនុវត្តការងាររបស់គ្រូបង្រៀនស្ថិតក្នុងស្ថានភាពមួយល្អដែលអាចទទួលយកបាន។លទ្ធផលនេះដូចគ្នាទៅនឹងការសិក្សាស្រាវជ្រាវរបស់Mosha,(2014)បានបង្ហាញថាការសិក្សារៀនសូត្ររបស់សិស្សត្រូវបានជះឥទ្ធិពលដោយសារតែគ្មានសម្ភារៈសម្រាប់បង្រៀន និង រៀន។ ក្រៅពីនេះលោកក៏បានបង្ហាញកត្តាបីផ្សេងទៀតដែលធ្វើឱ្យរាំងស្ទះដល់ការសិក្សារបស់សិស្សផងដែររួមមាន៖ គ្រូបង្រៀនដែលមិនបានទទួលការបណ្តុះបណ្តាល គ្រូដែលមានកម្រិតវិជ្ជាជីវៈទាប និងគ្រូដែលទទួលបានការបណ្តុះបណ្តាលច្រើនតែបង្រៀនរំលងចំណុចលំបាកក្នុងកម្មវិធីសិក្សាលម្អិត។តាមទស្សនៈយល់ឃើញរបស់សិស្សក្នុងតារាងទី១៧ បានបង្ហាញថា កត្តាដែលជះឥទ្ធិពលជាវិជ្ជមានចុងក្រោយគេនេះគឺ មេរៀនក្នុងសៀវភៅសិក្សាគោល និង ការសិក្សារបស់សិស្ស។ ទាំងនេះយើងអាចវាយតម្លៃបានថាមេរៀនក្នុងសៀវសិក្សាគោលអាចនឹងពិបាកយល់សម្រាប់សិស្សដោយសារតែមានកម្រិតយល់ដឹងជ្រៅពេក ឬមេរៀននីមួយៗមិនបានផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់សិស្សក៏ថាបាន។លើសពីនេះទៀតសិស្សអាចនឹងមិនបានខិតខំរៀនភាសាអង់គ្លេសបានជាប់លាប់ដូចមុខវិជ្ជាដទៃទៀត។ដូចគ្នានេះដែរតាមរយៈលទ្ធ

ផលនៃការសិក្សាស្រាវជ្រាវរបស់El-Omar,(2016)បានបង្ហាញថាសិស្សដែលចូលចិត្តរៀនភាសាអង់គ្លេសទទួលបានលទ្ធផលល្អជាងសិស្សដែលមិនចូលចិត្តរៀន។ចំណែកសិស្សដែលអានសៀវភៅមានវចនានុក្រមភាសាអង់គ្លេស មើលកម្មវិធីភាសាអង់គ្លេសតាមទូរទស្សន៍ ស្ដាប់ភាសាអង់គ្លេសតាមវិទ្យុ(សម្ភារៈគាំទ្រដល់ការសិក្សា)ត្រូវបានគេសង្កេតឃើញថា លទ្ធផលសិក្សារបស់គេបានប្រសើរជាងសិស្សដែលគ្មានសម្ភារៈគាំទ្រទាំងនោះ។

ប្រហាក់ប្រហែលគ្នានេះដែលគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សបានលើកឡើងថា៖ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅតាមវិទ្យាល័យនាពេលបច្ចុប្បន្ននេះមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមិនបានល្អ បញ្ហាទាំងនោះរួមមាន៖ សាលាខ្វះថវិកាក្នុងការជួយជ្រោមជ្រែងដល់ការប្រើប្រាស់សម្ភារៈឧបទ្ទេសគាំទ្រការបង្រៀន និងរៀនភាសាអង់គ្លេស (ខ្វះសៀវភៅសិក្សាគោល ឧបករណ៍ចាក់សម្លេង វីដេអូ និងឯកសារចាំបាច់មួយចំនួនទៀត) គ្រូឯកទេសមិនសូវទទួលបានការបណ្ដុះបណ្ដាលបំប៉នសមត្ថភាពលើវិធីសាស្ត្រថ្មីៗ សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រ មេរៀនក្នុងសៀវភៅសិក្សាមិនផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃក្នុងបរិបទកម្ពុជា និងកត្តាដែលជះឥទ្ធិពលសំខាន់ជាងគេបំផុតគឺដោយសារមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាបន្ថែម ដែលធ្វើឱ្យសិស្សស្ទើរតែទាំងអស់បង្កើតផ្នត់គំនិតបោះបង់ការសិក្សាភាសាអង់គ្លេសនៅកម្រិតថ្នាក់ទី១២ តែម្ដង។

សរុបសេចក្ដីមក ឆ្លងតាមការពិភាក្សាខាងលើបង្ហាញឱ្យឃើញថាមិនមែនតែគ្រូបង្រៀនទេ ដែលជាដើមចមនៃការធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សធ្លាក់ចុះ សូម្បីតែគណៈគ្រប់គ្រងសាលារៀន ពិសេសសិស្សខ្លួនឯងក៏បានរួមចំណែកក្នុងការធ្វើឱ្យមានការជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់ខ្លួនផងដែរ។ ដូចនេះ អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា អថេរទាំង៣ ដែលមាន(គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និង សិស្សានុសិស្ស)គឺពិតជាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងការសម្រេចលើជោគវាសនារបស់សិស្សគ្រប់រូប(លទ្ធផលសិក្សា) ឆ្ពោះទៅរកវឌ្ឍនភាពរួមមួយសម្រាប់អនាគតរបស់សិស្សគ្រប់រូប និងគ្រប់ជំនាន់ក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព និង បរិមាណលើមុខវិជ្ជាភាសាអង់គ្លេសនេះឡើងវិញ។

## ៤.៥ ទិន្នន័យលើដំណោះស្រាយជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អ

### ៤.៥.១ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន ដើម្បីជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អប្រសើរ

នៅក្នុងតារាងទិន្នន័យនេះបង្ហាញពីមធ្យមភាគ នៃចម្លើយតបរបស់គ្រូបង្រៀនលើកម្រងសំណួរក្នុងការស្វែងរកដំណោះស្រាយដែលជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស នៅក្នុងខេត្តព្រៃវែងបានល្អប្រសើរ តាមបទពិសោធន៍នៃការបង្រៀន របស់លោកគ្រូ-អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិនាពេលកន្លងមក។

*តារាង 4-.19 ៖ ក. កត្តាគណៈគ្រប់គ្រង*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ជំរុញបន្ថែមលើការចូលរួមក្នុងសហគមន៍ភាសាអង់គ្លេស ( CAMTESOL ) | 3.40 | មធ្យម |
| ២ | បង្កលទ្ធភាពគាំទ្រដល់បច្ចេកវិទ្យា ICT សម្រាប់ការរៀន និងបង្រៀនមុខវិជ្ជា ភាសាអង់គ្លេស | 3.65 | ល្អ |
| ៣ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់សម្ភារៈឧបទ្ទេស មុខវិជ្ជាភាសាអង់គ្លេស | 3.45 | ល្អ |
| ៤ | មានផែនការអភិវឌ្ឍ មុខវិជ្ជាភាសាអង់គ្លេស | 3.60 | ល្អ |
| ៥ | ពង្រឹងកម្មវិធីភាសាអង់គ្លេស ក្នុងសហគមន៍ | 3.60 | ល្អ |
| ៦ | ពង្រីកដៃគូរសហការលើកិច្ចការ រៀន និងបង្រៀនភាសាអង់គ្លេស | 3.95 | ល្អ |
| ៧ | ផ្តល់ការលើកទឹកចិត្តបន្ថែម តាមកម្រិតសមត្ថភាពចំណេះដឹងលើលទ្ធផលនិទ្ទេសប្រឡងមុខវិជ្ជាភាសាអង់គ្លេស | 3.75 | ល្អ |
| ៨ | ផ្តល់ការប្រឹក្សាពីសារៈសំខាន់នៃ ការប្រើប្រាស់ភាសាអង់គ្លេស | 3.80 | ល្អ |
| ៩ | ពង្រីកបន្ទប់អនុវត្តភាសាអង់គ្លេស ស្របតាមស្តង់ដារភាសាវិទ្យា | 3.50 | ល្អ |
| ១០ | អនុវត្តយន្តការពិនិត្យតាមដាន លើការសិក្សាភាសាអង់គ្លេស | 3.65 | ល្អ |
| សរុប | | **3.64** | ល្អ |

តារាងខាងលើបង្ហាញពីកត្តាគណៈគ្រប់គ្រងដែលអាចជួយជំរុញឱ្យលទ្ធផលប្រឡងបានល្អប្រសើរឡើងវិញ។ តាមការសង្កេតសមាសភាគនីមួយៗមានមធ្យមភាគខុសៗគ្នា ដែលសមាសភាគចំនួន ប្រាំបួនមានកម្រិតល្អ និងសមាសភាគចំនួន១ទទួលបានកម្រិតតែមធ្យម។ ក្នុងចំណោមសមាសភាគទាំង៩ ផ្នែកដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេបំផុតគឺ ពង្រីកដៃគូរសហការលើកិច្ចការ រៀន និងបង្រៀនភាសាអង់គ្លេស ដែលមាន មធ្យមភាគ =3.95 ទទួលបានកម្រិតល្អ ហើយសមាសភាគដែលទទួលបានលំដាប់ពិន្ទុទាបជាងគេបំផុតគឺ ជំរុញបន្ថែមលើការចូលរួមក្នុងសហគមន៍ភាសាអង់គ្លេស(CAMTESOL) ដែលមានមធ្យមភាគ =3.40 ។

*តារាង 4.20 ៖ ខ. កត្តាគ្រូបង្រៀន*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេស | 4.25 | ល្អណាស់ |
| ២ | បង្រៀនគ្រប់ម៉ោង និងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស | 4.35 | ល្អណាស់ |
| ៣ | ត្រួតពិនិត្យកិច្ចការសិស្ស ជាប្រចាំ | 3.95 | ល្អ |
| ៤ | យកចិត្តទុកដាក់ និងបំប៉នបន្ថែមសិស្សខ្សោយមុខវិជ្ជាភាសាអង់គ្លេស | 3.70 | ល្អ |
| ៥ | ផ្តល់ភាពងាយស្រួលដល់សិស្ស ក្នុងការសិក្សាភាសាអង់គ្លេស | 3.95 | ល្អ |
| ៦ | មានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់លើឯកទេសភាសាអង់គ្លេស | 4.15 | ល្អ |
| ៧ | មានសៀវភៅសិក្សាគោល នៃមុខវិជ្ជាភាសាអង់គ្លេស | 4.35 | ល្អណាស់ |
| ៨ | វាយតម្លៃលើការសិក្សារបស់សិស្សម្នាក់ៗ ដោយតម្លាភាព | 4.15 | ល្អ |
| **សរុប** | | **4.11** | **ល្អ** |

តាមតារាងខាងលើបង្ហាញពីកត្តាគ្រូបង្រៀនដែលអាចជួយជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានប្រសើរឡើង។ ក្នុងតារាងនេះបង្ហាញថាសមាសភាគនីមួយៗមានមធ្យមភាគ

ប្រហាក់ប្រហែលគ្នា ដែលសមាសភាគចំនួន ៥ មានកម្រិតល្អ និងសមាសភាគចំនួន៣ទទួលបានកម្រិតល្អណាស់។ ក្នុងចំណោមសមាសភាគទាំង៨ ផ្នែកដែលមានពិន្ទុខ្ពស់ជាងគេបំផុតលំដាប់ទី១មានសមាសភាគពីរគឺ(១)បង្រៀនគ្រប់ម៉ោង និងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស និង(២) មានសៀវភៅសិក្សាគោល នៃមុខវិជ្ជាភាសាអង់គ្លេស ដែលមាន មធ្យមភាគ = 4.35 ដូចគ្នា។ ការធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេស ស្ថិតក្នុងលំដាប់ទី ៣ ដែលមាន មធ្យមភាគ = 4.25 កម្រិតល្អណាស់។ ក្រៅពីនេះ ស្ថិតក្នុងលំដាប់ពិន្ទុល្អទាំងអស់ ។

*តារាង4.21៖ គ. កត្តាសិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បង្កើតក្លឹបសិក្សា ជាក្រុម លើមុខវិជ្ជាភាសាអង់គ្លេស | 3.65 | ល្អ |
| ២ | សិក្សាមុខវិជ្ជាភាសាអង់គ្លេស មុនពេលរៀនថ្នាក់ទី១២ | 4.30 | ល្អណាស់ |
| ៣ | យកចិត្តទុកដាក់រៀនមុខវិជ្ជាភាសាអង់គ្លេស ដូចមុខវិជ្ជាគោលដទៃទៀត | 3.90 | ល្អ |
| ៤ | សាកល្បងធ្វើលំហាត់ តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការ | 3.75 | ល្អ |
| ៥ | ចូលរួមវគ្គបណ្តុះបណ្តាលបន្ថែម លើសមត្ថភាពចំណេះដឹងភាសាអង់គ្លេស | 3.75 | ល្អ |
| ៦ | មានការបែងចែកពេលវេលា ក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅផ្ទះ | 3.65 | ល្អ |
| ៧ | ពង្រឹងឥរិយាបថឧស្សាហ៍ ព្យាយាម និងមករៀនទៀងទាត់ | 4.00 | ល្អ |
| ៨ | ពង្រឹង ដំណើរការស្វ័យសិក្សា និងត្រៀមលក្ខណះសម្រាប់ប្រឡង | 3.85 | ល្អ |
| **សរុប** | | **3.86** | **ល្អ** |

តារាងខាងលើបង្ហាញពីកត្តាសិស្សដែលអាចជួយឱ្យពួកគេប្រឡងជាប់ច្រើនលើមុខវិជ្ជាភាសាអង់គ្លេស។សមាសភាគដែលបានលើកឡើង មានមធ្យមភាគខុសៗគ្នា ដែលសមាសភាគចំនួន ៧ មានកម្រិតល្អនិងសមាសភាគតែមួយប៉ុណ្ណោះទទួលបានកម្រិតល្អណាស់។ផ្នែកដែលមានពិន្ទុខ្ពស់ជាងគេបំផុត

លំដាប់ទី១គឺសិក្សាមុខវិជ្ជាភាសាអង់គ្លេស មុនពេលរៀនថ្នាក់ទី១២ ដែលមាន មធ្យមភាគ = 4.30 កម្រិតល្អណាស់។ក្រៅពីនេះ ស្ថិតក្នុងលំដាប់ពិន្ទុមធ្យមភាគកម្រិតល្អទាំងអស់ដែលមាន មធ្យមភាគ ពីចន្លោះ មធ្យមភាគ = 3.65 ដល់ មធ្យមភាគ = 4.00 ។

*តារាង 4.22៖ ទិន្នន័យសរុបលើចម្លើយតបរបស់គ្រូបង្រៀន*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | កត្តាគណៈគ្រប់គ្រង | 3.64 | ល្អ |
| ខ | កត្តាគ្រូបង្រៀន | 4.11 | ល្អ |
| គ | កត្តាសិស្ស | 3.86 | ល្អ |
| **សរុប** | | **3.87** | ល្អ |

តាមតារាងមធ្យមភាគសរុបរបស់គ្រូបង្រៀនខាងលើបង្ហាញថា មធ្យមភាគសរុបលើការយល់ឃើញរបស់គ្រូបង្រៀនលើដំណោះស្រាយក្នុងការជួយជំរុញឱ្យសិស្សទទួលបានលទ្ធផលល្អប្រសើរ មានតម្លៃមធ្យមភាគសរុប= 3.87 ទទួលបានកម្រិតល្អ។ ផងដែរនោះ ក្នុងចំណោមសមាសធាតុធំៗទាំង ៣ ក្នុងតារាងសមាសធាតុដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេលំដាប់ទី១គឺ កត្តាគ្រូបង្រៀន ដែលមានតម្លៃ (មធ្យមភាគ= 4.11) លំដាប់ទី២ កត្តាសិស្សមានតម្លៃ (មធ្យមភាគ=3.86) និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាបជាងគេបំផុតគឺ កត្តាគណៈគ្រប់គ្រង(មធ្យមភាគ= 3.64) ដែលសមាសធាតុទាំង ៣ សុទ្ធតែទទួលបានកម្រិតល្អទាំងអស់។

### ៤.៥.២ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង ជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អប្រសើរ

នៅក្នុងតារាងទិន្នន័យនេះបង្ហាញពីមធ្យមភាគនៃចម្លើយតបរបស់គណៈគ្រប់គ្រង ក្នុងការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសនៅក្នុងខេត្តព្រៃវែងបានល្អ

ប្រសើរ តាមបទពិសោធន៍នៃការគ្រប់គ្រងរបស់នាយក នាយករង ទាំង៦វិទ្យាល័យ នៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលបានអនុវត្តន៍ពេលកន្លងមក ។

*តារាង 4.23 ៖ ក. កត្តាគណៈគ្រប់គ្រង*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ជំរុញបន្ថែមលើការចូលរួមក្នុងសហគមន៍ភាសាអង់គ្លេស ( CAMTESOL ) | 4.15 | ល្អ |
| ២ | បង្កលទ្ធភាពគាំទ្រដល់បច្ចេកវិទ្យា ICT សម្រាប់ការរៀន និង បង្រៀនមុខវិជ្ជា ភាសាអង់គ្លេស | 4.05 | ល្អ |
| ៣ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់សម្ភារៈឧបទ្ទេស មុខវិជ្ជាភាសាអង់គ្លេស | 3.55 | ល្អ |
| ៤ | មានផែនការអភិវឌ្ឍ មុខវិជ្ជាភាសាអង់គ្លេស | 4.10 | ល្អ |
| ៥ | ពង្រឹងកម្មវិធីភាសាអង់គ្លេស ក្នុងសហគមន៍ | 3.90 | ល្អ |
| ៦ | ពង្រីកដៃគូរសហការលើកិច្ចការ រៀន និងបង្រៀនភាសាអង់គ្លេស | 3.85 | ល្អ |
| ៧ | ផ្តល់ការលើកទឹកចិត្តបន្ថែម តាមកម្រិតសមត្ថភាពចំណេះដឹងលើលទ្ធផលនិទ្ទេសប្រឡងមុខវិជ្ជាភាសាអង់គ្លេស | 4.05 | ល្អ |
| ៨ | ផ្តល់ការប្រឹក្សាពីសារៈសំខាន់នៃ ការប្រើប្រាស់ភាសាអង់គ្លេស | 3.95 | ល្អ |
| ៩ | ពង្រីកបន្ទប់អនុវត្តភាសាអង់គ្លេស ស្របតាមស្តង់ដារភាសាវិទ្យា | 4.05 | ល្អ |
| ១០ | អនុវត្តយន្តការពិនិត្យតាមដាន លើការសិក្សាភាសាអង់គ្លេស | 4.15 | ល្អ |
| សរុប | | **3.98** | **ល្អ** |

តារាងខាងលើបង្ហាញពីកត្តាគណៈគ្រប់គ្រងតាមទស្សនៈរបស់នាយក នាយករងទាំង២០នាក់កំពុងបម្រើការងារនៅតាមវិទ្យាល័យគោលដៅ។ សមាសភាគដែលបានលើកឡើង មានមធ្យមភាគខុសៗគ្នា ប៉ុន្តែសមាសភាគទាំងអស់សុទ្ធតែទទួលបានពិន្ទុមធ្យមភាគកម្រិតល្អ។ ក្នុងចំណោមសមាសភាគទាំងនោះ សមាសភាគដែលមានពិន្ទុខ្ពស់ជាងគេបំផុតលំដាប់ទី១គឺ ការអនុវត្តយន្តការពិនិត្យតាមដាន លើការសិក្សាភាសាអង់គ្លេស ដែលមាន មធ្យមភាគ = 4.15 ទទួលបានកម្រិតល្អ។ សមាសភាគដែលមានពិន្ទុ

ទាបជាងគេបំផុតគឺ មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់សម្ភារៈឧបទ្ទេស មុខវិជ្ជាភាសាអង់គ្លេស ដែលមាន មធ្យមភាគ = 3.55 ទទួលបានកម្រិតល្អផងដែរ។

*តារាង 4.24 ៖ ខ. កត្តាគ្រូបង្រៀន*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេស | 4.15 | ល្អ |
| ២ | បង្រៀនគ្រប់ម៉ោង និងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសា | 4.15 | ល្អ |
| ៣ | ត្រួតពិនិត្យកិច្ចការសិស្ស ជាប្រចាំ | 3.95 | ល្អ |
| ៤ | យកចិត្តទុកដាក់ និងបំប៉នបន្ថែមសិស្សខ្សោយមុខវិជ្ជាភាសាអង់គ្លេស | 4.10 | ល្អ |
| ៥ | ផ្តល់ភាពងាយស្រួលដល់សិស្ស ក្នុងការសិក្សាភាសាអង់គ្លេស | 4.15 | ល្អ |
| ៦ | មានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់លើឯកទេសភាសាអង់គ្លេស | 4.10 | ល្អ |
| ៧ | មានសៀវភៅសិក្សាគោល នៃមុខវិជ្ជាភាសាអង់គ្លេស | 4.00 | ល្អ |
| ៨ | វាយតម្លៃលើការសិក្សារបស់សិស្សម្នាក់ៗ ដោយតម្លាភាព | 4.10 | ល្អ |
| **សរុប** | | **4.09** | **ល្អ** |

តារាងខាងលើ បង្ហាញពីកត្តាគ្រូបង្រៀន តាមការយល់ឃើញរបស់គណៈគ្រប់គ្រង។ សមាសភាគដែលបានលើកឡើងមានចំនួន ៨ ដែលមានមធ្យមភាគប្រហាក់ប្រហែលគ្នា ដោយទទួលបានពិន្ទុមធ្យមភាគកម្រិតល្អទាំងអស់។ ក្នុងចំណោមសមាសភាគទាំងនោះ សមាសភាគដែលមានពិន្ទុខ្ពស់ជាងគេបំផុតមាន៣សមាសភាគ គឺ (១) ធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេស(២)បង្រៀនគ្រប់ម៉ោងនិងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសានិង(៣)ផ្តល់ភាពងាយស្រួលដល់សិស្សក្នុងការសិក្សាភាសាអង់គ្លេសដែលមាន មធ្យមភាគ = 4.15 ទទួលបានកម្រិតល្អ។ ជារួម ចំពោះកត្តាគ្រូបង្រៀន

គណៈគ្រប់គ្រងភាគច្រើនយល់ឃើញថា គ្រូបង្រៀនជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការជំរុញសិស្សដើម្បីឱ្យទទួលបានលទ្ធផលល្អក្នុងប្រឡង។

*តារាង 4.25 ៖ គ. កត្តាសិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បង្កើតក្លឹបសិក្សា ជាក្រុម លើមុខវិជ្ជាភាសាអង់គ្លេស | 4.00 | ល្អ |
| ២ | សិក្សាមុខវិជ្ជាភាសាអង់គ្លេស មុនពេលរៀនថ្នាក់ទី១២ | 4.15 | ល្អ |
| ៣ | យកចិត្តទុកដាក់រៀនមុខវិជ្ជាភាសាអង់គ្លេស ដូចមុខវិជ្ជាគោលដទៃទៀត | 4.05 | ល្អ |
| ៤ | សាកល្បងធ្វើលំហាត់ តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការ | 4.10 | ល្អ |
| ៥ | ចូលរួមវគ្គបណ្តុះបណ្តាលបន្ថែម លើសមត្ថភាពចំណេះដឹងភាសាអង់គ្លេស | 3.75 | ល្អ |
| ៦ | មានការបែងចែកពេលវេលា ក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅផ្ទះ | 3.75 | ល្អ |
| ៧ | ពង្រឹងឥរិយាបថឧស្សាហ៍ ព្យាយាម និងមករៀនទៀងទាត់ | 3.90 | ល្អ |
| ៨ | ពង្រឹង ដំណើរការស្វ័យសិក្សា និងត្រៀមលក្ខណៈសម្រាប់ប្រឡង | 3.80 | ល្អ |
| **សរុប** | | **3.94** | **ល្អ** |

តារាងខាងលើ បង្ហាញពីកត្តាសិស្ស តាមការយល់ឃើញរបស់គណៈគ្រប់គ្រង នៅវិទ្យាល័យទាំង ៦ ក្នុងខេត្តព្រៃវែង។ សមាសភាគនីមួយៗមានមធ្យមភាគប្រហាក់ប្រហែលគ្នា ដោយទទួលបានពិន្ទុមធ្យមភាគកម្រិតល្អទាំងអស់។ ក្នុងចំណោមសមាសភាគទាំងនោះ សមាសភាគដែលមានពិន្ទុខ្ពស់ជាងគេបំផុតលំដាប់ទី១ គឺ ការសិក្សាមុខវិជ្ជាភាសាអង់គ្លេសមុនពេលរៀនថ្នាក់ទី១២ ដែលមានមធ្យមភាគ = 4.15 ទទួលបានកម្រិតល្អ និង លំដាប់ទី ២ ការសាកល្បងធ្វើលំហាត់ តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការមានមធ្យមភាគ = 4.10។ សមាសភាគដែលមានពិន្ទុទាបជាងគេបំផុតមានពីរ គឺ (១)ចូលរួមវគ្គបណ្តុះបណ្តាលបន្ថែម លើសមត្ថភាពចំណេះដឹងភាសាអង់គ្លេស និង (២)មានការបែងចែកពេល

វេលា ក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅផ្ទះ ដែលមាន មធ្យមភាគ = 3.75 ដូចគ្នា នឹងទទួលបាន កម្រិតល្អដូចគ្នាផងដែរ។

*តារាង 4.26 ៖ ទិន្នន័យសរុបលើចម្លើយតបរបស់គណៈគ្រប់គ្រង*

| **ល.រ** | **បរិយាយ** | **មធ្យមភាគ** | **កម្រិតចង្អុលបង្ហាញ** |
|---|---|---|---|
| ក | កត្តាគណៈគ្រប់គ្រង | 3.98 | ល្អ |
| ខ | កត្តាគ្រូបង្រៀន | 4.09 | ល្អ |
| គ | កត្តាសិស្ស | 3.94 | ល្អ |
| **សរុប** | | **4.00** | ល្អ |

តាមតារាងមធ្យមភាគសរុបរបស់គណៈគ្រប់គ្រងសាលារៀនខាងលើបង្ហាញថា មធ្យមភាគសរុបលើការយល់ឃើញរបស់គណៈគ្រប់គ្រង លើដំណោះស្រាយក្នុងការជួយជំរុញឱ្យសិស្សទទួលបានលទ្ធផលល្អប្រសើរឡើងវិញ មានតម្លៃ(មធ្យមភាគ =4.00) ទទួលបានកម្រិតល្អ។ ផងដែរនោះ ក្នុងចំណោមសមាសធាតុធំៗទាំង ៣ ក្នុងតារាង សមាសធាតុដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេលំដាប់ទី១គឺ កត្តាគ្រូបង្រៀន ដែលមានតម្លៃ(មធ្យមភាគ= 4.09) លំដាប់ទី២ កត្តាគណៈគ្រប់គ្រងសាលា (មធ្យមភាគ= 3.98) និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាបជាងគេបំផុតគឺ កត្តាសិស្សដែលតម្លៃ(មធ្យមភាគ= 3.94) ដែលសមាសធាតុទាំង ៣ សុទ្ធតែទទួលបានកម្រិតល្អទាំងអស់ ។

## ៤.៦ លទ្ធផលនៃការឆ្លើយតបសរុបពី គ្រូបង្រៀន និងគណៈគ្រប់គ្រង លើការជំរុញលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

តាមរយៈការបកស្រាយលើសមាសភាគតាមផ្នែកនីមួយៗដែលទទួលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា នៅតាមវិទ្យាល័យគោលដៅទាំងប្រាំមួយក្នុងខេត្តព្រៃវែង ស្ដីពីការស្វែងរកដំណោះស្រាយក្នុងការជួយជំរុញឱ្យសិស្សទទួលបានលទ្ធផលល្អប្រសើរ អ្នកសិក្សាស្រាវជ្រាវទទួលបានលទ្ធផលដូចខាងក្រោម៖

*តារាង 4.27 ៖ មធ្យមភាគសរុបរបស់គណៈគ្រប់គ្រង និង គ្រូបង្រៀន*

| ល.រ | បរិយាយ | មធ្យម ភាគ | កម្រិតចង្អុល បង្ហាញ |
|---|---|---|---|
| ១ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គណៈគ្រប់គ្រង ដើម្បីជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្ស | **4.00** | ល្អ |
| ២ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គ្រូបង្រៀន ដើម្បី ជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្ស | **3.87** | ល្អ |

តាងទិន្នន័យក្នុងតារាងខាងលើបង្ហាញថា ការឆ្លើយតបរបស់គណៈគ្រប់គ្រងលើការជំរុញឱ្យលទ្ធផលប្រឡងរបស់សិស្សបានល្អស្ថិតក្នុង(មធ្យមភាគ = 4.00) ដែលបង្ហាញថាគណៈគ្រប់គ្រងបានអនុវត្តការងារ គ្រប់គ្រងបានល្អ។ យ៉ាងណាមិញ បើយើងក្រឡេកមើលការឆ្លើយតបរបស់គ្រូបង្រៀនតម្លៃមធ្យមភាគគឺប្រហាក់ប្រហែលទៅនឹងគណៈគ្រប់គ្រងដែរគឺស្ថិតក្នុងរង្វង់(មធ្យមភាគ=3.87) ក្នុងកម្រិតល្អ ដែលតម្លៃនេះត្រូវការការបំពេញបន្ថែមច្រើនជាងគណៈគ្រប់គ្រង់ បើចង់ឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អ។

## ៤.៧ ការពិភាក្សាលើការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេសបានល្អ

ភាសាអង់គ្លេសជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាប្រឡងជាច្រើនសម្រាប់សិស្សថ្នាក់ទី១២ ទាំងផ្នែកវិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គមនៅក្នុងប្រទេសកម្ពុជា។ ថ្វីបើមុខវិជ្ជានេះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិជាច្រើនឆ្នាំហើយក្តី មុខវិជ្ជានេះនៅតែជាការលំបាកចំពោះសិស្សនៅពេលប្រឡងម្តងៗ ហើយលទ្ធផលលើមុខវិជ្ជាសិក្សាមួយនេះក៏នៅតែមិនទាន់បានល្អនៅឡើយ។ ដោយមើលឃើញពីការលំបាកនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវបានកំណត់វត្ថុបំណងក្នុងការស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាព ក្នុងការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសបានល្អប្រសើរឡើងវិញ។

តាមរយៈការប្រមូលទិន្នន័យពីកម្រងសំណួររបស់ គណៈគ្រប់គ្រងសាលា និង លោកគ្រូ-អ្នកគ្រូ អ្នកសិក្សាស្រាវជ្រាវបានកំណត់ដំណោះស្រាយលើកត្តាជាអាទិភាពចំនួន៣គឺ កត្តាគណៈគ្រប់គ្រងសាលា

កត្តាគ្រូបង្រៀន និង កត្តាសិស្ស។ តាមលទ្ធផលទិន្នន័យសរុបក្នុងតារាងទី៤.២៧ បង្ហាញថាមធ្យមភាគសរុបនៃអថេរទាំងពីរគឺស្ថិតនៅត្រឹមកម្រិតល្អនៅឡើយ ដោយតាមទស្សនៈគ្រូបង្រៀនមាន(មធ្យមភាគសរុប= 3.87) និង គណៈគ្រប់គ្រង(មធ្យមភាគសរុប=4.00)។ តាមរយៈការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងបង្ហាញថា គណៈគ្រប់គ្រងសាលាបានអនុវត្តការដឹកនាំការបង្រៀន និងរៀនបានល្អក្នុងកម្រិតដែលអាចទទួលយកបានក្នុងការជានាឱ្យលទ្ធផលរបស់សិស្សបានល្អ។ គណៈគ្រប់គ្រងក៏បានប្រើប្រាស់ប្រព័ន្ធលើទឹកចិត្តដល់គ្រូបង្រៀនដែលមានបំណងអភិវឌ្ឍសមត្ថភាពឱ្យបន្តការសិក្សា និងចូលរួមក្នុងសិក្ខាសាលានានាដែលពាក់ព័ន្ធនឹងឯកទេសបង្រៀនរបស់គ្រូផងដែរ។ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Supvitz, Sirinides,and May,(2014) បានលើកឡើងថាការអនុវត្តការងាររបស់គណៈគ្រប់គ្រងមានសារៈសំខាន់ណាស់ចំពោះការសិក្សារបស់សិស្សដែលមានន័យថា គណៈគ្រប់គ្រងត្រូវការការបំពេញបន្ថែមតែបន្តិចបន្តួចប៉ុណ្ណោះនោះលទ្ធផលសិក្សារបស់សិស្សនិងបានល្អប្រសើរឡើងវិញ។ តែទោះជាយ៉ាងក៏ដោយ តាមការឆ្លើយតបលើដំណោះជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អគឺ គ្រូបង្រៀន ដែលសំដៅដល់គ្រូបង្រៀនមានសមត្ថភាព មានគំនិតច្នៃប្រឌិតលើវិធីសាស្ត្របង្រៀន មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀន។ក្នុងន័យនេះ បើគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយក្នុងឆ្នាំសិក្សានីមួយៗ គោរពពេលវេលាក្នុងការនង្រៀន និងការប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន នោះលទ្ធផលសិក្សារបស់សិស្សពិតជាបានល្អប្រសើរជាក់ជាមិនខាន។ដូចគ្នានោះដែរយោងតាមលទ្ធផលនៃការស្រាវជ្រាវរបស់Phothongsunan, (2014) បង្ហាញថាដើម្បីឱ្យសិស្សទទួលបានជោគជ័យលើការសិក្សារៀនសូត្រ គ្រូបង្រៀនជាអ្នកដើរតួយ៉ាងសំខាន់ក្នុងជំរុញការទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ ហើយសិស្សខ្លួនឯងក៏ត្រូវប្រឹងប្រែងបន្ថែមទ្វេដងផងដែរ។ តាមលទ្ធផលនៃការស្រាវជ្រាវរបស់ Bouchaib, Ahmadou, & Abdelkader,(2018) នៅសាកលវិទ្យាល័យ Chouaib Doukkali University នៅប្រទេសម៉ូរ៉ូកូ បានបង្ហាញថា៖ និស្សិតដែលទទួលបានជោគជ័យក្នុងការសិក្សាភាសាបរទេសភាគច្រើនគឺដោយសារកត្តាខាងក្រៅដែលមានដូចជា៖បរិយា- កាសថ្នាក់រៀន និង វិធីសាស្ត្របង្រៀនជាដើម។តាមរយៈការសិក្សាស្រាវជ្រាវរបស់Bell&Bogan,(2013) បានបង្ហាញដំណោះស្រាយចំនួន៣គឺដំណោះស្រាយ

លើកម្មវិធីសិក្សា គ្រូបង្រៀន និង ថ្នាក់រៀន។ ក្នុងចំណោមដំណោះស្រាយទាំងអស់នេះ អ្នកសិក្សាស្រាវជ្រាវបានបញ្ជាក់ពីជាតុផ្សំតូចៗជាច្រើនដែលជួយជំរុញឱ្យសិស្សចូលចិត្តរៀនភាសាអង់គ្លេសដូចជា៖ ការរៀបចំបរិយាកាសគាំទ្រដល់ការសិក្សា ការបង្ហាញពីអាកប្បកិរិយាវិជ្ជមានរវាងគ្រូ និងសិស្ស ការបង្កើនឱកាសឱ្យគ្នាទៅវិញទៅមក ការបង្រៀនតាមក្រុមតូចៗ... ជាដើម -ល- ។ ដោយការអនុវត្តតាមដំណោះស្រាយទាំងនេះ សិស្សពិតជាពេញចិត្តក្នុងការរៀនសូត្រដែលជានាដល់ការលើកកម្ពស់លទ្ធផលប្រឡងរបស់ពួកគេបាន។ បន្ថែមពីនេះទៀត បើតាមទស្សនៈយោបល់បន្ថែមរបស់ លោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាបានសង្កត់ធ្ងន់ថា ដំណោះស្រាយដែលជួយជំរុញឱ្យសិស្សខិតខំរៀនភាសាអង់គ្លេស គួរផ្តោតសំខាន់លើចំណុចដៅជាអាទិភាពមួយចំនួនដូចជា៖ ការកែលម្អកម្មវិធីសិក្សាភាសាអង់គ្លេសឱ្យផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់គ្រូ និងសិស្ស បន្ថែមម៉ោងបង្រៀនក្នុងមួយសប្តាហ៍ ការបើកវគ្គបំប៉នសមត្ថភាពដល់គ្រូឯកទេសភាសាអង់គ្លេសលើវិធីសាស្ត្របង្រៀនថ្មីៗ បង្កើនសម្ភារៈឧបទ្ទេសក្នុងការបង្រៀន និងរៀន និងពិសេសជាងគេបំផុតគឺការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាប្រឡងមានពិន្ទុពេញដូចមុខវិជ្ជាដទៃទៀត ដែលមានន័យថាគ្មានការកាត់ពិន្ទុពាក់កណ្តាលចោល។ជាងនេះទៅទៀត គណៈគ្រប់គ្រងគួរតែបន្ត និង ពង្រឹងយន្តការពិនិត្យ តាមដាន និងវាយតម្លៃ ជាប្រចាំ លើលទ្ធផលការសិក្សារបស់សិស្ស និង ការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូ ព្រោះគណៈគ្រប់គ្រងសាលាជាអធិការអប់រំអែចិន្ត្រៃយ៍នៅក្នុងមូលដ្ឋានរបស់ខ្លួន ពិសេសគឺសាលារៀនតែម្តង ។ ផងដែរនោះ គ្រូបង្រៀនក៏ត្រូវតែមានសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សក្នុងកិច្ចដំណើរការរៀនសូត្ររបស់ពួកគេ។

សរុបសេចក្តីមក តាមរយៈការពិភាក្សាខាងលើបង្ហាញថាភាពជោគជ័យរបស់សិស្សលើការសិក្សារៀនសូត្រត្រូវការជាចាំបាច់នូវការចូលរួមចំណែកពីគ្រប់ភាគីភាពពាក់ព័ន្ធ ដែលរួមមាន គណៈគ្រប់គ្រង គ្រូបង្រៀន និង សិស្សានុសិស្សខ្លួនឯង។ យ៉ាងណាមិញ ក្នុងចំណោមតួអង្គទាំង ៣ តួអង្គដែលសំខាន់ជាងគេគឺ គ្រូបង្រៀន ព្រោះគ្រូបង្រៀនជាអ្នកនៅជាមួយសិស្សផ្ទាល់ស្ទើរតែរៀងរាល់ថ្ងៃ។មានតែគ្រូបង្រៀនដែលដឹងថាកម្រិតចំណេះដឹងសិស្សរបស់គាត់កម្រិតណា។ក្នុងនោះដែរយើងក៏បានរកឃើញដំណោះ

ស្រាយសំខាន់ៗមួយចំនួនទៀតដែលជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អរួមមាន ៖ ការអភិវឌ្ឍស ម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀននិងរៀន។ អ្នកស្រាវជ្រាវជឿជាក់ថាបើដំណើរការបង្រៀន និងរៀនមាន សម្ភារៈឧបទ្ទេសគ្រប់គ្រាន់ នោះលទ្ធផលនៃការសិក្សារបស់សិស្សប្រាកដជាបានប្រសើរជាងគ្មានសម្ភារៈ ។ គេក៏មានការរំពឹងខ្ពស់ផងដែរ បើទោះបីមានសម្ភារៈគ្រប់គ្រាន់ហើយ តែសិស្សមិនចូលរួមសហការរៀន សូត្រ នោះលទ្ធផលសិក្សាក៏មិនអាចកើតឡើងបានដែរ។ ពេលវេលាក៏ជាកត្តាសំខាន់ផងដែរ ដែលឈាន ដល់ការធ្វើឱ្យមានប្រសិទ្ធភាពក្នុងការសិក្សារៀនសូត្រ ។ ការពិនិត្យ តាមដាន និងវាយតម្លៃជាប្រចាំរបស់គ ណៈគ្រប់គ្រងសាលា ការខិតខំបំពេញការងាររបស់គ្រូបង្រៀនក៏ជាកត្តាដែលរួមចំណែកផងដែរ។ ហេតុ នេះហើយ ដោយឈរលើមូលដ្ឋានជាក់លាក់ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវពិតជាកំណត់បាន នូវដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានប្រសើរឡើងប្រាកដ មែន ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការប្រមូលទិន្នន័យតាមរយៈកម្រងសំណួរដែលរៀបចំឡើងសម្រាប់គណៈគ្រប់-គ្រង លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សនៅតាមវិទ្យាល័យគោលដៅមកវិភាគ និងពិភាក្សាយ៉ាងល្អិតល្អន់ក្នុងការកំណត់កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សពិសេសគឺលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជាភាសាអង់គ្លេស និងការស្វែងរកដំណោះស្រាយក្នុងការជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានប្រសើរ អ្នកសិក្សាស្រាវជ្រាវធ្វើការសន្និដ្ឋានលើលទ្ធផលនៃការស្រាវជ្រាវដូចតទៅ៖

ក្នុងចំណោមកត្តាជះឥទ្ធិពលដែលបានកំណត់ និងការផ្តល់យោបល់បន្ថែមរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និង សិស្សានុសិស្ស កត្តាដែលនាំឱ្យសិស្សមិនសូវទទួលបានលទ្ធផលល្អក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសរួមមាន៖ កត្តាធនធានរូបវន្ត ការប្រើប្រាស់សម្ភារៈឧបទ្ទេសបង្រៀននិងរៀន កត្តាមេរៀនក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស និងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសរបស់សិស្សជាកត្តាជះឥទ្ធិពលជាវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស។ ដោយយោងតាមការវិភាគទិន្នន័យដែលប្រមូលបានពីក្រុមគោលដៅតម្លៃមធ្យមភាគលើកត្តាទាំងបីនេះមានត្រឹមតែ( មធ្យមភាគ=3.32 ដល់ មធ្យមភាគ= 3.64 ) តែប៉ុណ្ណោះ។លទ្ធផលនេះពិតជាបានបង្ហាញពីភាពចាំបាច់ក្នុងការប្រើប្រាស់ ធនធានរូបវន្ត សម្ភារៈឧបទ្ទេសក្នុងកិច្ចដំណើរការបង្រៀននិងរៀនដែលជួយឱ្យសិស្សឆាប់ចាប់បាននូវខ្លឹមសារមេរៀនដែលឆ្លើយតបទៅនឹងទ្រឹស្តីរបស់ Bloom's Taxonomy ទាំងប្រាំមួយគឺ ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។ បន្ថែមពីនេះទៅទៀត មេរៀនក្នុងសៀវភៅសិក្សាគោល ក៏គួរតែមានការកែលម្អដើម្បីឱ្យសមស្របទៅនឹងជីវភាពរស់នៅតាមបរិបទរបស់ប្រទេសជាតិ ដើម្បីឱ្យសិស្សឆាប់យល់បាននូវខ្លឹមសារមេរៀន ជៀសវាងការយកខ្លឹមសារដែលធ្វើឱ្យសិស្សពិបាកយល់ និងសាំញ៉ាំ។ យ៉ាងណាមិញ ការកំណត់គោលដៅមិនច្បាស់លាស់របស់សិស្សក្នុងការ

សិក្សាភាសាអង់គ្លេសក៏ជាកត្តាមួយដែលប្រឈមខ្លាំងផងដែរ ទោះបីជាមាន ធនធានរូបវន្ត សម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀនកម្រិតណា មេរៀនផ្សារភ្ជាប់នឹងជីវភាពរស់នៅកម្រិតណាក៏ដោយ ក៏មិនអាចជួយជ្រោមជ្រែងឱ្យសិស្សទទួលបានលទ្ធផលល្អ និងជោគជ័យក្នុងការសិក្សាដែរ ។ ដូចសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរម្នាក់បានលើកឡើងថា "បើប្អូនៗមិនខិតខំហ្វឹកហាត់បន្ថែមដោយខ្លួនឯងទេ ទោះគ្រូបង្រៀនមកពីឋានព្រះឥន្ទក៏បង្រៀនប្អូនមិនចេះដែរ"។ក្រៅអំពីផលជះជាវិជ្ជមាននេះក៏នៅមានការលើកឡើងពីចំណុចគួរកែលម្អមួយចំនួនទៀតដែលគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ គួរយកចិត្តទុកដាក់រួមមានៈ ពង្រឹងយន្តការនៃការលើកទឹកចិត្ត បង្កើនការយកចិត្តទុកដាក់លើការបង្រៀនឱ្យគ្រប់ជ្រុងជ្រោយ ពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និតជាមួយគ្រប់ភាគីពាក់ព័ន្ធ លើកកម្ពស់ដល់ទំនាក់ទំនងគ្រូ-សិស្ស បន្តការជម្រុញឱ្យសិស្សខិតខំប្រឹងប្រែងរៀនភាសាអង់គ្លេសឡើងវិញនៅកម្រិតថ្នាក់ទី១២ឱ្យកាន់តែខ្លាំងក្លា និងផ្តល់ការប្រឹក្សាដល់សិស្សក្នុងការចាត់ទុកមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសំខាន់ដូចមុខវិជ្ជាសំខាន់ដូចទៅនឹងមុខវិជ្ជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ភាសាខ្មែរ ជីវវិទ្យា -ល- ។

ថ្វីបើមានឥទ្ធិពលជាវិជ្ជមានមួយចំនួនលើលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេសក្តីក៏នៅមានដំណោះស្រាយដែលអាចជម្រុញឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរឡើងវិញផងដែរ។ ក្នុងចំណោមដំណោះស្រាយលើសូចនាករធំៗចំនួន៣ ស្មើនឹង២៦សមាសធាតុតូចៗអ្នកសិក្សាស្រាវជ្រាវរកឃើញថាដំណោះស្រាយដែលអាចជួយជំរុញឱ្យលទ្ធផលសិក្សាភាសាអង់គ្លេសរបស់សិស្សបានល្អប្រសើរឡើងវិញ ចាំបាច់ជាងគេបំផុត គឺគ្រូបង្រៀន ដែលសំដៅដល់ការអនុវត្តកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយ មានវិធីសាស្ត្របង្រៀនល្អ មានគំនិតច្នៃប្រឌិតខ្ពស់តាមស្តង់ដារគ្រូបង្រៀនសតវត្សទី២១ បង្រៀនបានគ្រប់ម៉ោង និងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ពង្រីកដៃគូរសហការលើកិច្ចការរៀននិងបង្រៀនភាសាអង់គ្លេស ផ្តល់ការប្រឹក្សាពីសារៈសំខាន់នៃការប្រើប្រាស់ភាសាអង់គ្លេស មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេសជាប្រចាំ មានផែនការអភិវឌ្ឍមុខវិជ្ជាភាសាអង់គ្លេស កែលម្អបន្ទប់អនុវត្តន៍ភាសាអង់គ្លេសស្របតាមស្តង់ដារភាសាវិទ្យា ផ្តល់ការលើកទឹកចិត្តបន្ថែមតាមកម្រិតសមត្ថភាពចំណេះដឹង

លើលទ្ធផលនិទ្ទេសប្រឡងមុខវិជ្ជាភាសាអង់គ្លេស សិក្សាមុខវិជ្ជាភាសាអង់គ្លេសមុនពេលរៀនថ្នាក់ទី១២ និងចំណុចចុងក្រោយ ការសាកល្បងធ្វើលំហាត់តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការ។ ផ្អែកលើទឡ្ហីករណ៍ដែលមានលើកឡើងខាងនេះ សបញ្ជាក់ឱ្យឃើញថាការអនុវត្តតាមដំណោះស្រាយដែលបានរកឃើញគឺពិតជាអាចជួយឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សាក៏ដូចជាការប្រឡងមុខវិជ្ជាភាសាអង់គ្លេសជាក់ជាមិនខាន។តាមរយៈដំណោះស្រាយទាំងអស់ដែលបានរកឃើញខាងលើ ពិតជាបានឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវក្នុងការស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការ ជំរុញឱ្យសិស្សបន្តខិតខំរៀនសូត្រភាសាអង់គ្លេសឡើងវិញ ពិសេសគឺការធ្វើឱ្យលទ្ធផលរបស់ពួកគេបានល្អក្នុងពេលប្រឡង។ ដូចគ្នានេះដែរ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូបានបន្ថែមទៀតថា បើក្រសួងអប់រំ យុវជន និង កីឡាពិចារណាលើការមិនការកាត់ពិន្ទុពាក់កណ្តាលលើមុខវិជ្ជានេះ សិស្សនឹងងាកមករកការខិតខំសិក្សារៀនសូត្រលើមុខវិជ្ជាភាសាអង់គ្លេសឡើងវិញជាក់ជាមិនខាន។

សរុបសេចក្តីមក ការសិក្សារៀនសូត្រគ្រប់ដំណាក់កាល គ្រប់កម្រិត និងគ្រប់មុខវិជ្ជាតែងតែមានផលវិបាកមិនអាចជៀសផុតបានឡើយ។ដោយមើលឃើញពីការលំបាកនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តជ្រើសយកប្រធានបទខាងលើមកសិក្សា ដោយហេតុថាក្រោយពីការសិក្សាស្រាវជ្រាវនេះនឹងរកឃើញនូវរបកគំហើញថ្មីដើម្បីជាប្រយោជន៍សម្រាប់អ្នកសិក្សាជំនាន់ក្រោយ ពិសេសជាងនោះទៅទៀតគឺការធ្វើលទ្ធផលប្រឡងសិស្សថ្នាក់ទី១២មុខវិជ្ជាភាសាអង់គ្លេសបានល្អប្រសើរឡើងវិញក្រោយពីការសិក្សាស្រាវជ្រាវបានបញ្ចប់ទៅ។ ដូចការរំពឹងទុក អ្នកសិក្សាស្រាវជ្រាវពិតជាកំណត់បាននូវកត្តាចម្បងៗ និងដំណោះស្រាយជាក់លាក់ដែលឆ្លើយតបនឹងវត្ថុបំណងដែលមានកំណត់តាមរយៈសំណួរស្រាវជ្រាវប្រាកដមែន។ ដោយក្តីសង្ឃឹមយ៉ាងមុតមាំលើលទ្ធផលដែលរកឃើញ អ្នកសិក្សាស្រាវជ្រាវមានជំនឿជឿជាក់ថា បើថ្នាក់ដឹកនាំក្រសួង និងអ្នកពាក់ព័ន្ធដាក់ចេញនូវគោលការណ៍ចាំបាច់ទាំងនោះលើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស នោះលទ្ធផលសិក្សារបស់សិស្សពិតជាបានល្អប្រសើរឡើងវិញយ៉ាងពិតប្រាកដ។

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវយល់ឃើញថាការសិក្សាភាសាអង់គ្លេសរបស់សិស្សនៅកម្រិតថ្នាក់ទី១២កំពុងជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវការដោះស្រាយជាចាំបាច់ក្នុងការជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានប្រសើរឡើង។ ដោយហេតុថា ការសិក្សានេះស្ថិតនៅក្នុងបរិបទជំងឺឆ្លងកូវីឌ១៩(COVID-19)ដែលត្រូវការជាចាំបាច់នូវអ្នកសិក្សាបន្តបន្ថែមទៀត ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវកាន់តែមានសង្គតិភាព។ ផ្អែកលើគោលជំហរទាំងអស់នេះ អ្នកសិក្សាស្រាវជ្រាវ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស សូមសំណូមពរដូចតទៅ៖

### ក.ក្រសួងអប់រំ យុវជន និងកីឡា

- បង្កើនការបោះពុម្ពសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស និងផ្តល់ការគាំទ្រការផលិតសម្ភារៈឧបទ្ទេសដល់សាលារៀន ។
- អាចលុបចោលនូវលក្ខខណ្ឌកាត់ពិន្ទុពាក់កណ្តាលលើមុខវិជ្ជាភាសាអង់គ្លេស

### ខ. មន្ទីរអប់រំយុវជន និងកីឡា

- ពង្រឹងការអនុវត្តការបែងចែកភារៈកិច្ចការចុះពិនិត្យ តាមដាន និងវាយតម្លៃ លើការប្រើប្រាស់សៀវភៅសិក្សាគោល និងសម្ភារៈឧបទ្ទេស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និង សិស្ស
- សូមមន្ទីរពង្រឹងការបែងចែកភារៈកិច្ចការចុះពិនិត្យ តាមដាន និងវាយតម្លៃឱ្យបានជាប្រចាំលើការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលា និង លោកគ្រូអ្នកគ្រូក្នុងប្រើប្រាស់សម្ភារៈបង្រៀន និង ធនធានផ្សេងៗទៀត
- សូមមន្ទីរជំរុញការលើកទឹកចិត្តគ្រូបង្រៀនឱ្យផលិតសម្ភារៈឧបទ្ទេសដែលងាយស្រួលផលិតបានដោយខ្លួនឯង

## គ. គណៈគ្រប់គ្រងសាលា

- ណែនាំ និងបែងចែកសៀវភៅសិក្សាគោល សម្ភារៈឧបទ្ទេសសម្រាប់ការអនុវត្តការបង្រៀន និងរៀន ។
- សូមគណៈគ្រប់គ្រងសាលាផ្សព្វផ្សាយពីការណែនាំ និង បច្ចេកទេសថ្មីៗ ដល់លោកគ្រូ អ្នកគ្រូ
- សូមផ្ដល់ការលើកទឹកចិត្តបន្ថែមជូនលោកគ្រូ-អ្នកគ្រូ និងសិស្សទាំងឡាយណាដែលមានស្នាដៃឆ្នើម
- សូមពង្រឹងការប្រើប្រាស់យន្តការអធិការកិច្ចផ្ទៃក្នុងដើម្បីពង្រឹងដល់ការអនុវត្តការងាររបស់គ្រូបង្រៀន
- សូមពង្រឹងការពិនិត្យតាមដានឱ្យបានជាប្រចាំលើវត្តមានរបស់សិស្ស

## ឃ. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

- សូមអ្នកសិក្សាជំនាន់ក្រោយពង្រីកសំណាក និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានទូលំទូលាយជាងនេះ
- សូមអ្នកសិក្សាជំនាន់ក្រោយពង្រីកសំណាក និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានទូលំទូលាយលើកត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងលើមុខវិជ្ជាភាសាបរទេសផ្សេងៗ ទៀត ដូចជា៖ បារាំង ចិន ជប៉ុន -ល- និងសិក្សាស៊ីជម្រៅបន្ថែមលើប្រធានដែលបានសិក្សានេះ ដោយផ្អែកលើការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ។

# ឯកសារយោង


ក្រសួងផែនការ (២០១៩) ជំរឿនប្រជាជន

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) ស្ថិតិ និងសូចនាករអប់រំសាធារណៈ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡា (២០១១) ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី ១១ និង ថ្នាក់ទី ១២

អនុក្រិត្យស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន (២០០៨)

Bell, D., & Bogan, B. L. (2013). English language learners: Problems and solutions found in the research of general practitioners of early childhood. *The Journal of Balanced Literacy Research and Instruction*, *1*(2), 5.

Best, J.W. (1981). Research in Education. Englewood Cliffs, 4th Edition ed., New York, Jersey: Prentice Hall, Inc.

Blase, J., & Blase, J. (2000). Effective instructional leadership. *Journal of educational administration*.

Bouchaib, B., Ahmadou, B., & Abdelkader, S. (2018). High School Students' Attributions of Success in English Language Learning. *International Journal of Instruction*, *11*(2), 89-102.

Cheng, L. (2008). The key to success: English language testing in China. *Language Testing*, *25*(1), 15-37.

Dunlosky, J., Rawson, K. A., Marsh, E. J., Nathan, M. J., & Willingham, D. T. (2013). Improving students’ learning with effective learning techniques: Promising directions from cognitive and educational psychology. *Psychological Science in the Public Interest*, *14*(1), 4-58.

El-Omari, A. H. (2016). Factors affecting students' achievement in English language learning. *Journal of Educational and Social Research*, *6*(2), 9.

Gan, Z., Humphreys, G., & Hamp-Lyons, L. (2004). Understanding successful and unsuccessful EFL students in Chinese universities. *The modern language journal, 88*(2), 229-244.

Jan, H. (2017). Teacher of 21st century: Characteristics and development. *Research on Humanities and Social sciences, 7*(9), 50-54

Mohammed, A. (2016). EFL effective factors: anxiety and motivation and their effect on Saudi college student's achievement. *Arab World English Journal (AWEJ) Vol, 6*.

Mosha, M. A. (2014). Factors affecting students' performance in English language in Zanzibar rural and urban secondary schools. *Journal of Education and Practice, 5*(35), 64-76.

Noom-Ura, S. (2013). English-Teaching Problems in Thailand and Thai Teachers' Professional Development Needs. *English Language Teaching, 6*(11), 139-147.

Papay, J. P., Murnane, R. J., & Willett, J. B. (2010). The consequences of high school exit examinations for low-performing urban students: Evidence from Massachusetts. *Educational Evaluation and Policy Analysis, 32*(1), 5-23.

Phothongsunan, S. (2014). Investigating Thai university students' attributions of English learning success: An international university context. In *A paper presented at The 2014 WEI International Academic Conference Proceedings Vienna, Austria*.

Souriyavongsa, T., Rany, S., Abidin, M. J. Z., & Mei, L. L. (2013). Factors causes students low English language learning: A case study in the National University of Laos. *International Journal of English Language Education*, *1*(1), 179-192.

Supovitz, J., Sirinides, P., & May, H. (2010). How principals and peers influence teaching and learning. *Educational Administration Quarterly, 46*(1), 31-56.

Yim, D. H. (2012). Developing a model of instructional leadership with reference to differentiated instruction of English at Life University in Cambodia. *Scholar: Human Sciences*, *4*(1).

## ឧបសម្ព័ន្ធ ក

## កម្រងសំណួរក្នុងការប្រមូលទិន្នន័យ
## សម្រាប់លោកគ្រូ អ្នកគ្រូ មធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង

ខ្ញុំបាទឈ្មោះ ចែម ចិន្តា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "កត្តាជះឥទ្ធិពលដល់លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីកត្តាដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តព្រៃវែង និងដំណោះស្រាយ លើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យលទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេសកាន់តែល្អប្រសើរ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ ការងារមុខវិជ្ជាភាសាអង់គ្លេស។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូ-អ្នកគ្រូ ជួយផ្តល់ព័ត៌មានពិតជាក់ស្តែងតាមការសង្កេត លើមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យខ្ញុំបាទអាចទទួលបានទិន្នន័យពិតប្រាកដ យកមកសិក្សាវិភាគ ព្រមទាំងអាចឆ្លើយតបទៅនឹងសំនួរស្រាវជ្រាវដែលបានកំណត់។

ខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់ លោកគ្រូ-អ្នកគ្រូ។

### ផ្នែកទី១៖ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. ជាគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ដែលកំពុងបង្រៀន ☐ បាទ/ចាស ☐ ទេ

២. បម្រើការងារនៅ៖.......................................................ឃុំ/សង្កាត់៖...............................

ក្រុង/ស្រុក/ខណ្ឌ៖..............................................ខេត្ត៖................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ១៨-២៣ ឆ្នាំ ☐ ២៤-២៩ឆ្នាំ ☐ ៣០-៣៥ឆ្នាំ ☐ លើសពី៣៥ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ ចប់ថ្នាក់ទី១២ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ

៦.បទពិសោធន៍បង្រៀន៖☐១ ដល់ ៥ ឆ្នាំ ☐៦ ទៅ១០ ឆ្នាំ☐ ១១ទៅ១៥ ឆ្នាំ ☐លើសពី១៥ឆ្នាំ

៧. មុខវិជ្ជាឯកទេស៖.............................................បង្រៀនថ្នាក់ទី៖.........................

**ផ្នែកទី២៖ កត្តាបរិយាកាសរបស់គ្រូ ដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃការប្រឡងមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តព្រៃវែង**

